វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

សាកលវិទ្យាល័យស៊ីដនី

# អភិបាលកិច្ចទឹកស្រោចស្រព នៅកម្ពុជាតាមបែបវិមជ្ឈការ៖

## ការផ្គូផ្គងគោលការណ៍ ទៅនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន



**ជា ជូ, ណាំង តិរុណា,**
Isabelle WHITEHEAD, Phillip HIRSCH **និង** Anna THOMPSON

**ឯកសារពិភាក្សាលេខ ៦២**

**ខែធ្នូ ឆ្នាំ២០១២**

**ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន** CDRI

# អភិបាលកិច្ចទឹកស្រោចស្រព នៅកម្ពុជាតាមបែបវិមជ្ឈការ៖

## ការផ្គូផ្គងគោលការណ៍ ទៅនឹង ស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន

**ឯកសារពិភាក្សាលេខ ៦២**

**ជា ជូ, ណាំង ភិរុណ,**
Isabelle WHITEHEAD, Phillip HIRSCH **និង** Anna THOMPSON

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខែធ្នូ ឆ្នាំ២០១២ ភ្នំពេញ កម្ពុជា**

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្ម រួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

© **រក្សាសិទ្ធិឆ្នាំ២០១២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វបសអ ឡើយ។

ISBN-13: 978-99950–52–54-6

**អភិបាលកិច្ចទឹកស្រោចស្រពនៅកម្ពុជាតាមបែបវិមជ្ឈការ៖** ការផ្គូផ្គងគោលការណ៍ ទៅនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន (Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities)

| | |
|---|---|
| ជា ជូ | អ្នកស្រាវជ្រាវ កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈនៃ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| ណាំង ភិរុណ | អ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| Isabelle WHITEHEAD & Anna THOMPSON | អ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| Philip HIRSCH | សាស្ត្រាចារ្យភូមិវិទ្យាមនុស្ស នៃមហាវិទ្យាល័យវិទ្យាសាស្ត្រ ផ្នែកភូគព្ភសាស្ត្រ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវមេគង្គអូស្ត្រាលី នៃសាកលវិទ្យាល័យស៊ីដនី |

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។*

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤; អ៊ីមែល៖ cdri@cdri.org.kh; http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និងយូ-សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង សេង
បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ពអង្គរអុហ្វសិត រាជធានីភ្នំពេញ
រូបថតក្របមុខ៖ ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ខេត្តពោធិ៍សាត់

# មាតិកា


បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ..... v

សេចក្តីថ្លែងអំណរគុណ ..... vii

ខ្លឹមសារសង្ខេប ..... 1

**១. សេចក្តីផ្តើម** ..... 3

**២. ការសិក្សាឯកសារមានស្រាប់** ..... 5

២.១ ការអភិវឌ្ឍ អភិបាលកិច្ច និងបេសកកម្មអ៊ីដ្រូលិក "Hydraulic Mission" ..... 5

២.២ ការបកស្រាយពាក្យ "ការចូលរួម" ..... 6

២.៣ អភិបាលកិច្ចធារាសាស្ត្រក្នុង "ទ្រង់ទ្រាយសមស្រប"? ..... 8

២.៤ ការខ្សត់ទឹក និងថ្លៃសេវាកម្មធារាសាស្ត្រ ..... 9

**៣. វិធីសាស្ត្រស្រាវជ្រាវ** ..... 11

៣.១ ការជ្រើសរើសទីតាំង និងការគូរផែនទី ..... 12

៣.២ សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ..... 12

៣.៣ ការពិភាក្សាតាមក្រុមស្នូលជាមួយកសិករ និងមេភូមិ ..... 12

៣.៤ ការធ្វើសម្ភាសន៍កសិករ និងការសង្កេតដល់កន្លែង ..... 13

៣.៥ សិក្ខាសាលាថ្នាក់ខេត្ត ..... 13

៣.៦ ការផ្ទៀងផ្ទាត់បញ្ជាក់ទិន្នន័យ ..... 14

**៤. តំបន់សិក្សា** ..... 15

៤.១ ប្រព័ន្ធធារាសាស្ត្ររលួស ..... 15

៤.២ ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ..... 17

៤.៣ ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ..... 18

**៥. លទ្ធផលស្រាវជ្រាវ** ..... 21

៥.១ ការណែនាំបង្ហាញពីលទ្ធផលស្រាវជ្រាវ ..... 21

៥.២ ការរៀបចំអភិបាលកិច្ចជាក់ស្តែង ..... 21

៥.២.១ ភាពពេញច្បាប់នៃ សកបទ ..... 21

៥.២.២ តួនាទីជាក់ស្តែងរបស់សហគមន៍កសិករប្រើប្រាស់ទឹក ..... 22

៥.២.៣ សមត្ថភាពគណកម្មាធិការ សកបទ៖ ធនធាន និងបញ្ហាប្រឈម ..... 25

៥.៣ ការចូលរួម ..... 26

៥.៣.១ ការរួមចំណែករបស់កសិករក្នុងការបង់ថ្លៃសេវាកម្មធារាសាស្ត្រ ...... 26
៥.៣.២ ការចូលរួមរបស់កសិករក្នុងការប្រជុំ និងការបោះឆ្នោត...... 28
៥.៤ ការសម្របសម្រួលអ្នកពាក់ព័ន្ធ ...... 28
៥.៤.១ ការសម្របសម្រួលនៅមូលដ្ឋាន ...... 28
៥.៤.២ ការសម្របសម្រួលក្នុងតំបន់...... 30
**៦. ការពិភាក្សា និង សេចក្តីសន្និដ្ឋាន** ...... 33
៦.១ ភាពស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត...... 33
៦.២ ការកែសម្រួលរបៀបរបបអភិបាលកិច្ចមានចែងរួចហើយ ...... 36
៦.៣ សេចក្តីសន្និដ្ឋាន យោបល់ និង ការស្រាវជ្រាវបន្ថែម ...... 41
**៧. អនុសាសន៍គោលនយោបាយ** ...... 42
**ឯកសារយោង**...... 44
**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន** CDRI ...... 47

# បញ្ជីតារាង និងរូបភាព

តារាង ១៖ ការប្រមូលព័ត៌មានពី កសិករ ក្រុមពិភាក្សាស្នូល និងអ្នកផ្តល់ព័ត៌មានគន្លឹះ...... 14
តារាង ២៖ ព័ត៌មានសង្ខេបស្តីពីប្រព័ន្ធធារាសាស្ត្ររលួស...... 16
តារាង ៣៖ ព័ត៌មានសង្ខេបពីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ...... 18
តារាង ៤៖ ព័ត៌មានសង្ខេបពីប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត...... 20

រូបភាព ១៖ ផែនទីនៃប្រព័ន្ធធារាសាស្ត្រដែលបានសិក្សា...... 11
រូបភាព ២៖ ផែនទីប្រព័ន្ធធារាសាស្ត្ររលួស និងតំបន់សិក្សា...... 15
រូបភាព ៣៖ ផែនទីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងទីតាំងសិក្សាស៊ីជម្រៅ...... 17
រូបភាព ៤៖ ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត និងទីតាំងសិក្សាស៊ីជម្រៅ ...... 19

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| កកបទ | ក្រុមកសិករប្រើប្រាស់ទឹក (Farmer Water User Group) |
| ក្រឃ | ក្រុមប្រឹក្សាឃុំ (Commune Council) |
| សកបទ | សហគមន៍កសិករប្រើប្រាស់ទឹក (Farmer water user community) |
| សេដាក | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា<br>(Centre for Studies and Development of Cambodia) |
| ហ្គ្រេត | ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកទេស<br>(Groupe d'Echanges et de Recherche Technologiques) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AFD | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (Agence Française de Développement) |
| CDRI - វបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Resource Institute) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| GWP | ដៃគូអភិវឌ្ឍន៍ធនធានទឹកពិភពលោក (Global Water Partnership) |
| GWP-TAC | ដៃគូអភិវឌ្ឍន៍ធនធានទឹកពិភពលោក--គណៈកម្មាធិការប្រឹក្សាបច្ចេកទេស<br>(Global Water Partnership – Technical Advisory Committee) |
| ICWE | សន្និសីទអន្តរជាតិស្តីពីធនធានទឹក និងបរិស្ថាន |
| IMT | ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (Irrigation Management Transfer) |
| ISF | ថ្លៃសេវាកម្មធារាសាស្ត្រ (Irrigation Service Fee) |
| IWMI | វិទ្យាស្ថានគ្រប់គ្រងធនធានទឹកអន្តរជាតិ (International Water Management Institute) |
| IWRM | ការគ្រប់គ្រងទឹកចម្រុះ (Integrated Water Resources Management) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency) |
| KI | អ្នកផ្តល់ព័ត៌មានគន្លឹះ (Key Informant) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resource and Meteorology) |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ<br>(National Committee for the Management of Decentralisation and De-concentration) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non Government Organisation) |
| O&M | ដំណើរការ និងការថែទាំ ( Operation and Maintenance ) |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>( Provincial Department of Agriculture, Forestry and Fisheries ) |
| PDOWRAM | មន្ទីរធនធានទឹក និងឧតុនិយម ( Provincial Department of Water Resource and Meteorology ) |
| PIMD | ការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍<br>( Participatory Irrigation Management and Development ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា ( Royal Government of Cambodia ) |
| SCIRIP | គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទនិងធារាសាស្ត្រស្ទឹងជីនិត<br>( Stung Chinit Irrigation and Rural Infrastructure Project ) |
| UNCED | សន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ<br>( United Nations Conference on Environment and Development ) |
| WCD | គណៈកម្មការទំនប់វារីអគ្គិសនីពិភពលោក ( World Commission on Dams ) |

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធ សូមអរគុណយ៉ាងជ្រាលជ្រៅដល់ការរួមចំណែក និងគាំទ្រពីសំណាក់មន្ត្រីដូចខាងក្រោមដែលបានជួយឲ្យការសិក្សានេះអាចអនុវត្តទៅបាន។

ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី ចំពោះជំនួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដ៏សំខាន់ ផ្តល់តាមរយៈ AusAID ចំពោះ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP) ដែលមានវិទ្យាស្ថាន CDRI ជាដៃគូ។ យើងខ្ញុំក៏សូមអរគុណផងដែរដល់ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID) ចំពោះការផ្តល់ហិរញ្ញប្បទានដល់ កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ របស់ CDRI។ ជំនួយគាំទ្រដ៏សប្បុរសរបស់ស្ថាប័នទាំងបី បានញ៉ាំងឲ្យការសិក្សានេះអាចអនុវត្តទៅបានប្រកបដោយជោគជ័យ។

យើងខ្ញុំសូមសំដែងការដឹងគុណដល់លោកបណ្ឌិត ពេជ្រ សុខេម លោកសាស្ត្រាចារ្យ Joakim Ojendal និងលោកស្រីបណ្ឌិត Rebecca F. Catalla ដែលបានផ្តល់ជាយោបល់ និងអនុសាសន៍ដ៏មានប្រយោជន៍ដល់ការសិក្សានេះ។ ប្រសិនបើគ្មានការរួមចំណែកទាំងនេះទេ លទ្ធផលដូចមានរៀបរាប់ក្នុងអត្ថបទនេះ ក៏មិនបានរឹងប៉ឹងដូច្នេះដែរ។

យើងខ្ញុំសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅ ដល់សហសេវិកនៅវិទ្យាស្ថាន CDRI និងនៅតាមស្ថាប័នជាច្រើនទៀត។ ដោយឡែកនៅ CDRI យើងខ្ញុំសូមអរគុណដល់លោកបណ្ឌិត កុយ រ៉ា លោក អ៊ូ ស៊ីវហួច និង លោក គឹម សួ ដែលបានជួយសម្របសម្រួលដំណើរការរៀបចំ និងផ្សព្វផ្សាយអត្ថបទនេះ។ យើងខ្ញុំសូមអរគុណដល់ លោក រស់ បានសុខ ចំពោះការចុះស្រាវជ្រាវដល់កន្លែង លោក អ៊ុច ឈួង និង លោកស្រី ឈឹម រម្យមុនី សម្រាប់ជំនួយការរដ្ឋបាល និងលោកស្រី Susan Watkins ចំពោះការផ្តល់យោបល់ជួយកែលំអអត្ថបទឲ្យមានលក្ខណៈងាយស្រួលសម្រាប់អ្នកអាន។ យើងខ្ញុំសូមអរគុណជាពន្លឹកដល់ការគាំទ្រ និងការយកចិត្តទុកដាក់របស់ លោក Larry Strange នាយកប្រតិបត្តិនៃ CDRI និង លោក អ៊ឹង ស៊ានលី នាយកផ្នែកប្រតិបត្តិការនៃ CDRI។ ចំពោះស្ថាប័នខាងក្រៅវិញ យើងខ្ញុំសូមអរគុណដល់ លោក ចាន់ ស៊ីណាត មន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម (MOWRAM) និង លោក ម៉ក់ សឿន មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ចំពោះការជួយគាំទ្រផ្នែកបច្ចេកទេស។ យើងសូមអរគុណជាពិសេសដល់លោក នង គាមនី នៃក្រសួងធនធានទឹកនិងឧតុនិយម និង លោក ខោល ម៉ានី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានជួយសម្របសម្រួលដល់ការចុះស្រាវជ្រាវដល់កន្លែង។

ការសិក្សានេះអាចសម្រេចទៅបាន ក៏ដោយសារមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីសំណាក់អ្នកឆ្លើយសម្ភាសន៍ទាំងអស់ ដែលបានចែករំលែកការយល់ដឹងដ៏មានតម្លៃអំពីស្ថានភាពនៅមូលដ្ឋាន។ អ្នកដឹកនាំសហគមន៍កសិករប្រើប្រាស់ទឹក ប្រជាកសិករ មន្ត្រីមកពីមន្ទីរខេត្តនានា ក្រុមប្រឹក្សាឃុំ (ក្រឃ) និងមេភូមិនៅតាមតំបន់ប្រព័ន្ធធារាសាស្ត្រទាំងបីដែលបានជ្រើសរើសសម្រាប់ការសិក្សា បានជួយច្រើនណាស់តាមការចែករំលែកចំណេះដឹងពីមូលដ្ឋាន និងយោបល់របស់ខ្លួន នៅក្នុងបទសម្ភាសន៍ជាបុគ្គល បទសម្ភាសន៍ជាក្រុម ការពិភាក្សាជាក្រុម សិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានផ្សេងៗ និងការចូលរួមយ៉ាងសកម្មក្នុង វិធីសាស្ត្រស្រាវជ្រាវប្រកបដោយការចូលរួមអនុវត្តដោយគម្រោងស្រាវជ្រាវនេះ។ អត្ថបទនេះ គឺជាផលសម្រេចរួមគ្នាមួយរបស់អ្នកឆ្លើយសម្ភាសន៍ និងអ្នកនិពន្ធ ហើយយើងខ្ញុំសូមអរគុណអស់ពីដួងចិត្តដល់អ្នកទាំងនោះផងដែរ។

# ខ្លឹមសារសង្ខេប

បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងអនុវត្តកម្មវិធីសំខាន់នៃការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។ ជាទូទៅ ការរៀបចំផ្នែកបច្ចេកទេសនៃ គម្រោងធារាសាស្ត្រកាន់តែមានភាពល្អប្រសើរឡើង ប៉ុន្តែនៅមានបញ្ហាប្រឈមខាងអភិបាលកិច្ចធារាសាស្ត្រជាច្រើនដែលរារាំង ដំណើរការប្រកបដោយប្រសិទ្ធភាព សមភាព និងនិរន្តរភាពនៃប្រព័ន្ធស្រោចស្រព។ ការសិក្សានេះផ្តោតលើបញ្ហាថា តើអភិបាលកិច្ចធារាសាស្ត្រ ស៊ីគ្នានឹងតម្រូវការនៃគម្រោងធារាសាស្ត្រដែរឬទេ ដោយពិនិត្យលំអិតពីជាតិពន្ធុសាស្ត្រនៃគម្រោងបីគឺ រលួស និងស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ និងដំណាក់អំពិល ក្នុងខេត្តពោធិ៍សាត់ និងដោយស្រាវជ្រាវ ជាពិសេសលើ ១) កម្រិតស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច ហើយនិងតម្រូវការអភិបាលកិច្ចពិតៗដែលកំណត់ដោយ លក្ខណៈរូបវ័ន្តនៃប្រព័ន្ធធារាសាស្ត្រ និង ២) មធ្យោបាយកែសម្រួលរបៀបរៀបចំអភិបាលកិច្ចដែលបានកំណត់ហើយក្នុងពេលកន្លងមក ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅតាមមូលដ្ឋាន។

ការសិក្សាបានរកឃើញចំណុចខុសប្លែកគ្នារវាង របៀបរបបអនុវត្តអភិបាលកិច្ចជាក់ស្តែង និងគោលការណ៍អភិបាលកិច្ចល្អ ដូចមានចែងក្នុងឯកសារ ការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (PIMD) និងការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) និងបរិបទនៃហេដ្ឋារចនាសម្ព័ន្ធនិងទីតាំងគម្រោង។ ការសិក្សាបានរកឃើញថា ១) វិសាលភាពតំបន់គ្រប់គ្រង វាធំលើសពីចំនួនសកម្មជន និងសមាជិកនៃសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ហើយអ្នកទាំងនោះនៅមានកង្វះខាតចំណេះដឹងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុ ដើម្បីជួសជុល អភិវឌ្ឍ និងថែទាំប្រព័ន្ធធារាសាស្ត្រ និង ២) របៀបរបបជាក់ស្តែងនៃការគ្រប់គ្រងធារាសាស្ត្រនៅកម្រិតប្រព័ន្ធនិងអនុប្រព័ន្ធ មានការខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ពីគោលការណ៍នៃ PIMD និង IWRM។ ឧទាហរណ៍ តួនាទីជាក់ស្តែងរបស់ សកបទ មិនបានគ្រប់តាមសេចក្តីចែងនៅក្នុងអាណត្តិរបស់ខ្លួនទេ ហើយការអនុវត្តក៏មិនបានល្អដែរ។

តួនាទីដ៏សំខាន់បំផុតរបស់ សកបទ នៅតាមប្រព័ន្ធធារាសាស្ត្រដែលបានសិក្សានីមួយៗគឺ ធ្វើជាអ្នកសម្របសម្រួលរវាងកសិករ និងមន្ទីរធនធានទឹកនិងឧតុនិយម (PDOWRAM) មិនមែនតួនាទីចម្បងនៅក្នុងអាណត្តិខ្លួន ពោលគឺការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រឲ្យមានប្រសិទ្ធភាពនោះទេ។ សកបទ ក៏មានតួនាទីធ្វើការបែងចែកទឹកពីប្រឡាយមេ និងប្រឡាយរង ដោះស្រាយទំនាស់តូចតាចរវាងកសិករនៅក្នុងសហគមន៍ និងប្រមូលថ្លៃសេវាកម្មធារាសាស្ត្រដែរ ប៉ុន្តែការអនុវត្តភារកិច្ចទាំងនេះ កន្លងមកមិនបានទៀងទាត់ល្អ និងមានចន្លោះខ្វះខាតច្រើន។ ការសិក្សាបានសន្និដ្ឋានថា របៀបរៀបចំអភិបាលកិច្ចបច្ចុប្បន្ន វាមិនសូវស្របតាមតម្រូវការផុសចេញពីលក្ខណៈរូបវ័ន្តនៃគម្រោង និងទ្រឹស្តីខាងអភិបាលកិច្ចល្អ ដែលមានចែងនៅក្នុងគោលនយោបាយនានានៃ PIMD ទេ។ បន្ទាប់មក ការសិក្សាបានលើកជាយោបល់ថា ដើម្បីដោះស្រាយបញ្ហាខាងលើ គួរតែធ្វើការកែប្រែគោលនយោបាយ និងអាណត្តិរបស់ សកបទ ក៏ដូចជា រចនាសម្ព័ន្ធអភិបាលកិច្ច ដើម្បីផ្តល់ការគាំទ្រឲ្យបានកាន់តែច្រើនដល់ សកបទ និងដើម្បីកែលំអឲ្យពួកគាត់អាចធ្វើការកាន់តែស៊ីសង្វាក់គ្នាទៅនឹងក្របខ័ណ្ឌអភិបាលកិច្ចមានស្រាប់។

# ១ សេចក្តីផ្តើម

បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងអនុវត្តកម្មវិធីដ៏សំខាន់នៃការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ដែលគំរោងធារាសាស្ត្រខ្លះមានទំហំធំ ហើយខ្លះទៀតមានទំហំមធ្យម និងតូច។[១] ការពង្រីកប្រព័ន្ធធារាសាស្ត្រ រួមមាន ការសាងសង់ប្រព័ន្ធថ្មី និងការស្តារប្រព័ន្ធចាស់ៗដែលខូចខាតអស់ ឬទ្រុឌទ្រោមពេក ឬសាងសង់មិនបានល្អ ជាពិសេស ប្រព័ន្ធធារាសាស្ត្រដែលសាងសង់ក្រោមរបបខ្មែរក្រហម ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩។ បច្ចេកទេសកសាងប្រព័ន្ធធារាសាស្ត្រ កំពុងមានភាពរីកចម្រើនឡើង ប៉ុន្តែនៅមានបញ្ហាប្រឈមផ្នែកអភិបាលកិច្ចធារាសាស្ត្រជាច្រើនទៀត ដែលរារាំងដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៃប្រព័ន្ធទាំងនេះ។

អភិបាលកិច្ចធារាសាស្ត្រ ជាផ្នែកមួយដ៏សំខាន់នៃការធ្វើផែនការ ការសាងសង់ និងប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ មានហេតុផលចម្បងពីរដែលត្រូវយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើអភិបាលកិច្ចល្អគឺ ទី១ ទឹកស្រោចស្រពត្រូវតែគ្រប់គ្រងយ៉ាងណាឲ្យវាបានទៅដល់តំបន់ និងកសិករជាគោលដៅ ដោយគេអាចស្មានដឹងជាមុនមានបរិមាណគ្រប់គ្រាន់ និងទាន់ពេលវេលា និងទី២ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្គត់ផ្គង់ទឹក ត្រូវតែរៀបចំ សាងសង់ និងថែទាំយ៉ាងណា ឲ្យវាអាចបន្តផ្តល់អត្ថប្រយោជន៍ប្រកបដោយសមធម៌ដល់ប្រជាជននៅមូលដ្ឋាន។ ប្រការនេះមិនមែនគ្រាន់តែជាបញ្ហាគ្រប់គ្រងផ្នែកបច្ចេកទេសសាមញ្ញនោះទេ។ បទពិសោធន៍ផ្នែកធារាសាស្ត្រក្នុងតំបន់ជាច្រើនលើសាកលលោក បង្ហាញថា បញ្ហាថាតើនរណាជាអ្នកធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង សម្រេចនៅកម្រិតណា និងក្នុងនាមអ្នកណានោះ វាសំខាន់ខ្លាំងណាស់ដើម្បីឲ្យហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធអាចដំណើរការបានល្អ និងផ្តល់អត្ថប្រយោជន៍ដូចការរំពឹងទុក។ បញ្ហាខាងអភិបាលកិច្ច រួមមាន ការរៀបចំរចនាសម្ព័ន្ធអាជ្ញាធរ និងបែបបទធ្វើសកម្មភាពរួមគ្នា តាមរយៈស្ថាប័នសមស្រប គួបផ្សំនឹងរបៀបដឹកនាំមិនផ្លូវការផ្សេងៗ គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ការបែងចែកទឹកប្រកបដោយសមធម៌ និងការប្រើប្រាស់និងអភិរក្សធនធានទឹកប្រកបដោយនិរន្តរភាព។

បញ្ហាអភិបាលកិច្ចទទួលបានការចាប់អារម្មណ៍ច្រើននៅក្នុង ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ថ្មីៗរបស់ប្រទេសកម្ពុជា និងក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (D&D) ដោយរួមបញ្ចូលទាំងវិស័យធារាសាស្ត្រផងដែរ។ គំនិតបែបថ្មី រួមមាន គោលការណ៍ណែនាំនានាស្តីពីរបៀបអនុវត្តដ៏ល្អថ្នាក់អន្តរជាតិ ជាពិសេស ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមានការចូលរួម និងកិច្ចអភិវឌ្ឍ (PMID) និងការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (IMT)[២] ។ វិសហមជ្ឈការនៃអភិបាលកិច្ចធារាសាស្ត្រ អាចឃើញច្បាស់នៅកម្រិតប្រព័ន្ធធារាសាស្ត្រ ក្នុងទម្រង់ជា សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ដែលមានតួនាទីចម្បងក្នុងអភិបាលកិច្ច (ដោយរួមសហការជាដៃគូជាមួយ មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត) ដើម្បីបម្រើដល់ ប្រជាកសិករអ្នកប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនោះ។ បញ្ហាប្រឈមផ្នែកអភិបាលកិច្ចរបស់ សកបទ រួមមាន ការចូលរួម តម្លាភាព វិមជ្ឈការ ការគ្រប់គ្រងធនធានទឹកចម្រុះ និង ការឈានទៅអនុវត្តរបបថវិកាផ្អែកលើប្រាក់បង់ដោយអ្នកប្រើប្រាស់ទឹក។

---

១ សម្រាប់គោលបំណងនៃការសិក្សានេះយើងកំណត់ន័យថាប្រព័ន្ធធារាសាស្ត្រខ្នាតធំត្រូវមានតំបន់គ្របគ្រាធំជាង៥០០០ហិកតា ប្រព័ន្ធខ្នាតមធ្យម ត្រូវមានទំហំពី ២០០-៥០០០ហិកតា ហើយប្រព័ន្ធខ្នាតតូច ត្រូវមានទំហំតូចជាង ២០០ហិកតា។

២ គោលការណ៍ IMT៖ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ត្រូវផ្ទេរទៅឲ្យ សកបទ ដូចមានចែងក្នុងគោលនយោបាយទឹក៖ សារាចរលេខ០១ ចុះថ្ងៃទី១១ មករា ១៩៩៩ (ភ្នំពេញ: MOWRAM)។

អភិបាលកិច្ចធារាសាស្ត្រ រួមមាន មុខងារសំខាន់ៗនៃការបែងចែកទឹក ការសម្របសម្រួលដើម្បីធានានូវការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពពីសំណាក់ កសិករនៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម នៃប្រភពទឹកជាមួយគ្នា ការថែទាំប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទំនាស់រវាងអ្នកប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រជាមួយគ្នា។ ការអនុម័តយកម៉ូដែល សកបទ បានផ្តល់នូវភាពជាក់លាក់ផ្នែកស្ថាប័ន ព្រមទាំងក្របខ័ណ្ឌច្បាប់និងគោលនយោបាយសម្រាប់អភិបាលកិច្ចធារាសាស្ត្រនៅមូលដ្ឋានក៏ពិតមែន ប៉ុន្តែបទពិសោធន៍កន្លងមកមានលទ្ធផលចម្រុះ។ សកបទ ទាំងអស់ អនុវត្តការងារតាមគោលការណ៍ និងបទបញ្ញត្តិដូចៗគ្នា ប៉ុន្តែ អភិបាលកិច្ចប្រព័ន្ធធារាសាស្ត្រតាមបែបវិមជ្ឈការដែលដំណើរការតាមរយៈ សកបទ មិនបានអនុវត្តនៅក្នុងក្របខ័ណ្ឌសង្គម ឬរូបវ័ន្តដូចគ្នានោះទេ។

អត្ថបទនេះបង្ហាញពីការសិក្សាថា តើអភិបាលកិច្ចលើប្រព័ន្ធធារាសាស្ត្របច្ចុប្បន្ន វាស៊ីគ្នាប៉ុណ្ណាទៅនឹង តម្រូវការនៃប្រព័ន្ធធារាសាស្ត្រផ្សេងៗគ្នា។ ប្រព័ន្ធមួយកន្លែងៗ មានទំហំ សណ្ឋាន និងប្រភេទខុសៗគ្នា ហើយគោលការណ៍ណែនាំដែល សកបទ យកមកអនុវត្ត ក៏មានលក្ខណៈខុសប្លែកគ្នាខ្លះដែរ។ តាមរយៈការសិក្សាលំអិតពីជាតិពន្ធុសាស្ត្រនៃប្រព័ន្ធធារាសាស្ត្របីកន្លែង ឯកសារនេះបង្ហាញពីកម្រិតស៊ីគ្នារវាង របៀបរៀបចំអភិបាលកិច្ច និងតម្រូវការពិតៗផុសចេញពីស្ថានភាពជាក់ស្តែងនៃប្រព័ន្ធ។ អត្ថបទនេះពិនិត្យផងដែរថា តើរបៀបរៀបចំអភិបាលកិច្ចដែលបានចែងហើយ អាចកែសម្រួលបែបណាបាន ដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋាន ព្រមទាំងផ្តល់ការយល់ដឹងស៊ីជម្រៅពីតម្រូវការភាពបត់បែន និងការបើកចំហសម្រាប់ការសម្របខ្លួនតាមអភិបាលកិច្ចមូលដ្ឋាន។

អត្ថបទនេះ ផ្តោតលើសំណួរស្រាវជ្រាវពីរ គឺ៖

១. ការផ្គូផ្គងរបៀបរៀបចំអភិបាលកិច្ច ជាមួយនឹងប្រព័ន្ធធារាសាស្ត្ររូបវ័ន្ត៖ តើការអនុវត្ត និងរចនាសម្ព័ន្ធអភិបាលកិច្ចដែលមានស្រាប់ មានភាពស៊ីគ្នាល្អប៉ុណ្ណាទៅនឹងសណ្ឋាន និងទំហំប្រព័ន្ធធារាសាស្ត្រ?

២. ការផ្គូផ្គងអភិបាលកិច្ចជាក់ស្តែង ទៅនឹងអភិបាលកិច្ចតាមទ្រឹស្តី៖ តើការអនុវត្តអភិបាលកិច្ចធារាសាស្ត្រ ក្នុងការថែទាំប្រព័ន្ធស្រោចស្រព ការបែងចែកទឹក ការសម្របសម្រួល និងការគ្រប់គ្រងទំនាស់ វាស៊ីគ្នាល្អប៉ុណ្ណាទៅនឹង "ទ្រឹស្តីសម្រាប់ការអនុវត្ត" និងការសន្មតនៅក្នុងគំនិតផ្តួចផ្តើមអភិបាលកិច្ចផ្សេងៗ ដូចជា ការផ្ទេរការគ្រប់គ្រងធារាសាស្ត្រ (IMT) និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (PMID) ដែលបានកំណត់សម្រាប់ សកបទ? ហេតុអ្វី? (តើមានលក្ខខណ្ឌជាក់លាក់អ្វីខ្លះនៅកម្ពុជា ដែលធ្វើឲ្យគំនិតផ្តួចផ្តើមទាំងនោះមានជោគជ័យ ទទួលបរាជ័យ ឬត្រូវធ្វើការកែប្រែ?)

# ២ ការសិក្សាឯកសារមានស្រាប់

ជារឿយៗ គេចាត់ទុកប្រព័ន្ធធារាសាស្ត្រជាមូលដ្ឋាននៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនៅតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅកម្ពុជា ដែលប្រជាពលរដ្ឋមួយភាគធំនៅតំបន់ជនបទប្រកបរបរធ្វើស្រែ។ ថ្មីៗនេះ មានការជជែកវែកញែកគ្នាជាខ្លាំងពីអភិបាលកិច្ច និងប្រសិទ្ធភាពធារាសាស្ត្រ ដោយសារបានពិនិត្យឃើញកំណើនវិនិយោគបរទេស និងពាក់កណ្តាលបរទេសលើផ្នែកធារាសាស្ត្រនិងផលិតកម្មស្រូវ និងការដាក់អនុវត្តគោលនយោបាយស្រូវថ្មីនៅកម្ពុជា។ ការជជែកវែកញែកនេះ បានជួយបំផុសចំណាប់អារម្មណ៍ច្រើនណាស់លើផ្នែកធារាសាស្ត្រ។ កម្ពុជាតែងជួបបញ្ហាខ្សត់ទឹកសម្រាប់សេដ្ឋកិច្ច។ ទោះបីជាតំបន់ភាគច្រើនសម្បូរទឹកក៏ដោយ (ជាពិសេសនៅរដូវវស្សា ពីខែឧសភា ដល់ តុលា) ក៏ជារឿយៗ សហគមន៍ជនបទ មិនអាចប្រើប្រាស់ទឹកទាំងនោះទេ ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធ។ មន្ទីរក្រសួងរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសហគមន៍នានា បានដឹងច្បាស់ពីបញ្ហានេះ ហើយមានការយល់ស្របគ្នាជាទូទៅថា ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាមិនទាន់ដំណើរការបានពេញកម្លាំងនោះទេ (ឧទាហរណ៍ ADB 2008)។ ប៉ុន្តែមតិយល់ស្របគ្នានេះ មិនទាន់មានលក្ខណៈស៊ីជម្រៅនៅឡើយ។ ក្រុមមនុស្សផ្សេងៗគ្នា មានការយល់ដឹង និងដោះស្រាយបញ្ហាអភិវឌ្ឍន៍ធារាសាស្ត្រតាមមធ្យោបាយខុសគ្នាស្រឡះ ទៅតាមប្រវត្តិផ្នែកមនោគមវិជ្ជា និងបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ។ ការសិក្សាឯកសារមានស្រាប់នេះ សំដៅកំណត់ ពន្យល់ និងវិភាគទស្សនៈទាំងនោះនៅក្នុងបរិបទកម្ពុជា អាស៊ីអាគ្នេយ៍ និងសាកល។ ផ្នែកនេះនឹងពិនិត្យពីទ្រឹស្តី និងរបៀបអនុវត្តសំខាន់ៗ ដើម្បីផ្ទៀងផ្ទាត់លើសម្មតិកម្មសំខាន់ពីរ (ដូចអាចដឹងបានតាមរយៈសំណួរស្រាវជ្រាវ) គឺ ទី១-ប្រព័ន្ធធារាសាស្ត្ររូបវ័ន្ត មិនមែនសុទ្ធតែមានទំហំសមស្រប និងស៊ីគ្នានឹងស្ថាប័នសង្គមដែលមានស្រាប់នោះឡើយ។ ទី២-គំរូអភិបាលកិច្ចល្អ មិនមែនសុទ្ធតែឆ្លុះបញ្ចាំងពីអ្វីដែលកើតឡើងនៅពេលអនុវត្តនោះទេ។

## ២.១ ការអភិវឌ្ឍ អភិបាលកិច្ច និង បេសកកម្មអ៊ីដ្រូលិក (Hydraulic Mission)

*ការណែនាំពីមធ្យោបាយផ្សេងៗសម្រាប់កំណត់ក្របខ័ណ្ឌបញ្ហាធារាសាស្ត្រ*

ការអភិវឌ្ឍធារាសាស្ត្រ អាចកំណត់ចេញជា បញ្ហាប្រឈមខាងបច្ចេកទេសវិស្វកម្ម ការងារសម្របសម្រួលផ្នែកសង្គម ឬបញ្ហាទាញយកប្រយោជន៍ពីធនធានទឹកនៅក្នុងកម្រិតព្រំដែនមិនខូចខាតដល់អេកូឡូស៊ី។ នៅកម្ពុជា ការយល់ឃើញផ្សេងៗគ្នានេះពីបញ្ហាគ្រប់គ្រងទឹក បាននាំឲ្យមានដំណោះស្រាយខុសៗគ្នា (និងតែងមានការខ្វែងមតិគ្នា) ក្នុងការគ្រប់គ្រងទឹក។

កន្លងមក ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងស្ថាប័នរដ្ឋាភិបាលថ្នាក់កណ្តាល បានសង្កត់ធ្ងន់លើទិដ្ឋភាពជលសាស្ត្រ និងធារាសាស្ត្ររូបវ័ន្ត (Coward 1976; Barker & Molle 2004)។ ដើម្បីសម្រេចបេសកកម្មអ៊ីដ្រូលិកនាសតវត្សរ៍ទី២០ ប្រព័ន្ធការិយាធិបតេយ្យខាងធនធានទឹកទាំងនេះ បានផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាងគំនិតផ្តួចផ្តើមផ្នែកសង្គមដែលមានភាពអរូបី (Reisner 1986; Molle *et al.* 2009)។ ចាប់តាំងពីទសវត្សរ៍១៩៦០ ដល់ដើមទសវត្សរ៍១៩៨០ វិស្វករសំណង់ស៊ីវិល និងអ្នកជំនាញបច្ចេកទេសនានា បានលើកកម្ពស់ការសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតធំថាជា មាគ៌ាសម្រាប់ការអភិវឌ្ឍនៅអាស៊ីអាគ្នេយ៍ (Barker & Molle 2004; Ojendal 2000)។ ក្នុងន័យយុទ្ធសាស្ត្រវិញ របៀបវារៈអភិវឌ្ឍន៍នេះ ទទួលរងឥទ្ធិពលយ៉ាងច្រើនពីនយោបាយភូមិសាស្ត្រនៃសង្គ្រាមត្រជាក់។ ទោះយ៉ាងនេះក្តី ចំណូលចិត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធប្រើដើមទុនខ្ពស់នេះ ក៏អាចយល់បានថាជាដំណើរការនៃ "ការងប់ងល់ផ្នែកបច្ចេកទេស"។ ដោយប្រើវិធីវិភាគរបស់ Rose (1999) និង Li (2006) ពួក "ជំនាញការ" ខាងធារាសាស្ត្រ បានព្យាយាមពុះបំបែកបញ្ហាស្មុគស្មាញខាងសង្គមនិងបរិស្ថាន ឲ្យទៅជាបញ្ហាបច្ចេកទេសតូចៗ

ជាមូលដ្ឋានវិញ ដូច្នេះដំណោះស្រាយខាងគោលនយោបាយក៏ច្រើនតែមានលក្ខណៈតូចចង្អៀត និងបច្ចេកទេសដូចគ្នាដែរ។ ប៉ុន្តែមានមតិទិតៀនជាច្រើនថា ដំណោះស្រាយផ្អែកបច្ចេកទេសទាំងនេះ អាចបង្កើតជាលាភសម្រាប់បុគ្គលដែលមានខ្សែរយៈទំនាក់ទំនងល្អ ប៉ុន្តែជារឿយៗ វាធ្វើឲ្យប្រជាជនភាគច្រើនកាន់តែយ៉ាប់យ៉ឺនថែមទៀត (Molle *et al.* 2009)។ ករណីនេះ ជាក់ស្តែងជាពិសេស សម្រាប់ប្រព័ន្ធធារាសាស្ត្រខ្នាតធំដែលគេកសាងឡើងដោយមិនមានការយល់ដឹងសមស្របពីជីវភាពសហគមន៍តូចៗដែលមានស្រាប់នៅទីនោះ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មនោគមវិជ្ជាបែបអភិវឌ្ឍន៍និយម (developmentalist) ដែលធ្លាប់មានជាទូទៅនោះ បានទទួលការទិតៀនយ៉ាងខ្លាំងពីអង្គការអន្តរជាតិ និងសំឡេងប្រជាជន (ជាឧទាហរណ៍ WCD 2000; Living River Siam 2010)។ គោលគំនិតបែបបុរាណ នៃការគ្រប់គ្រងធនធានទឹកតាមបែបវិស្វកម្ម និងផ្អែកលើអ្នកជំនាញការ កំពុងដួលរលំដោយសារគោលគំនិតនៃ "អភិបាលកិច្ចធនធានទឹក" ដ៏ធំទូលាយ និងផ្សារភ្ជាប់នឹងសង្គម (Mollinga 2008)។ ក្នុងន័យទូទៅ អភិបាលកិច្ចធនធានទឹកសំដៅលើ៖

> *ប្រព័ន្ធផ្សេងៗផ្នែកនយោបាយ សង្គម សេដ្ឋកិច្ច និងរដ្ឋបាល ដែលកំពុងប្រើប្រាស់ ដើម្បីត្រួតពិនិត្យលើការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក និងផ្តល់សេវាកម្មទឹកនៅតាមកម្រិតផ្សេងៗក្នុងសង្គម (GWP 2002)។*

ក្នុងន័យជាក់លាក់ជាងនេះទៀត គោលគំនិតនៃ "អភិបាលកិច្ចធនធានទឹក" បានទទួលស្គាល់ថា បច្ចេកវិទ្យាធារាសាស្ត្ររូបវ័ន្ត ត្រូវតែមានរួមផ្សំផងដែរដោយ ស្ថាប័នសង្គមនិងសេដ្ឋកិច្ចដ៏សមស្រប (Coward 1980; Ostrom 1999)។ តាមមធ្យោបាយផ្លូវការនិងមិនផ្លូវការ វិធីសាស្ត្ររួមបញ្ចូលគ្នានេះ ព្យាយាមសម្រេចលទ្ធផលធារាសាស្ត្រឲ្យកាន់តែមានប្រសិទ្ធភាព សមភាព និងនិរន្តរភាព។ លោក Elino Ostrom ដែលទទួលបានរង្វាន់ណូបែលផ្នែកសេដ្ឋកិច្ចឆ្នាំ២០០៩ បានលើកថា៖

> *សម្រាប់ប៉ុន្មានទសវត្សរ៍ទៅមុខនេះ បញ្ហាសំខាន់ជាងគេក្នុងការអភិវឌ្ឍធនធានទឹក គឺការរចនារៀបចំខាងស្ថាប័ន ជាជាងការរចនារៀបចំខាងវិស្វកម្ម (Ostrom 1999:74)។*

## ២.២ ការបកស្រាយពាក្យ "ការចូលរួម"

*អត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចធារាសាស្ត្រ*

អភិបាលកិច្ចធារាសាស្ត្រ គួរមានការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ និងនៅកម្រិតខុសៗគ្នាក្នុងសង្គម។ នៅក្នុងគោលការណ៍ដ៏ធំទូលាយនេះ នៅមានគំនិតដ៏ជាក់លាក់ជាច្រើនទៀត។ ដោយសំអាងលើការសិក្សារបស់ Arnstein (1969) អំពី "ចំណាត់ថ្នាក់នៃការចូលរួមរបស់ប្រជាជន" នោះ លោក Ribot (2000) បានវែកញែកថា ការសម្រេចចិត្តដ៏មានប្រសិទ្ធភាព ត្រូវមានការចែករំលែកអំណាចពិតៗ មិនមែនគ្រាន់តែជាការចូលរួមឲ្យល្អមើលចេញចូលៗនោះទេ។ យោងតាម Ostrom (1992) អ្នករៀបចំផែនការធារាសាស្ត្រគួរយកចិត្តទុកដាក់ជាពិសេសលើមតិរបស់ "សហគមន៍ទទួលផល" ដែលទទួលការប៉ះពាល់ខ្លាំងជាងគេ។ ដោយផ្តោតលើទិដ្ឋភាពពេលវេលា Calaguas and Francis (2004) បានសង្កត់ធ្ងន់ថា មតិយោបល់របស់សហគមន៍មានសារៈសំខាន់នៅគ្រប់ដំណាក់កាលនៃការរចនារៀបចំ ការសាងសង់ និងការថែទាំប្រព័ន្ធធារាសាស្ត្រ។ នៅក្នុងឯកសារស្រាវជ្រាវកន្លងមក បានបង្ហាញឲ្យឃើញកាន់តែច្រើនឡើងនូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយមានការប្រមែប្រមូលលំនាំគិតគូរផ្សេងៗនៃ "វិធីសាស្ត្រអភិវឌ្ឍន៍ដោយមានការចូលរួម"។

គោលគំនិតនៃការចូលរួមរបស់សហគមន៍ មានបង្កប់យូរយារមកហើយនៅក្នុង វិស័យមួយចំនួននៃឯកសារស្រាវជ្រាវស្តីពីការគ្រប់គ្រងធនធានទឹក (ឧទាហរណ៍ សូមមើលក្នុង Curran 1971; Coward 1976)។ ប៉ុន្តែទើបក្នុង ២០ឆ្នាំចុងក្រោយនេះទេ ដែល "វិធីសាស្ត្រអភិវឌ្ឍន៍ដោយមានការចូលរួម" បានជ្រាបចូលដល់មាគ៌ាអភិវឌ្ឍន៍ និង

ល្បីល្បាញឡើងឆ្លងតាមការជួបប្រជុំនិងកិច្ចព្រមព្រៀងអន្តរជាតិនានា។ សេចក្តីថ្លែងការណ៍ក្រុង Dublin ស្តីពីធនធានទឹក និងការអភិវឌ្ឍប្រកបដោយចីរភាព ("គោលការណ៍ Dublin") ដែលត្រៀមរៀបចំសម្រាប់ សន្និសីទកំពូលស្តីពីផែនដី (Earth Summit) នៅទីក្រុង Rio ឆ្នាំ១៩៩២ បានបញ្ជាក់ថា "ការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក គួរផ្អែកលើវិធីសាស្ត្រមានការចូលរួម ដោយគិតបញ្ចូលទាំងអ្នកប្រើប្រាស់ អ្នកធ្វើផែនការ និងអ្នកបង្កើតគោលនយោបាយនៅគ្រប់កម្រិត" (ICWE 1992: Principle 2)។ ក្នុងសន្និសីទកំពូលក្រុង Rio របៀបវារៈ២១ បានសង្កត់ធ្ងន់លើ តម្រូវការនូវ "ការចូលរួមជាសាធារណៈពេញលេញ គឺមានទាំង នារី យុវជន ជនជាតិភាគតិច និងសហគមន៍មូលដ្ឋាន" (UNCED 1992: Article 9, Chapter 18)។ រឹតតែសំខាន់ទៀត របៀបវារៈទី២១ បានភ្ជាប់ "ការចូលរួម" ទៅនឹងរបៀបវារៈផ្សេងទៀតនៃ "វិមជ្ឈការ" ដោយអំពាវនាវឲ្យ ការគ្រប់គ្រងធនធានទឹកធ្វើឡើងនៅកម្រិតសមស្របដ៏ទាបបំផុត (UNCED 1992: Article 12(o) (i), Chapter 18)។ សន្និសីទកំពូលពិភពលោកឆ្នាំ២០១២ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បានបញ្ជាក់ជាថ្មីពីខ្លឹមសារទាំងនេះ ក្នុងទម្រង់ជាបទបញ្ញត្តិ។ ផែនការអនុវត្តក្រុង Johannesburg (Johannesburg Plan of Implementation) បានអំពាវនាវឲ្យមានភាពជាដៃគូ និងការកសាងសមត្ថភាពសង្គមស៊ីវិល ដើម្បីញ៉ាំងឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធនៅគ្រប់កម្រិតនៃការគ្រប់គ្រងទឹក (WSSD 2002: Article 25)។

សេចក្តីថ្លែងការណ៍ទាំងនេះ មានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលគេបានទទួលយកជាទូទៅ។ IWRM ព្យាយាមគួបផ្សំការយល់ដឹងរបស់អ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកសម្រាប់បរិស្ថាន សង្គម និងសេដ្ឋកិច្ច (GWP-TAC 2000) ដែលពាក់ព័ន្ធគ្នា។ យោងតាមមតិក្រុមអ្នកគាំទ្រ IWRM គឺជា "របៀបរបបអនុវត្តល្អបំផុត" សម្រាប់គ្រប់វិស័យក្នុងការគ្រប់គ្រងធនធានទឹកនាពេលបច្ចុប្បន្ន (ឧទាហរណ៍ សូមមើល GWEP 2002: IWMI 2007)។ ប៉ុន្តែក្រុមអ្នករិះគន់ IWRM បានបង្ហាញថា ទោះបីមាន "ការវិនិយោគមូលធនច្រើនសម្បើម" ដើម្បីអនុវត្តគំនិតទាំងនេះក្តី ក៏លទ្ធផលតាមទ្រឹស្តី និងតាមភាពជាក់ស្តែង នៅឃ្លាតឆ្ងាយពីគ្នាជាខ្លាំង (Jonker 2002; Jeffrey & Gearey 2006)។ សូម្បីនៅក្នុងកម្មវិធីបរិស្ថានសហប្រជាជាតិក្តី ក៏គេបានកំណត់តាមហេតុជាក់ស្តែងថា IWRM នេះជា "ការងារមិនទាន់ចប់" ដែរ។ Jeffrey and Gearey (2006) បានបញ្ជាក់ទៀតថា "ភស្តុតាងជាក់ស្តែងដែលបង្ហាញច្បាស់ពីអត្ថប្រយោជន៍នៃ IWRM គឺពុំទាន់ឃើញមាន ឬក៏ពុំបានរាយការណ៍ល្អទេ"។

មតិរិះគន់ទាំងនេះ ផុសចេញពីបទពិសោធន៍ថ្មីៗនៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ជាពិសេសការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។ ជាលក្ខណៈផ្លូវការ រដ្ឋាភិបាលកណ្តាល បានទទួលយក ក្របខ័ណ្ឌ PIMD របស់ធនាគារ ADB ដើម្បីតម្រង់ទិសគម្រោងធារាសាស្ត្រទៅអនាគត។ ចំណុចគន្លឹះមួយនៃគោលនយោបាយនេះ គឺដំណើរការផ្ទេរការគ្រប់គ្រងធារាសាស្ត្រ (IMT) ដែលព្យាយាមផ្ទេរទំនួលខុសត្រូវប្រចាំថ្ងៃផ្នែកធារាសាស្ត្រ ពីស្ថាប័នរដ្ឋ ទៅឲ្យសហគមន៍មូលដ្ឋាន និងវិស័យឯកជន។ ប៉ុន្តែទោះបីមានចេតនាល្អដូច្នេះក្តី ក៏គោលគំនិតដូចជា ការអភិវឌ្ឍរួមគ្នា ភាពជាដៃគូរវាងរដ្ឋនិងឯកជន និងវិធីសាស្ត្រមានការចូលរួម មិនទាន់មានការយល់ដឹងល្អនៅកម្រិតសហគមន៍មូលដ្ឋានទេ (ឧទាហរណ៍ សូមមើល Sneddon & Fox 2007; Rusten *et al.* 2007)។ ការដាក់អនុវត្តគោលការណ៍អភិវឌ្ឍន៍ពហុវិស័យបែបបស្ចឹមប្រទេស នៅក្នុងសង្គមបែបបុរាណ និងមានឋានានុក្រមនៅកម្ពុជា ប្រហែលមិនគួរ ឬក៏ធ្វើមិនកើតទៀតផង។ សូម្បីនៅកម្រិតខ្ពស់បំផុតនៃអភិបាលកិច្ចផ្លូវការរបស់កម្ពុជា ក៏នៅតែពិបាកតាមដានពីទំនាក់ទំនងរវាងគោលគំនិត និងការអនុវត្តដែរ។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានអនុម័តចេញនៅឆ្នាំ២០០៧ ប៉ុន្តែតាមការសិក្សារបស់យើង ច្បាប់ដ៏សំខាន់នេះមិនទាន់មានឯកសារគាំទ្រជា គោលនយោបាយ ឬបទបញ្ញត្តិណែនាំការអនុវត្តនោះទេ។ ឯកសារពិភាក្សានេះ ព្យាយាមផ្តល់នូវទស្សនៈជាក់ស្តែងមួយ ស្តីពីបញ្ហាមិនទាន់ដោះស្រាយដូចរៀបរាប់ខាងលើ នៃអភិបាលកិច្ចធារាសាស្ត្រនៅកម្ពុជា ហើយតាមការស្រាវជ្រាវផ្អែកជាតិពន្ធុវិទ្យា បានសិក្សាស្វែងយល់ពីបែបបទដែលការចូលរួម បានដំណើរការនៅក្នុងសហគមន៍ជាក់ស្តែង៖ នៅក្នុងវាលស្រែ នៅការិយាល័យក្រុមប្រឹក្សាឃុំ (ក្រឃ) និងនៅក្នុងបន្ទប់ប្រជុំរបស់ សកបទ។

## ២.៣ អភិបាលកិច្ចធារាសាស្ត្រក្នុង "ទ្រង់ទ្រាយសមស្រប"?

*ការបង្កើតទ្រឹស្តីស្តីពីទំនាក់ទំនងរវាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័នសង្គម*

ចាប់តាំងពីបដិវត្តន៍បៃតងចូលមកដល់ ទេសភាពតំបន់កសិកម្មនៅអាស៊ីអាគ្នេយ៍ បានផ្លាស់ប្តូរដោយសារមានហេដ្ឋារចនាសម្ព័នធារាសាស្ត្រទំនើបៗ។ ក្នុងកិច្ចប្រឹងប្រែងសម្រេចគោលដៅ "អភិវឌ្ឍន៍ជនបទ" ដែលកំណត់ឡើងដោយរដ្ឋាភិបាលកណ្តាល ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីៗជាច្រើន ត្រូវបានកសាង និងដាក់ដំណើការនៅក្នុងសង្គមនិងវប្បធម៌នានាដែលមានលក្ខណៈបុរាណ។ តាំងពីកោះបាលី មកដល់ប្រទេសឡាវ និងកម្ពុជា ប្រព័ន្ធធារាសាស្ត្រថ្មីៗដែលមានលក្ខណៈបច្ចេកទេសខ្ពស់ បានអនុញ្ញាតឲ្យអ្នកជំនាញការ និងស្ថាប័នផ្សេងៗមកពីស្រុកក្រៅ មានតួនាទីកាន់តែច្រើនក្នុងអភិបាលកិច្ចធារាសាស្ត្រនៅតាមមូលដ្ឋាន។ ក្នុងពេលជាមួយគ្នានេះ ស្ថាប័នគ្រប់គ្រងធនធានទឹកក្នុងស្រុក ជារឿយៗត្រូវបានគេផាត់ចេញ ឬបំភ្លេចចោល បើសិនមិនស៊ីគ្នានឹងទំហំ និងរបៀបរៀបចំនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តថ្មី។

ពីមួយឆ្នាំទៅមួយឆ្នាំ គោលគំនិតអភិវឌ្ឍន៍នៃការបន្សុីគ្នារវាងប្រព័ន្ធធារាសាស្ត្ររូបវ័ន្តទំនើប ជាមួយនឹងអភិបាលកិច្ចបែបទំនើបដែលដឹកនាំដោយអ្នកជំនាញការ គឺបានជួបបញ្ហាដោយសារមានភស្តុតាងផ្ទុយកាន់តែច្រើនឡើង។ Coward (1976) បានរិះគន់មុនគេ ដោយផ្អែកលើការសិក្សារបស់គាត់ពីតំបន់ធារាសាស្ត្រទំនើបថ្មីមួយឈ្មោះ Nam Tan នៅភាគខាងលិចប្រទេសឡាវ។ Coward បានសន្និដ្ឋានថា ប្រពៃណីគ្រប់គ្រងធនធានទឹកពីមុននៅតំបន់នោះ មិនបានរារាំងដំណើរការទំនើបកម្មទេ។ ជាក់ស្តែងទៅ ការរក្សានិងការទទួលយកប្រពៃណីទាំងនេះ បានរួមចំណែកយ៉ាងខ្លាំងដល់ជោគជ័យនៃប្រព័ន្ធធារាសាស្ត្រថ្មីៗ។ តួនាទីរបស់អ្នកដឹកនាំជាប្រពៃណី (ដូចជា អ្នកគ្រប់គ្រងធនធានទឹកក្នុងភូមិ) គេបានកែសម្រួលឲ្យក្លាយជា អភិបាលកិច្ច "ថ្នាក់កណ្តាល" ដ៏សំខាន់ដែលតភ្ជាប់ប្រសិទ្ធភាពការិយាធិបតេយ្យទឹកក្នុងតំបន់ ជាមួយនឹងបណ្តាញសង្គម និងចំណងផ្សារភ្ជាប់ផ្នែកវប្បធម៌នៃអ្នកប្រើប្រាស់ទឹកក្នុងតំបន់។

រចនាសម្ព័ន្ធបែបកូនកាត់នៃអភិបាលកិច្ចធារាសាស្ត្រទំនើប និងបុរាណនេះ មានលក្ខណៈស្រដៀងគ្នានឹងប្រព័ន្ធសកបទ នៅកម្ពុជា។ MOWRAM និង លក្ខន្តិកៈ សកបទ ជាតិ បានកំណត់ថា សកបទ ត្រូវបំពេញមុខងារជា អង្គការសហគមន៍ឯករាជ្យ ដែលអ្នកដឹកនាំមានទំនួលខុសត្រូវធ្វើទំនាក់ទំនងជាមួយមន្ត្រីជាន់ខ្ពស់ ប៉ុន្តែមានគណនេយ្យភាពចម្បងចំពោះអ្នកប្រើប្រាស់ទឹកនៅមូលដ្ឋាន។ ក្នុងការអនុវត្តជាក់ស្តែង អ្នកដឹកនាំ សកបទ អាចខ្វះខាតជំនាញ និងការលើកទឹកចិត្ត ដើម្បីធ្វើការប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀត គណៈកម្មការ សកបទ អាចត្រូវព្យាយាមអនុវត្តការងារដោយប្រុងប្រយ័ត្នកុំឲ្យប៉ះពាល់ដល់ចំណងភក្តីភាព និងរចនាសម្ព័ន្ធអំណាចដែលមានស្រាប់ ទាំងចំពោះថ្នាក់លើនិងថ្នាក់ក្រោមខ្លួន នៅក្នុងឋានានុក្រមអភិបាលកិច្ចធនធានទឹក។ ការបញ្ជាក់នៅខាងលើមានលក្ខណៈជាការប៉ាន់ស្មាន ហើយឯកសារមានស្រាប់នាពេលបច្ចុប្បន្ន ផ្តល់ភស្តុតាងតិចតួចណាស់សម្រាប់បញ្ជាក់គាំទ្រ ឬច្រានចោលបញ្ហាទាំងនេះ។ ឯកសារពិភាក្សានេះ មានបំណងផ្តល់មូលដ្ឋានជាក់ស្តែងគួរឲ្យទុកចិត្តជាងមុនមួយ សម្រាប់ការពិភាក្សា និងដោះស្រាយបញ្ហាសំខាន់ៗ នៅក្នុងរបបអភិបាលកិច្ចធារាសាស្ត្រកម្ពុជា។

ផ្ទុយពីការសិក្សារបស់ Coward នៅប្រទេសឡាវ ការសិក្សារបស់ Lansing (1987) អំពីធារាសាស្ត្រ "ប្រាសាទទឹក" (water temple) បុរាណនៅកោះបាលី បានបង្ហាញពីឧទាហរណ៍ដ៏ល្អនិងស្រស់បំព្រងមួយនៃអភិបាលកិច្ចធារាសាស្ត្រ។ ឆ្លងតាមការអភិវឌ្ឍកសិកម្មសរីរាង្គក្នុងពេលជាច្រើនរយឆ្នាំកន្លងមកនេះ (មុនពេលបដិវត្តន៍បៃតងនៅទសវត្សរ៍១៩៦០) ស្ថាប័នអភិបាលកិច្ចទឹក (subaks) ដែលចាក់ឫសជាប់ក្នុងវប្បធម៌កោះបាលី បានក្លាយជាមានលក្ខណៈស៊ីគ្នាយ៉ាងល្អទៅនឹងទិដ្ឋភាពរូបវ័ន្តនៃប្រព័ន្ធធារាសាស្ត្រក្នុងកោះ។ ទំនាក់ទំនងនេះអាចជួយពង្រឹងគ្នាទៅវិញទៅមកផង តួយ៉ាង គេបានប្រើប្រាស់ពិធីបុណ្យសាសនា ដើម្បីកែតម្រូវជាសាធារណៈនូវប្រព័ន្ធប្រតិទិនពីរដ៏ស្មុគស្មាញរបស់កោះបាលី ជួយឲ្យកសិករអាចតម្រឹមពេលគ្នាបានយ៉ាងល្អសម្រាប់តម្រូវការទឹកស្រោចស្រពរបស់ខ្លួន (Lansing 1987: 330-332)។ គេអាចវិភាគផ្ទុយពីនេះដែរថា លំហូរទឹករូបវន្ត តំណាងឲ្យមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៃ វប្បធម៌ និងសាសនានៅកោះ

បាលី។ Lansing បង្ហាញថា ចំណងទាក់ទងតាមទិដ្ឋភាពច្រើនបែបយ៉ាងទាំងនេះ បានញាំងឲ្យមានការសម្របសម្រួល និងការដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាព ដោយមិនចាំបាច់មាន "លទ្ធិផ្តាច់ការបែបបូព៌ាប្រទេស" ដូចដែល Wittfogel (1957) បានលើកឡើងនោះទេ។ ផ្អែកលើការសិក្សារបស់ Janssen (2007: 188) លោក Lansing និង Kremer (1993) បានបង្ហាញថា "អន្តរកម្មពីក្រោមទៅលើដ៏សាមញ្ញនៃ subaks អាចនាំឲ្យប្រព័ន្ធធារាសាស្ត្រខ្នាតធំដ៏ស្មុគស្មាញមួយដំណើរការបានល្អ"។

បើពិនិត្យគ្រួសៗ ការរៀបរាប់របស់ Lansing ស្តីពីធារាសាស្ត្របែបបុរាណនៅកោះបាលី ហាក់ដូចខុសគ្នាឆ្ងាយពីស្ថានភាពនៅកម្ពុជានាបច្ចុប្បន្ន។ បើធៀបនឹងប្រព័ន្ធកសិ-អេកូឡូស៊ីបុរាណ និងចីរភាពផ្នែកសង្គមវប្បធម៌របស់កោះបាលីនោះ ស្ថាប័នអភិបាលកិច្ចធារាសាស្ត្ររបស់កម្ពុជា អាចចាត់ទុកថា នៅមានលក្ខណៈថ្មីថ្មោង និងមានអស្ថិរភាពខ្លាំង។ ការវែកញែកនេះក៏មានភាពពិតជាក់ស្តែងផងដែរ៖ ប្រវត្តិសាស្ត្រយ៉ាងវែងនៃការរឹករវផ្នែកនយោបាយនៅកម្ពុជា និងចំណាកស្រុកក្នុងប្រទេស (ជាពិសេសក្នុងសម័យខ្មែរក្រហម) បានធ្វើឲ្យកត្តារូបវន្ត និងកត្តាសង្គមវប្បធម៌របស់កម្ពុជា មិនអាចគួបកម្លាំងគ្នារីកលូតលាស់ទៅបាន ហើយករណីកោះបាលីនេះក៏អាចមានតែមួយវិសេសលើសគេដែរ។ ប៉ុន្តែការវែកញែកនេះគួរតែប្រើប្រាស់ការពិចារណាដោយប្រុងប្រយ័ត្ន។ ទោះបីមានអំឡុងពេលរឹករវពិតមែនក្តី ក៏អ្នកបង្កើតគោលនយោបាយ មិនគួរសន្មតថា កម្ពុជាគ្មានការជិតដាមអ្វីសោះ ខាងផ្នែករចនាសម្ព័ន្ធធារាសាស្ត្រ និងអភិបាលកិច្ចធារាសាស្ត្រនោះដែរ។ ការពិនិត្យអង្កេតពីលើអាកាសនិងភស្តុតាងខាងបុរាណវត្ថុវិទ្យា បានបង្ហាញថា ប្រជាជនកម្ពុជាបានអនុវត្តកសិកម្មធារាសាស្ត្រខ្នាតធំតាំងពីមួយសហស្សវត្សរ៍មុនម្ល៉េះ ជាពិសេសក្នុងសម័យអង្គរ(ឧទាហរណ៍សូមមើល Moore 1989)។ តាំងពីសតវត្សរ៍ទី១១ ម្ល៉េះ បារាយខាងលិចដ៏ធំសម្បើមដល់ទៅ ៨គ.ម x ២គ.ម គឺជាឧទាហរណ៍ជាក់ស្តែងនៃរចនាសម្ព័ន្ធធារាសាស្ត្រក្នុងសម័យអង្គរ ដែលនៅតែប្រើការបានរហូតមកទល់សព្វថ្ងៃ។ សរុបមក ទោះបីជាប្រវត្តិនៃការគ្រប់គ្រងទឹកនៅកម្ពុជា មិនបាននឹងនរ និងមានកំណត់ត្រាល្អ ដូចនៅកោះបាលីក៏ពិតមែន ប៉ុន្តែបានផ្តល់ជាបទពិសោធន៍ដ៏សំខាន់មួយសម្រាប់អភិបាលកិច្ចធារាសាស្ត្រសម័យទំនើប។

## ២.៤ ការខ្សត់ទឹក និងថ្លៃសេវាកម្មធារាសាស្ត្រ

*តាមការប្រៀបធៀបក្នុងបរិបទខុសៗគ្នា តើ "ចំណាយលើទឹក" មានន័យយ៉ាងដូចម្តេច?*

ក្នុងប្រទេសអភិវឌ្ឍន៍ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ កសិករនៅទសវត្សរ៍ទី២១ ភាគច្រើន រំពឹងថា ត្រូវតែបង់ថ្លៃសេវាកម្មដើម្បីអាចប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ ទោះបីជារដ្ឋចេញបានថ្លៃសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្តី ក៏ថ្លៃដំណើរការ និងការថែទាំ (O&M) ត្រូវធ្លាក់ទៅលើសហគមន៍មូលដ្ឋាន និងអ្នកម៉ៅការឯកជនដែលទទួលកិច្ចសន្យាឲ្យគ្រប់គ្រងការងារ (Molle *et al.* Wster 2009: 341-342)។ ដំណើរការវិវត្តន៍នេះ បានកើតឡើងក្នុងបរិបទនៃនិន្នាការពីរ (ដែលអាចជាប់ទាក់ទងគ្នា)៖ ការរួមចំណែកចវិការរដ្ឋាភិបាលកណ្តាលក្នុងសម័យសេរីនិយមបែបថ្មី (neoliberal era) និង របៀបវារៈទី២១ នៃការលើកកម្ពស់វិមជ្ឈការ និងគោលការណ៍ "subsidiarity"[៣] ។

នៅប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក គេចាត់ទុកទឹកជាធនធានកម្រដែលមានតម្លៃខាងសេដ្ឋកិច្ច ហើយកសិករត្រូវបង់ថ្លៃផ្អែកលើទីផ្សារសម្រាប់ការចែកចាយទឹក និងការទទួលបានសិទ្ធិប្រើប្រាស់។ ផ្ទុយទៅវិញ នៅកម្ពុជាប្រជាជនកម្រមើលឃើញថា ទឹកក៏ជាធនធានដ៏ខ្សត់ណាស់ក្នុងភាពជាក់ស្តែង។ ទោះយ៉ាងនេះក្តី សារៈសំខាន់ខាងសេដ្ឋកិច្ចនៃទឹក ត្រូវតែពិចារណាឲ្យបានម៉ត់ចត់។ គោលនយោបាយ PIMD ថ្មី បានណែនាំពីវិធានថ្មីមួយសម្រាប់ឲ្យកសិករកម្ពុជាបង់ថ្លៃសេវាកម្មធារាសាស្ត្រ (ISF) ទៅឲ្យគណៈកម្មការ សកបទ ក្នុងតំបន់របស់ខ្លួន។ ISF នៅកម្ពុជា និងថ្លៃទឹកនៅប្រទេសអូស្ត្រាលី ផ្អែកលើស្ថានភាពសេដ្ឋកិច្ចខុសគ្នាទាំងស្រុង។ អាងទឹក Murray Darling

---

[៣] គោលការណ៍ដែលអនុញ្ញាតឲ្យមានការសម្រេចចិត្តជាលក្ខណៈបុគ្គល លើបញ្ហាដែលប៉ះពាល់ដល់ពួកគេ ដោយមិនចាំបាច់រង់ចាំការសម្រេចចិត្តដោយសមាជិកក្រុមទាំងមូល។

នៅប្រទេសអូស្ត្រាលី មានហេដ្ឋារចនាសម្ព័ន្ធល្អតែខ្វះទឹក។ អាងទឹកនេះជួបបញ្ហាខ្សត់ទឹករូបវ័ន្ត ដូចមានបង្ហាញក្នុងការសិក្សារបស់ Molden (2007)។ ដើម្បីគ្រប់គ្រងលើភាពខ្សត់នេះ គេយកថ្លៃទឹកមកប្រើដើម្បីបែងចែកទឹក៖ កសិករនៅក្នុងតំបន់ត្រូវតែបង់ថ្លៃដើម្បីប្រើប្រាស់ទឹក (ឧទាហរណ៍ ថ្លៃទឹកគិតក្នុងមួយមេហ្គាលីត្រ)។ ចំណែកឯ ISF នៅកម្ពុជាវិញ គេបង្កើតឡើងសម្រាប់ដោះស្រាយបញ្ហាមួយផ្សេង ពោលគឺ "ភាពកម្រខាងសេដ្ឋកិច្ច"។ ប្រទេសកម្ពុជាសំបូរទឹក ប៉ុន្តែមានហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ។ ទោះជាសំបូរទឹក ក៏កសិករកម្ពុជាមិនមានមធ្យោបាយដើម្បីទាញយកទឹកនោះមកប្រើឲ្យមានផលិតភាពដែរ។ ដូច្នេះ ISF គឺសម្រាប់កែលំអនិងថែទាំហេដ្ឋារចនាសម្ព័ន្ធទឹក ព្រមទាំងដោះស្រាយចំណាយប្រតិបត្តិការរបស់ សកបទ។ ថ្លៃប្រើប្រាស់ទឹកនេះ មិនជាប់ទាក់ទងនឹងបរិមាណទឹកប្រើប្រាស់ជាក់ស្តែងនោះទេ។

ភាពខុសគ្នារវាងភាពកម្រខាង "សេដ្ឋកិច្ច" និង "រូបវ័ន្ត" វាផ្អែកលើភាពសមហេតុផលផ្នែកសេដ្ឋកិច្ច ហើយមានការយល់ស្របច្រើនក្នុងរង្វង់អ្នកធ្វើគោលនយោបាយ និងអ្នកសិក្សា។ ទោះជាយ៉ាងនេះក្តី នៅពេលអនុវត្តក្នុងស្ថានភាពមូលដ្ឋានដ៏ស្មុគស្មាញ ភាពខុសគ្នានេះហាក់រលុបបាត់អស់ជាច្រើនដោយសារហេតុផលច្រើនមួយចំនួន។ទី១ដោយសារចន្លោះខ្វះខាតផ្នែកទំនាក់ទំនង ប្រជាជនមូលដ្ឋានអាចមិនបានយល់ពីគោលបំណងនៃថ្លៃសេវាប្រើប្រាស់ទឹក។ តួយ៉ាង ISF តែងបកប្រែជាភាសាខ្មែរថា "ថ្លៃទឹក" ជាជាង "ថ្លៃសេវាកម្មធារាសាស្ត្រ" ដូច្នេះ តើកសិករកម្ពុជាបានដឹងច្បាស់ទេថាពួកគាត់កំពុងតែបង់ថ្លៃអ្វី? ហើយ តើការយល់ដឹងនេះជះឥទ្ធិពលយ៉ាងណាទៅលើឆន្ទៈក្នុងការបង់ប្រាក់របស់ពួកគាត់? ទី២ គំនិតជាទូទៅនៃ "ភាពកម្រផ្នែកសេដ្ឋកិច្ច" នៅកម្រិតអាងស្ទឹង អាចបាំងបាត់នូវ ភាពកម្រនៃធារាសាស្ត្ររូបវ័ន្តធ្ងន់ធ្ងរនៅតាមភូមិ និងតាមក្បាលដី។ នៅកម្ពុជា ករណីនេះអាចកើតមានឡើងនៅពេលដែលកសិករនៅខ្សែទឹកខាងលើគាត់បិទប្រឡាយស្រោចស្រព ហើយទប់ទឹកមិនឲ្យហូរធ្លាក់ដល់កសិករនៅខ្សែទឹកខាងក្រោម។ ម៉្យាងវិញទៀត ភាពកម្រផ្នែករូបវ័ន្តនៅរដូវប្រាំង ជាបញ្ហាមួយដែលកំពុងរីកធំ ពីព្រោះការធ្វើស្រែពីរដងក្នុងមួយឆ្នាំ ត្រូវពឹងផ្អែកជារឿយៗទៅលើប្រព័ន្ធធារាសាស្ត្រដែលគេកសាងឡើងសម្រាប់តែផ្តល់ទឹកបន្ថែមនៅរដូវវស្សាប៉ុណ្ណោះ។

# ៣ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ បានប្រើវិធីជាច្រើនដើម្បីប្រមូលទិន្នន័យ ចាប់ពីថ្ងៃទី ១៣ កក្កដា ដល់ ១៨ កញ្ញា ២០១០ នៅក្នុងប្រព័ន្ធធារាសាស្ត្រជាគោលដៅបី (រូបភាព ១)។ ការសម្ភាសជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ និងនៅថ្នាក់មូលដ្ឋាន បានធ្វើឡើង ដើម្បីប្រមូលមតិយោបល់លើបញ្ហាការគ្រប់គ្រងទឹកនៅជនបទ។ ការពិភាក្សាតាមក្រុមស្នូល (FGDs) ការសម្ភាសកសិករ និងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ នៅខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់ បានធ្វើឡើង ដើម្បីស្រង់ព័ត៌មានពីការយល់ឃើញរបស់អ្នកពាក់ព័ន្ធសំខាន់ៗអំពីតួនាទីរបស់ខ្លួន និងអំពីការរំពឹងទុកលើលទ្ធផលនៃការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងដើម្បីសិក្សាពីបទពិសោធន៍ការងាររបស់ពួកគេនៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចធនធានទឹកនៅកម្ពុជា។ តាមរយៈវិធីសាស្ត្រទាំងនេះ ការសិក្សាក៏ព្យាយាមកំណត់ពីកម្រិតនៃភាពស៊ីគ្នានៃការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាលើទិដ្ឋភាពសំខាន់ៗនៃអភិបាលកិច្ចធនធានទឹក។

រូបភាព ១៖ ផែនទីនៃប្រព័ន្ធធារាសាស្ត្រដែលបានសិក្សា



### ៣.១ ការជ្រើសរើសទីតាំង និងការគូរផែនទី

ប្រព័ន្ធធារាសាស្ត្របីកន្លែង ត្រូវបានជ្រើសរើសឡើងសម្រាប់ការសិក្សា គឺមាន ប្រព័ន្ធរលួស និងប្រព័ន្ធស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ និងប្រព័ន្ធដំណាក់អំពិល ក្នុងខេត្តពោធិ៍សាត់។ តំបន់សិក្សាទាំងនោះត្រូវបានជ្រើសរើសឡើងយ៉ាងម៉ត់ចត់ ដើម្បីតំណាងឲ្យគម្រោងផ្សេងៗទៀតនៅជុំវិញបឹងទន្លេសាប។ កាសិក្សាបានផ្តោតលើៈ កម្រិតនៃការចូលរួម និងការសម្របសម្រួលលើ ISF និង O&M នៅក្នុងប្រព័ន្ធ ការអភិវឌ្ឍនិងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនៃប្រព័ន្ធ រចនាសម្ព័ន្ធគ្រប់គ្រង សកបទ ការចូលរួមរបស់វិស័យឯកជន[៤] ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធារាសាស្ត្រ និងការគ្រប់គ្រងទំនាស់លើការប្រើប្រាស់ទឹកក្នុងអំឡុងពេលខ្វះទឹក។

### ៣.២ សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ

អ្នកផ្តល់ព័ត៌មានគន្លឹះ (KI) នៅកម្រិតខេត្ត និងមូលដ្ឋាន ដែលមកពី PDOWRAM និងក្រុមហ៊ុនឯកជន ក៏ដូចជាកសិករ សមាជិកគណៈកម្មការ សកបទ និងសមាជិក ក្រយ ត្រូវបានកំណត់សម្រាប់ការធ្វើសម្ភាសន៍ និងពិភាក្សាដោយប្រើសំណួរណែនាំផ្សេងៗ។ សំណួរទាំងនេះបានបង្កើតឡើងដោយផ្អែកលើតួនាទីជាក់លាក់ ការរំពឹងទុក និងបទពិសោធន៍របស់អង្គការនានាដែលធ្វើការក្នុងវិស័យទឹក និងកសិកម្ម។ បទសម្ភាសន៍មានគោលដៅ ស្វែងរកព័ត៌មានលើបញ្ហាពាក់ព័ន្ធនឹងទឹក។

ក្រុមស្រាវជ្រាវបានជួបជាមួយ PDOWRAM និង គណៈកម្មការ សកបទ ដើម្បីពិភាក្សាពីការគ្រប់គ្រងទឹកជាទូទៅនៅក្នុងប្រព័ន្ធជាករណីសិក្សានីមួយៗ។ ចំណុចបានពិភាក្សារួមមានៈ

១. ការបង្កើត សកបទ

២. ការស្តារជួសជុលប្រព័ន្ធធារាសាស្ត្រឡើងវិញ

៣. ការធ្វើផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធារាសាស្ត្រសម្រាប់ដោះស្រាយបញ្ហាទឹក (IWRM, IMT, PIMD, ISF, O&M)

៤. ការបែងចែក និងគ្រប់គ្រងទឹក និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ នៅក្នុងប្រព័ន្ធនីមួយៗ (ឧទាហរណ៍ ប្រឡាយមេ ប្រឡាយរងទី២ ប្រឡាយរងទី៣)

៥. ទំនាក់ទំនង និងការសម្របសម្រួលរវាងគណៈកម្មការ សកបទ និង ក្រយ ក្នុងប្រព័ន្ធដែលគ្រប់គ្រងដោយច្រើនឃុំ

### ៣.៣ ការពិភាក្សាតាមក្រុមស្នូលជាមួយកសិករ និងមេភូមិ

ព័ត៌មានក៏ប្រមូលបានផងដែរតាមរយៈ FGD។ ក្រុមកសិករត្រូវបានជ្រើសរើសឡើងដោយផ្អែកលើ ទីតាំងភូមិសាស្ត្រនៅខាងលើ និងខាងក្រោមខ្សែទឹក ការសម្របសម្រួលមានតិចតួច និងទំនាស់កើតមានជាប្រចាំក្នុងអំឡុងពេលខ្វះទឹក។ ក្នុងប្រព័ន្ធនីមួយៗ បានដំណើរការ FGD ចំនួនពីរលើក ។ FGD ទី១ រួមមាន សកបទ និងថ្នាក់ដឹកនាំភូមិ ហើយផ្តោតលើព័ត៌មានទូទៅ ដូចជា ប្រភេទ ទំហំ លក្ខខណ្ឌរូបវ័ន្តនិងភូមិសាស្ត្រនៃប្រព័ន្ធធារាស្ត្រ ប្រព័ន្ធប្រឡាយ ការចែកចាយទឹក ការសម្របសម្រួល និងការគ្រប់គ្រងទំនាស់ ជាដើម។ FGD ទី២ មានការចូលរួមពីគណៈកម្មការ សកបទ និងបើកទូលាយផងដែរដល់កសិករដែលមិនមែនជាសមាជិក សកបទ និងដែលមានជីវភាពពឹងផ្អែកលើកសិកម្ម (ក្នុងករណីភាគច្រើនគឺ ការធ្វើស្រែប្រាំង និង/ឬ ស្រែវស្សា)។ FGD ទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យ និងព័ត៌មានទូទៅអំពីរដ្ឋបាលមូលដ្ឋាន និងបញ្ហាសង្គមផ្សេងៗ ជាពិសេសទាក់ទងនឹងសកម្មភាពកសិកម្ម ការបង្កើត

---

[៤] ការអនុវត្តឲ្យវិស័យឯកជនចូលរួមក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍នៅភាគខាងលិចនៃប្រព័ន្ធរលួស ក្នុងខេត្តកំពង់ធំ (មើលផែនទីក្នុងផ្នែកលទ្ធផលស្រាវជ្រាវ) ទើបតែចាប់ផ្តើមក្នុងខែសីហា ២០១០។

ប្រាក់ចំណូល និងការលើកកម្ពស់ជីវភាព ក៏ដូចជា ដើម្បីផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធនានា អំពីបញ្ហាទាក់ទងនឹងទឹក (ការស្តារនិងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងការបង្កើត សកបទ)។

## ៣.៤ ការធ្វើសម្ភាសន៍កសិករ និងការសង្កេតដល់កន្លែង

សម្ភាសន៍កសិករ បានអនុវត្តឡើងបន្ទាប់ពី FGD ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យនិងព័ត៌មាន ដែលប្រមូលបានពី FGD។ អ្នកតំណាងមកពី ១២ ទៅ ២៥គ្រួសារ ត្រូវបានជ្រើសរើសសម្រាប់ធ្វើសម្ភាសន៍នៅក្នុងប្រព័ន្ធកំពុងសិក្សានីមួយៗ ដោយត្រូវមានលក្ខណៈតំណាងឲ្យគ្រួសារនានានៅក្នុងតំបន់ទីតាំងភូមិសាស្ត្រផ្សេងៗនៃប្រព័ន្ធនោះ ពោលគឺ ក្រុមទី១ មកពីប្រព័ន្ធធារាសាស្ត្រនៅខ្សែទឹកខាងក្រោម ក្រុមទី២ មកពីប្រព័ន្ធនៅកណ្តាល និង ក្រុមទី៣ មកពីប្រព័ន្ធនៅខ្សែទឹកខាងលើ។ សម្ភាសន៍ជាមួយកសិករបានធ្វើឡើងជាលក្ខណៈឯកជន ដើម្បីទទួលបានចម្លើយដែលមិនរងសម្ពាធពីវត្តមាននៃគណៈកម្មការ សកបទ។ ជារឿយៗ សម្ភាសន៍បានធ្វើឡើងនៅឯដីស្រែរបស់អ្នកឆ្លើយសម្ភាសន៍ផ្ទាល់ ដើម្បីឲ្យក្រុមអង្កេតអាចធ្វើការសង្កេតពិនិត្យដោយផ្ទាល់ផងដែរ។ បទសម្ភាសន៍ រួមមាន សំណួរជាទូទៅអំពីការប្រើប្រាស់ធនធានទឹកសម្រាប់កសិកម្ម ការបែងចែកទឹក ការចូលរួមរបស់កសិករ និងការយល់ដឹងពីបញ្ហា ISF និង O&M ទាក់ទងនឹងការប្រើប្រាស់ទឹក ក៏ដូចជា ដំណោះស្រាយជាក់ស្តែងនៅមូលដ្ឋាន និងយន្តការដោះស្រាយទំនាស់។ សំណួរមួយចំនួនដែលបានលើកឡើងនៅក្នុង FGD ក៏អាចលើកមកសួរកសិករម្តងទៀតក្នុងពេលធ្វើសម្ភាសន៍ដែរ ដើម្បីផ្ទៀងផ្ទាត់លើចម្លើយកាលពីមុន។ បញ្ជីសំណួរសម្រាប់កសិករ បានយកមកប្រើដោយមានភាពបត់បែនខ្លះ ពោលគឺ ចម្លើយបានមកពីសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ និង FGD លើកទី១ អាចយកមកប្រើដើម្បីតម្រង់ទិសសម្ភាសន៍ជាមួយកសិករបាន ទៅតាមការចាំបាច់។

ការសង្កេតពិនិត្យដល់កន្លែង បានធ្វើឡើងក្នុងពេលព្រមគ្នានឹងសម្ភាសន៍ជាមួយកសិករ ដើម្បីមានគំនិតកាន់តែច្បាស់ពីការគ្រប់គ្រងធារាសាស្ត្រសព្វថ្ងៃ របៀបរបបបែងចែកទឹក រចនាសម្ព័ន្ធរូបវន្តនៃប្រព័ន្ធធារាសាស្ត្រ និងបញ្ហាផ្សេងៗទៀតទាក់ទងនឹងទឹក។ សំខាន់ជាងនេះទៀត ការសង្កេតពិនិត្យពីទីតាំងវាលស្រែរបស់អ្នកឆ្លើយសម្ភាសន៍នៅក្នុងប្រព័ន្ធធារាសាស្ត្រ វាផ្តល់នូវបរិបទនៃចម្លើយ និងការយល់ឃើញរបស់ពួកគេលើបញ្ហាផ្សេងៗ។ ការសង្កេតដល់កន្លែង ផ្តល់ឱកាសឲ្យក្រុមអង្កេតអាចវាយតម្លៃ និងប្រមូលទិន្នន័យនិងព័ត៌មានបានកាន់តែច្រើន និងបានឃើញផ្ទាល់ពីបែបបទ និងកន្លែងដែលបញ្ហាទាក់ទងនឹងទឹកបានកើតមានឡើងនៅក្នុងស្ថានភាពភូមិសាស្ត្រជាក់លាក់ណាមួយ។ ក្នុងពេលពិភាក្សា ផែនទីដែលបង្កើតឡើងដោយក្រុមស្រាវជ្រាវ ត្រូវបានយកមកប្រើជាឧបករណ៍ជំនួយសម្រាប់ឲ្យកសិករចង្អុលបង្ហាញទីតាំងច្បាស់លាស់នៃបញ្ហាចោទធំៗ និងទីតាំងដែលអាចជាដំណោះស្រាយខាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាកន្លែងអាចកសាងប្រព័ន្ធប្រឡាយ ដើម្បីដោះស្រាយបញ្ហាខ្វះទឹក ឬដើម្បីកែលំអការគ្រប់គ្រង និងបែងចែកទឹកក្នុងតំបន់។

## ៣.៥ សិក្ខាសាលាថ្នាក់ខេត្ត

សិក្ខាសាលាថ្នាក់ខេត្តជាច្រើន ត្រូវបានធ្វើឡើងក្នុងខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ ដើម្បីប្រមូលទិន្នន័យ និងព័ត៌មាន និងស្វែងរកមតិយោបល់បន្ថែម ដែលអាចជួយកែលំអការគ្រប់គ្រងទឹក និងបង្កើនផលិតកម្មកសិកម្ម។ សិក្ខាសាលាបានផ្តល់ឱកាសមួយយ៉ាងល្អសម្រាប់ឲ្យអ្នកពាក់ព័ន្ធនានាពិភាក្សាពី៖

១. ចក្ខុវិស័យរួមគ្នាមួយ

២. យុទ្ធសាស្ត្រកែលំអប្រព័ន្ធធារាសាស្ត្រ

៣. បញ្ហាសំខាន់ៗ និងដំណោះស្រាយផ្សេងៗ

៤. ទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានាក្នុងការគ្រប់គ្រងធារាសាស្ត្រ

៥. ការផ្តល់មតិពីវិធីសាស្ត្រសំខាន់ៗដែលក្រុមស្រាវជ្រាវត្រូវកំណត់ឡើង ដើម្បីចូលរួមប្រកបដោយផ្លែផ្កាក្នុងការកសាងគោលការណ៍ណែនាំសម្រាប់ការបែងចែកទឹក និងរបៀបរបបអនុវត្តល្អៗបំផុតដើម្បីកែលំអការគ្រប់គ្រងធារាសាស្ត្រ និងអភិបាលកិច្ចទឹកនៅថ្នាក់មូលដ្ឋាន។

## ៣.៦ ការផ្ទៀងផ្ទាត់បញ្ជាក់ទិន្នន័យ

ទិន្នន័យបានពីការសិក្សាមានស្រាប់ ការសម្ភាសជាមួយកសិករ និងអ្នកផ្តល់ព័ត៌មានគន្លឹះ FGD និងសិក្ខាសាលានានា ត្រូវបានយកមកផ្ទៀងផ្ទាត់ (តាមការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ) និងចងក្រងបញ្ចូលគ្នា។ វិធីសាស្ត្រផ្ទៀងផ្ទាត់ "Triangulation" នេះ ធានាឲ្យទិន្នន័យកាន់តែច្បាស់លាស់គួរទុកចិត្ត ហើយការវិភាគទិន្នន័យកាន់តែគួរឲ្យជឿជាក់។

ការវិភាគទិន្នន័យស៊ីជម្រៅ បានអនុវត្តឡើងដើម្បី៖ ១) កំណត់ឫសគល់នៃបញ្ហាទឹក និងគម្លាត ឬភាពមិនស៊ីគ្នារវាងគោលនយោបាយ និងការអនុវត្តរបស់កសិករ និងស្វែងរកដំណោះស្រាយសមស្របពីអ្នកពាក់ព័ន្ធ ២) យល់ដឹងច្បាស់ពីលក្ខខណ្ឌជាក់លាក់នៅកម្ពុជា ដែលអាចជួយដល់គំនិតផ្តួចផ្តើមអភិបាលកិច្ច ដូចជា PIMD និង IMT និងជួយឲ្យសកបទ ធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និង ៣) ជួយដល់អ្នកធ្វើគោលនយោបាយសាធារណៈក្នុងការប្រៀបធៀប និងវាយតម្លៃលើជម្រើសគោលនយោបាយនានា។

តារាង ១៖ ការប្រមូលព័ត៌មានពី កសិករ ក្រុមពិភាក្សាស្នូល និងអ្នកផ្តល់ព័ត៌មានគន្លឹះ

| គម្រោង | ខេត្ត | កាលបរិច្ឆេទ | ភូមិ | ឃុំ | កសិករ | FGDs | KIs | អ្នកចូលរួម |
|---|---|---|---|---|---|---|---|---|
| ស្ទឹងជីនិត | កំពង់ធំ | ១១-២១ កក្កដា ២០១០ | 6 | 3 | 15 | 2 | 9 | អ្នកភូមិ សកបទ PDOWRAM មេភូមិ |
| ដំណាក់អំពិល | ពោធិ៍សាត់ | ១៣-១៨ កញ្ញា 2010 | 3 | 7 | 25 | 2 | 10 | អ្នកភូមិ សកបទ PDOWRAM, ក្រឃ, អ្នកយាមទឹក មេភូមិ |
| រលួស | កំពង់ធំ | 11-17 សីហា 2010 | 4 | 2 | 12 | 2 | 8 | អ្នកភូមិ សកបទ ក្រុមហ៊ុនឯកជន PDOWRAM មេភូមិ |

# ៤ តំបន់សិក្សា

## ៤.១ ប្រព័ន្ធធារាសាស្ត្ររលួស

ប្រព័ន្ធធារាសាស្ត្ររលួស ស្ថិតនៅចម្ងាយប្រហែល ៧គ.ម ភាគខាងលិចក្រុងស្ទឹងសែន (ទីរួមខេត្តកំពង់ធំ) និងជាប្រភេទអាងទឹករួមមានជម្រៅរាក់។ ទឹកហូរចូលក្នុងប្រព័ន្ធនេះតាម ប្រាំច្រកៈ ស្ពានពោធិ៍បាក្រុង លូរំដោះទឹកបល្ល័ង្គ ស្ពានត្បូងចាម ព្រែកស្បូវ និងព្រែកអូរឡេក (រូបភាព២)។ ស្ទឹងសែន ព្រែកស្បូវ និងព្រែកចោងម៉ោង ផ្តល់ទឹកច្រើនបំផុតទៅក្នុងប្រព័ន្ធរលួសដែលមានទំហំប្រមាណ ១០០៩ហិកតា ឆ្លងកាត់ ៧ភូមិ និង ៤ឃុំ[៩] គឺអូរគន្ធរ កំពង់រទេះ ដំរីជាន់ខ្លា និងស្រយ៉ូវ។ ដីស្រែនៅប្រព័ន្ធធារាសាស្ត្ររលួស ចែកចេញជាបីកម្រិតកម្ពស់។ ដីស្រែទាបបំផុត ស្ថិតនៅប៉ែកនិរតី ដីស្រែមានកម្ពស់មធ្យម ស្ថិតនៅជុំវិញប្រព័ន្ធ និងដីស្រែកម្រិតខ្ពស់ជាងគេ ស្ថិតនៅភាគខាងកើត។

រូបភាព ២៖ ផែនទីប្រព័ន្ធធារាសាស្ត្ររលួស និងតំបន់សិក្សា




ទំនប់ទឹកប្រវែង ៤គ.ម បានកសាងឡើងនៅឆ្នាំ១៩៦៩ ដើម្បីទប់ទឹកបម្រើកសិកម្មនៅតំបន់រលួស។ នៅឆ្នាំ ២០០៤ ទំនប់ទឹកនេះត្រូវបានជួសជុលឡើងវិញដោយ ក្រុមហ៊ុនស្រាវជ្រាវ និងអភិវឌ្ឍន៍ SBK (SBK Research and Development)។ ទំនប់នេះ មានទ្វារទឹក៧ លូរំដោះទឹក២ និងឧបករណ៍សម្រួលលំហូរទឹក ១៣។ រលួសជាប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម ដែលផ្តល់អត្ថប្រយោជន៍ឲ្យប្រមាណ ៨៨២គ្រួសារ។ ប្រឡាយមេ ប្រឡាយរងទី២ និងទី៣ បានកសាងឡើងក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ហើយបានចាស់ទ្រុឌទ្រោមដោយសារខ្វះការថែទាំ និងជួសជុល។

[៩] ទិន្នន័យប្រមូលបានពីរបាយការណ៍ប្រចាំឆ្នាំ២០១០ របស់ក្រុមហ៊ុនស្រាវជ្រាវ និងអភិវឌ្ឍន៍ SBK។

ប្រឡាយទាំងនេះ បានខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារព្យុះកេតសាណា នៅខែកញ្ញា ២០០៩។ ទ្វារទឹកទាំង៧ សម្រាប់គ្រប់គ្រងលំហូរទឹកទៅក្នុងប្រព័ន្ធ ហើយគេបិទវានៅរដូវវស្សាដើម្បីស្តុកទឹកទុកប្រើនៅរដូវប្រាំង។

ការចូលរួមរបស់វិស័យឯកជនក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធារាសាស្ត្រ បានចាប់ផ្តើមក្នុងខែសីហា ២០១០ ហើយបានផ្តល់ឱកាសសម្រាប់ការធ្វើស្រែប្រាំងនៅភាគខាងលិចនៃប្រព័ន្ធរលួស។ ហេដ្ឋារចនាសម្ព័ន្ធកាន់កាប់ដោយវិស័យឯកជន ជួយឲ្យប្រឡាយមេមានទឹកនៅម៉ុឌិតបឹងលៀសនៅរដូវប្រាំង ហើយថ្លៃសេវាផ្គត់ផ្គង់ទឹកគឺ ១០០ដុល្លារសម្រាប់ស្រូវមួយហិកតា។ កសិករដែលប្រើប្រឡាយឯកជននេះ ក៏ត្រូវបង់ថ្លៃបូមទឹកពីប្រឡាយចូលស្រែដែរដែលមានចំនួនពី ៥០-៦០ដុល្លារក្នុងស្រូវមួយហិកតា។ មុនពេលក្រុមហ៊ុនឯកជននេះមកដល់រលួស កសិករខ្លះត្រូវចំណាយអស់ប្រហែល ៦០-១០០ដុល្លារក្នុងស្រូវមួយហិកតា លើការបូមទឹកពីស្ទឹងចូលប្រឡាយមេ និងពីប្រឡាយមេចូលក្នុងស្រែរបស់គាត់។ ចំណាយលើការបូមទឹកនេះ ប្រែប្រួលខុសៗគ្នាពីកសិករម្នាក់ទៅកសិករម្នាក់ អាស្រ័យលើចម្ងាយពីស្រែគាត់ទៅប្រឡាយមេ។

តារាង ២៖ ព័ត៌មានសង្ខេបស្តីពីប្រព័ន្ធធារាសាស្ត្ររលួស

| បរិយាយ | រលួស |
|---|---|
| សាងសង់ | ១៩៦៩ (ទំនប់ទឹក)<br>១៩៧៥-១៩៧៩ (ប្រព័ន្ធប្រឡាយ) |
| ស្តារជួសជុលឡើងវិញ | ២០០៤ |
| ទំហំ (គិតជាហិកតា) | ១០០៩ |
| ស្រែវស្សា គិតជាហិកតា | ៦១០ |
| ស្រែប្រាំង គិតជាហិកតា | ៣៧៦ |
| សណ្ឋានរូបវ័ន្ត | អាងទឹករួមមានជម្រៅរាក់ |
| ប្រភេទប្រព័ន្ធ | ប្រព័ន្ធប្រើកម្លាំងទឹកហូរចុះតាមធម្មជាតិ (Gravity-fed system) |
| ឆ្នាំបង្កើត សកបទ | ២០០៤ |
| ឃុំ | ៣ |
| ភូមិ | ៧ |
| គ្រួសារ | ៨៨២ |

នៅរលួស កសិករធ្វើទាំងស្រូវវស្សា និងស្រូវប្រាំង ប៉ុន្តែស្រូវប្រាំងអាចធ្វើបានតែនៅតំបន់ភាគខាងជើង និងខាងលិចនៃប្រព័ន្ធប៉ុណ្ណោះ ដែលមានប្រព័ន្ធស្រោចស្រព និងលទ្ធភាពយកទឹកពីស្ទឹងជួយសម្រួលការដាំដុះ។ ស្រែវស្សាមានច្រើនលើសលុបដោយគ្របដណ្តប់លើផ្ទៃដី ៦១០ហិកតា ធៀបនឹងស្រែប្រាំងដែលមានតែ ៣៧៦ហិកតា។ ការធ្វើស្រូវប្រាំង កាន់តែពេញនិយមឡើង ព្រោះបានទិន្នផលប្រហែលពីរដងនៃស្រូវវស្សា (ដែលបានទិន្នផលត្រឹម ១,៥-២,៥ តោន/ហិកតា)។ កំណើនការធ្វើស្រែប្រាំងនេះ បានដាក់សម្ពាធទៅលើធនធានទឹកក្នុងតំបន់ ជាពិសេសនៅចុងរដូវវស្សាដែលជាពេលចាប់ផ្តើមធ្វើស្រែប្រាំង។ ទោះបីជាស្រូវប្រាំងផ្តល់ទិន្នផលខ្ពស់ក្តី ក៏ការឡើងចុះថ្លៃស្រូវនៅទីផ្សារ គួបផ្សំនឹងចំណាយផលិតកម្ម (ឧទាហរណ៍ ការប្រើម៉ាស៊ីនបូមទឹក ជី និងប្រឡាយឯកជន) នៅតែជាកត្តាគន្លឹះមួយដែលជះឥទ្ធិពលទៅលើទឹកចិត្តកសិករក្នុងការធ្វើស្រូវប្រាំង។

នៅឆ្នាំ២០០៤ ប្រព័ន្ធធារាសាស្ត្ររលួស មាន សកបទ ចំនួន២ គឺមួយនៅជុំវិញភូមិព្រៃកស្បូវ និងមួយទៀតនៅជុំវិញភូមិរលួស។ ប៉ុន្តែនៅឆ្នាំ២០០៧ ដោយពិនិត្យឃើញថា ពួកគាត់មិនមានលទ្ធភាពគ្រប់គ្រងគម្រោងឲ្យបានល្អនោះ សមាជិកគណៈកម្មការ សកបទ ព្រៃកស្បូវ បានសុំឲ្យអ្នកដឹកនាំ សកបទ រលួស ទទួលបន្ទុកនិងគ្រប់គ្រងតំបន់ទាំងមូល ហើយសហគមន៍ទាំងពីរ ក៏បានរួមបញ្ចូលគ្នា។ សកបទ រលួសមានសមាជិកសរុបបួននាក់៖ ប្រធាន អនុប្រធាន អ្នកកាន់

ហិរញ្ញវត្ថុ និងគណនេយ្យករ។ សកបទ នៅគម្រោងរលួស ចែកជា ៤អនុក្រុម ដែលហៅថា ក្រុមកសិករប្រើប្រាស់ទឹក (កកបទ)។ កកបទ ទាំងនោះតំណាងឲ្យបួនភូមិ គឺមាន អូរគន្ធរត្បូង ព្រៃកស្បូវ រលួស និងកំពង់សំរោង។

## ៤.២ ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល

ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ស្ថិតនៅចម្ងាយប្រហែល ១៥គ.ម ភាគខាងលិចស្រុកសំពៅមាស (ទីរួមខេត្ត ពោធិ៍សាត់) ក្នុងខេត្តពោធិ៍សាត់ និងប្រមាណ ១៩០គ.ម ពីក្រុងភ្នំពេញ។ ប្រព័ន្ធនេះ ជាអាងទឹកមានតំបន់ដីខ្ពស់ព័ទ្ធជុំវិញ និងស្ថិតនៅកណ្តាលខេត្តពោធិ៍សាត់ (រូបភាព ៣)។ ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិលទទួលទឹកភាគច្រើនពីស្ទឹងពោធិ៍សាត់ ហើយមានប្រព័ន្ធធារាសាស្ត្រជាច្រើនទៀតនៅខ្សែទឹកខាងក្រោមដែលទទួលទឹកពីប្រព័ន្ធដំណាក់អំពិល ដូចជា ប្រព័ន្ធក្រូចសើច អន្លង់ស្វាយ វត្តលៀប និងកំប៉ាង។ គម្រោងដំណាក់អំពិលគ្របដណ្តប់លើ ៧ឃុំ និង ៥០ភូមិ និងស្ថិតក្នុងចំណាត់ថ្នាក់ប្រព័ន្ធធារាសាស្ត្រខ្នាតធំ។

រូបភាព ៣៖ ផែនទីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងទីតាំងសិក្សាស៊ីជម្រៅ




ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិលមានទ្វារទឹកឈើ និងសាងសង់ឡើងនៅចន្លោះឆ្នាំ១៩៧៦ និង ១៩៧៨ ក្នុងសម័យខ្មែរក្រហម ដើម្បីបង្វែរទឹកពីស្ទឹងពោធិ៍សាត់ចូលក្នុងប្រឡាយមេ ទុកសម្រាប់ផ្គត់ផ្គង់ដល់ផ្ទៃដីប្រមាណ ២៧.០០០ហិកតា។ ប្រព័ន្ធនេះមិនបានទទួលការថែទាំទេរហូតដល់ឆ្នាំ២០០៥ ទើបមានការជួសជុលប្រឡាយមេឡើងវិញ ហើយទោះបីការជួសជុលនេះបានចប់សព្វគ្រប់នៅឆ្នាំ២០១០ក្តី ក៏ប្រឡាយរងទី២ និងទី៣ ភាគច្រើននៅតែមានសភាពទ្រុឌទ្រោមនៅឡើយ។ ប្រឡាយមេមានប្រវែង ២៥គ.ម ហើយតភ្ជាប់ទៅ ប្រឡាយរង ៨ ទ្វារទឹក ៣ និងឧបករណ៍សម្រួលលំហូរទឹក ៧។ មានកសិករជាច្រើនមិនទាន់ទទួលបានអត្ថប្រយោជន៍ពីប្រឡាយទាំងនេះទេ ហើយត្រូវប្រើប្រាស់មធ្យោបាយផ្ទាល់ខ្លួនដើម្បីយកទឹកពីប្រឡាយមេ មកបញ្ចូលក្នុងស្រែ។ គម្រោងសាកល្បងលើវាលស្រែរបស់ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) គ្រោងដំណើរការនៅឆ្នាំ២០១១-២០១៣ ដោយអនុវត្តលើផ្ទៃដីប្រមាណ ១០០

ហិកតា ក្នុង ៣ភូមិ គឺ ភូមិខ្នារ កណ្ដឹងមាស និង ឆ្មោះតាចាប។ គម្រោងនេះក៏មានការសាងសង់ប្រព័ន្ធប្រឡាយពេញលេញមួយ ដើម្បីបង្ហាញដល់កសិករមូលដ្ឋានពីរបៀបអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រថែមទៀតផង។

នៅខេត្តពោធិ៍សាត់ មានដីស្រែប្រមាណ ១០-១១% ប៉ុណ្ណោះដែលអាចស្រោចស្រពធ្វើស្រែប្រាំងបាន[៦] ។ ក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិលស្រូវវស្សាដាំដុះលើផ្ទៃដីប្រមាណជា ២០.០០០ហិកតា ហើយស្រូវប្រាំងដាំដុះលើប្រមាណ ៥០០០ហិកតា។ ក្នុងអំឡុងពេលពីរ-បីឆ្នាំចុងក្រោយនេះ កសិករកាន់តែព្យាយាមធ្វើស្រែប្រាំងឲ្យតែមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រព។ ដូច្នេះកំណើនការធ្វើស្រូវប្រាំងបានកើនឡើងនៅតាមដីស្រែដែលនៅជិតប្រឡាយមេ។ ស្ថិតិថ្មីៗបង្ហាញថា ស្រូវប្រាំងផ្ដល់ផល ២,៥-៣តោន/ហិកតា ហើយស្រូវវស្សាផ្ដល់ផល ២-២,៥តោន/ហិកតា។ ស្ថិតិនេះបង្ហាញពីទិន្នផលជាមធ្យម ហើយកង្វះខាតទឹកជាបញ្ហាដ៏ធ្ងន់ធ្ងរចំពោះកសិករនៅខេត្តពោធិ៍សាត់ ព្រោះគ្រោះរាំងស្ងួតបានកើតមានឡើងនៅរដូវវស្សាក្នុងពីរ-បីឆ្នាំចុងក្រោយនេះ និងកាន់តែមានរយៈពេលយូរឡើងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ពេលខ្លះ កសិករដែលមានស្រែនៅឆ្ងាយពីប្រឡាយស្រោចស្រព ត្រូវប្រើម៉ាស៊ីនបូមទឹកមកបំពេញបន្ថែមលើទឹកភ្លៀងថែមទៀត។

តារាង ៣៖ ព័ត៌មានសង្ខេបពីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល

| បរិយាយ | ដំណាក់អំពិល |
|---|---|
| សាងសង់ | ១៩៧៦-១៩៧៨ |
| ជួសជុល | ២០០៦-២០១០ |
| ទំហំ (គិតជាផ្ទៃដីស្រោចស្រពជាហិកតា) | ២៧.០០០ |
| ស្រែវស្សា គិតជាហិកតា | ២០.០០០ |
| ស្រែប្រាំង គិតជាហិកតា | ៥០០០ |
| សណ្ឋានរូបវ័ន្ត | ប្រឡាយមេ ប្រឡាយរងទី២ ប្រឡាយរងទី៣ |
| ប្រភេទប្រព័ន្ធ | ទំនប់បង្វែរទឹក/ប្រឡាយមេ |
| ឆ្នាំ សកបទ បានបង្កើតឡើង | ៣ក់កណ្ដាលឆ្នាំ២០០៧ |
| ឃុំ | ៧ |
| ភូមិ | ៥០ |
| គ្រួសារ | មិនមានទិន្នន័យ |

ធនាគារពិភពលោក បានគាំទ្រ PDOWRAM ឲ្យបង្កើត សកបទ ដំណាក់អំពិល ដែលបានចុះឈ្មោះនៅក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០០៤-០៥។ គណៈកម្មការ សកបទ រួមមាន ប្រធានមួយរូប អនុប្រធានពីររូប មន្ត្រីហិរញ្ញវត្ថុមួយរូប និងគណនេយ្យករមួយរូប ដែលសុទ្ធតែជាសមាជិក ក្រយ។ ជំទប់ទី១នៃឃុំលលកស គឺជាប្រធានសកបទ។ យោងតាម PDOWRAM នៅពេលប្រព័ន្ធបានជួសជុលរួចរាល់ហើយ គេនឹងបង្កើត កកបទ ឡើង ដើម្បីឲ្យទទួលខុសត្រូវលើការបែងចែកទឹកតាមប្រឡាយរង។ PDOWRAM គ្រោងផ្ដល់ការបណ្ដុះបណ្ដាលពី PIMD និងគោលការណ៍គ្រប់គ្រងទឹកផ្សេងៗទៀត ដល់គណៈកម្មការ សកបទ កកបទ ឃុំ និងអ្នកភូមិដែលរស់នៅតាមបណ្ដោយប្រឡាយមេ ដើម្បីឲ្យពួកគេអាចគ្រប់គ្រងប្រព័ន្ធធារាសាស្ត្របានកាន់តែប្រសើរ។

## ៤.៣ ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត

ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្ថិតក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ក្នុងចម្ងាយប្រមាណ ១៤០គ.ម ពីខាងជើងក្រុងភ្នំពេញ និងទទួលទឹកពីស្ទឹងជីនិត។ ប្រព័ន្ធនេះផ្ដល់ទឹកស្រោចស្រពសម្រាប់ផ្ទៃដី ២៦៤៥ហិកតា ដែលផ្ដល់អត្ថប្រយោជន៍ដល់ ៣០០០គ្រួសារ ក្នុង ២៤ភូមិ និង ៣ឃុំ[៧] និងស្ថិតក្នុងប្រភេទ ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម (រូបភាព

[៦] ព័ត៌មានទទួលបានពី ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ ឆ្នាំ២០១០

[៧] ព័ត៌មានពីប្រធាន PDAFF ខេត្តពោធិ៍សាត់ ឆ្នាំ២០១០

៤)។ ដីស្រែបានរៀបចំឡើងវិញជារាងចតុកោណដើម្បីសម្រួលការដឹកប្រឡាយបញ្ចូលទឹក។ សរុបមក ប្រព័ន្ធនេះចែកចេញជាដីស្រែ ៤៨ប្លុក ដោយប្លុកនីមួយៗមានផ្ទៃដីប្រមាណ ៥០-១០០ហិកតា[៨]។

រូបភាព ៤៖ ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត និងទីតាំងសិក្សាស៊ីជម្រៅ




ប្រព័ន្ធធារាសាស្ត្រនេះ កសាងឡើងនៅឆ្នាំ១៩៧៨ ក្នុងរបបខ្មែរក្រហម និងបានស្តារឡើងវិញក្នុងឆ្នាំ១៩៨០-៨៧, ១៩៨៩, ១៩៩០ និង ១៩៩៣ ដោយ MAFF។ នៅឆ្នាំ២០០០ និងចាប់ពីឆ្នាំ២០០២ ដល់ ២០០៨ ប្រព័ន្ធនេះត្រូវបានសិក្សា និងកែជួសជុលជាថ្មី ក្នុងលក្ខណៈជាផ្នែកមួយនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ និងធារាសាស្ត្រស្ទឹងជីនិត (SCIRIP) ដែលទទួលហិរញ្ញប្បទានរួមដៃគ្នាពី ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) និងរាជរដ្ឋាភិបាលកម្ពុជា (RGC)។ SCIRIP ផ្តោតជាសំខាន់លើ៖ ១) ការបង្កើត សកបទ ២) ការកែលំអប្រព័ន្ធដាំដុះ[៩] ៣) ការស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ[១០] និង ៤) ការអភិវឌ្ឍផ្លូវថ្នល់និងទីផ្សារជនបទ[១១] ។

ប្រព័ន្ធស្ទឹងជីនិត បានជួសជុលរួចរាល់ហើយ និងរួមមាន ទំនប់បង្វែរទឹកមួយ និងទំនប់បង្ហៀរមួយប្រវែង ៧០០ម ប្រឡាយមេប្រវែង១៦គ.ម ប្រឡាយរងទី២ចំនួន៥ ប្រឡាយរងទី៣ មួយចំនួនតូចសម្រាប់បង្ហាញជាគំរូ[១២] និងអាងទឹកធំមួយសម្រាប់ផ្ទុកទឹកប្រមាណ ២៣លានម៉ែត្រគូប ដើម្បីស្រោចស្រពលើផ្ទៃដីក្នុងប្រព័ន្ធទាំងមូល។ ប្រឡាយភាគច្រើនក្នុងប្រព័ន្ធនេះ មានលំហូរទឹកដែលហូរចុះតាមធម្មជាតិ (gravity-fed)។

---

៨ ទិន្នន័យពីការសម្ភាសជាមួយសមាជិកគណៈកម្មការ សកបទ ស្ទឹងជីនិត ឆ្នាំ២០១០

៩ ផ្តល់ហិរញ្ញប្បទានដោយ AFD និង អនុវត្តដោយ MOWRAM

១០ Ibid

១១ ផ្តល់ហិរញ្ញប្បទានដោយ ADB និងអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ

១២ រចនារៀបចំឡើងដើម្បីបង្ហាញពីរបៀបនិងទីតាំងកសាងប្រឡាយរងទី៣ ថែមទៀត។ ប៉ុន្តែ ចាប់តាំងពីគម្រោង SCIRIP បានបញ្ចប់ទៅ មិនមានប្រឡាយរងទីបីណាផ្សេងទៀត បានសាងសង់ឡើងដោយកសិករនោះទេ។

តារាង ៤៖ ព័ត៌មានសង្ខេបពីប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត

| | |
|---|---|
| បរិយាយ | ស្ទឹងជីនិត |
| សាងសង់ | ១៩៧៧ |
| ជួសជុល | ១៩៨០-៨៧<br>១៩៨៩ ១៩៩០ និង ១៩៩៣<br>២០០០ ២០០២ និង ២០០៤ |
| ទំហំ(ផ្ទៃដីស្រោចស្រពគិតជាហិកតា) | ២៦៤៥ |
| ស្រែវស្សា គិតជាហិកតា | ១៥០០ |
| ស្រែប្រាំង គិតជាហិកតា | ៥០០ |
| សណ្ឋានរូបវ័ន្ត | ប្រព័ន្ធប្រឡាយពេញលេញ (ប្រឡាយមេ ប្រឡាយរងទី២ និងទី៣)។ ដីស្រែចែកជា ៤៨ប្លុក ប្លុកនីមួយៗមានទំហំ ៥០-១០០ហិកតា |
| ប្រភេទប្រព័ន្ធ | ទំនប់បង្វៀរ |
| ឆ្នាំបង្កើត សកបទ | ២០០២-០៤ (ចុះបញ្ជីក្នុងឆ្នាំ២០០៦) |
| ឃុំ | ៣ |
| ភូមិ | ២៦ |
| គ្រួសារ | ៣០០០ |

កសិករនៅស្ទឹងជីនិត ធ្វើស្រែវស្សាតាមបែបប្រពៃណីជាសំខាន់ និងមានធ្វើស្រែប្រាំងខ្លះៗ ហើយក៏មានធ្វើនេសាទ និងចិញ្ចឹមសត្វផងដែរ។ ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត រចនារៀបចំឡើងដើម្បីផ្គត់ផ្គង់ទឹកដល់ផ្ទៃដីស្រែវស្សាប្រមាណ ១៥០០ហិកតា និងស្រែប្រាំង ៥០០ហិកតា។ ស្ទឹងជីនិត មានទឹកសម្បូរទាំងក្នុងរដូវវស្សា និងរដូវប្រាំង ប៉ុន្តែមានកសិករមួយចំនួនតូចទេដែលអនុវត្តធ្វើស្រែប្រាំង ដោយភាគច្រើនទៅរកការងារធ្វើកន្លែងផ្សេង ដូចជា នៅក្នុងចំការកៅស៊ូទំរីង ឬក៏ដាំដំណាំផ្សេងទៀត ដូចជា ត្រសក់ និងឪឡឹកជាដើម។ កសិករដែលធ្វើស្រែប្រាំង ត្រូវជួបបញ្ហាសត្វល្អិតចង្រៃ ទិន្នផលទាបត្រឹមប្រមាណ ៣-៤តោន/ហិកតា (ស្រូវវស្សាបានប្រមាណ ២-២.៥តោន/ហិកតា) បញ្ហាគោក្របីចូលស៊ីស្រូវ បញ្ហាជី និងថ្នាំសម្លាប់សត្វចង្រៃមានថ្លៃខ្ពស់ និងបញ្ហាថ្លៃអង្ករឡើងចុះ។

សកបទ ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត បានកកើតឡើងជាផ្លូវការក្នុងឆ្នាំ២០០២ និងចុះបញ្ជីនៅ MOWRAM ក្នុងឆ្នាំ២០០៦ (Chem *et al.* 2010)។ គណៈកម្មការថ្មី ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងឆ្នាំ២០០៧ ដោយមានការចូលរួមពី ២៦ភូមិ ក្នុង ៣ឃុំ ស្ថិតក្នុងតំបន់នៃប្រព័ន្ធធារាសាស្ត្រ[១៣] ។ សកបទ មានសមាជិក ១០រូប[១៤] រួមមាន ប្រធាន អនុប្រធានទី១ ទទួលបន្ទុកផ្នែកធារាសាស្ត្រ និងអនុប្រធានទី២ ទទួលបន្ទុកផ្នែកដំណើរការ និងថែទាំជួសជុល (មានជំនួយការរៀងៗខ្លួន) មន្ត្រីហិរញ្ញវត្ថុ និងលេខាធិការទទួលបន្ទុកផ្នែកបទបញ្ជាផ្ទៃក្នុងនិងការដោះស្រាយទំនាស់ ព្រមទាំងបុគ្គលិកជំនួយ ៣រូប គឺនាយកមួយនាក់ទទួលបន្ទុកការគ្រប់គ្រងទូទៅ ផ្តល់មតិប្រឹក្សា សរសេររបាយការណ៍ ធ្វើផែនការ និងធ្វើទំនាក់ទំនងជាមួយគណៈកម្មការគាំទ្រ និងជំនួយការ ២រូប គឺមួយរូបទទួលបន្ទុកខាងកិច្ចការទូទៅ និងមួយរូបទៀតទទួលបន្ទុកលើកិច្ចការហិរញ្ញវត្ថុ។ PDOWRAM ទទួលបន្ទុកលើការគ្រប់គ្រងទឹកក្នុងប្រឡាយមេ ចំណែកឯគណៈកម្មការ សកបទ ទទួលបន្ទុកលើប្រឡាយរងទី២ និងប្រឡាយដោះទឹកផ្សេងទៀត។ កកបទ នឹងត្រូវបង្កើតឡើងដើម្បីគ្រប់គ្រងលើប្រឡាយរងទី៣ និងប្រឡាយដោះទឹកផ្សេងៗ។

[១៣] ផ្អែកលើការប្រាស្រ័យទាក់ទងជាមួយគណៈកម្មការ សកបទ ឆ្នាំ២០១០

[១៤] មានសមាជិកតាមផ្លូវច្បាប់ចំនួនប្រាំរូប (ប្រធានមួយរូប អនុប្រធានពីររូប មន្ត្រីហិរញ្ញវត្ថុមួយរូប និងជំនួយការមួយរូប) និងបុគ្គលិកបន្ថែមចំនួនប្រាំរូប (ជំនួយការពីររូប គឺមួយនាក់សម្រាប់អនុប្រធាននីមួយៗ និងបុគ្គលិកគាំទ្រចំនួនបីរូប គឺមាន នាយក និងជំនួយការពីររូប)។

# ៥ លទ្ធផលស្រាវជ្រាវ

## ៥.១ ការណែនាំបង្ហាញពីលទ្ធផលស្រាវជ្រាវ

អភិបាលកិច្ចទឹកមានលក្ខណៈខុសៗគ្នាទៅតាម ប្រព័ន្ធធារាសាស្ត្រនីមួយៗដែលបានសិក្សា ដោយសារកត្តាជាច្រើន ដូចមាន ភាពខុសគ្នាផ្នែក ទំហំ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រចនាសម្ព័ន្ធនៃអង្គភាពអភិបាលកិច្ចទឹក ការសម្របសម្រួល និងការចូលរួមរបស់កសិករ សមត្ថភាពផ្ទៃក្នុងរបស់គណៈកម្មការ សកបទ និងការជំនួយទ្រទ្រង់ពីខាងក្រៅសម្រាប់ សកបទ ក្នុងប្រព័ន្ធនីមួយៗ។ លទ្ធផលបានពីការសម្ភាស និងពិនិត្យសង្កេតដល់កន្លែង ត្រូវបានយកមកបកស្រាយទៅតាមបរិបទនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រជាក់ស្តែងនៅតំបន់ជនបទប្រទេសកម្ពុជា និងកម្រិតនៃការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងទឹក។ ជំពូកនេះចែកចេញជាបីផ្នែកពាក់ព័ន្ធនឹងព័ត៌មានប្រមូលបានពីអ្នកឆ្លើយសម្ភាសន៍ ពោលគឺ ការរៀបចំអភិបាលកិច្ចជាក់ស្តែង ការចូលរួមរបស់កសិករ និងការសម្របសម្រួលអ្នកពាក់ព័ន្ធ។ សមាសធាតុទាំងបួននៃអភិបាលកិច្ចប្រព័ន្ធធារាសាស្ត្រ (ការថែទាំប្រព័ន្ធ ការបែងចែកទឹក ការសម្របសម្រួល និងការគ្រប់គ្រងទំនាស់) ដូចមានបញ្ជាក់ក្នុងសំណួរស្រាវជ្រាវនៃការសិក្សានេះ អាចធំទូលាយជាងផ្នែកទាំងបីខាងលើ ហើយត្រូវបានពិនិត្យវិភាគឆ្លងតាមករណីសិក្សាដែលមានលើកជាឧទាហរណ៍បន្តបន្ទាប់នៅក្នុងជំពូកនេះ។

## ៥.២ ការរៀបចំអភិបាលកិច្ចជាក់ស្តែង

### *៥.២.១ ភាពពេញច្បាប់នៃ សកបទ*

ភាពពេញច្បាប់នៃ សកបទ ត្រូវបានទទួលស្គាល់ខ្លាំងជាងគេនៅកម្រិត PDOWRAM ចំណែកឯអ្នកភូមិ និងក្រសួងធនធានទឹក និងឧតុនិយម មិនមែនតែងតែទទួលស្គាល់ទាំងស្រុងថា គណៈកម្មការ សកបទ ជាអង្គភាពអភិបាលកិច្ចពេញមុខច្បាប់នោះទេ។ សកបទ នៅក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងស្ទឹងជីនិត បានចុះបញ្ជីផ្លូវការរួចហើយនៅឯ MOWRAM។ ក្នុងប្រព័ន្ធធារាសាស្ត្ររលួស សកបទ បានធ្វើប្រតិបត្តិការតាំងពីឆ្នាំ២០០៤ និងបានធ្វើការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការបីលើករួចមកហើយ (ក្នុងឆ្នាំ២០០៤ ២០០៧ និង ២០១០[១៥]) ប៉ុន្តែមិនទាន់បានចុះបញ្ជីនៅ MOWRAM ទេ បើទោះជាមានការទទួលស្គាល់ជាផ្លូវការដោយអ្នកស្រុក និង PDOWRAM ក្តី។ អ្នកតំណាងរបស់ សកបទ ក្នុងប្រព័ន្ធធារាសាស្ត្ររលួស បានរាយការណ៍ថា រាល់លក្ខខណ្ឌ និងតម្រូវផ្សេងៗដែលមានចុះក្នុងលក្ខន្តិកៈបង្កើតគណៈកម្មការ សកបទ គឺបានបំពេញហើយ ប៉ុន្តែដោយសារកំហិតខាងថវិការបស់ សកបទ និង PDOWRAM គេមិនបានអញ្ជើញអ្នកតំណាងពី MOWRAM ឲ្យមកចូលរួមការបោះឆ្នោតទេ។ ទោះបីមានការទទួលស្គាល់គណៈកម្មការ សកបទ ថាជាអង្គភាពអភិបាលកិច្ចមួយក្តី ក៏កសិករមួយចំនួនបានប្រាប់ថា ពួកគាត់មិនសូវទុកចិត្តលើសមត្ថភាពគណៈកម្មការក្នុងការគ្រប់គ្រងប្រព័ន្ធទេ ព្រោះពុំមានឯកសារចុះបញ្ជីជាផ្លូវការជាមួយ MOWRAM ហើយអារម្មណ៍ខ្វះទំនុកចិត្តនេះកាន់តែឃើញថាត្រឹមត្រូវឡើង ឆ្លងតាមសកម្មភាពឆ្លើយតបមិនគ្រប់គ្រាន់ក្នុងអំឡុងពេលមានខ្យល់ព្យុះកេតសាណានៅឆ្នាំ២០០៩ និងការពុំអាចបង្ហាញពីសមត្ថភាពខាងបច្ចេកទេស និងកសិកម្មរបស់គណៈកម្មការ សកបទ។

បទសម្ភាសន៍ជាមួយតំណាង PDOWRAM ជាច្រើននាក់នៅខេត្តពោធិ៍សាត់ បានបង្ហាញថា ទីភ្នាក់ងារអ្នកផ្តល់ជំនួយបានណែនាំឲ្យ បង្កើតគោលនយោបាយមួយទប់ស្កាត់សមាជិកសហគមន៍ដែលកំពុងកាន់មុខតំណែងក្នុងជួរ

---

[១៥] ការបោះឆ្នោតលើកក្រោយបំផុត ធ្វើឡើងនៅខែឧសភា ២០១០ ដោយបានអញ្ជើញសមាជិក PDOWRAM ម្នាក់មកចូលរួម (ការប្រាស្រ័យទាក់ទងជាមួយប្រធាន សកបទ នៅ រលួស ថ្ងៃទី១ មេសា ២០១១)។

អាជ្ញាធរ (ឧទាហរណ៍ សមាជិក ក្រុយ) កុំឲ្យមកឈរឈ្មោះបោះឆ្នោតចូលជាសមាជិកនៃ សកបទ[១៦]។ មតិណែនាំនេះមានឥទ្ធិពលខ្លាំងគួរសមរហូតមកទល់ពេលថ្មីៗនេះ។ សកបទ ដែលទើបបង្កើតថ្មីនៅក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល មានសមាជិក ក្រុយ ប្រាំពីរនាក់ មកពីឃុំខុសៗគ្នានៅក្នុងតំបន់ស្រោចស្រព។ PDOWRAM ខេត្តពោធិ៍សាត់ បានលើកហេតុផលថា តំណាងមកពី ក្រុយ ទាំងនេះ "មានគេស្គាល់ច្រើន មានប្រជាប្រិយភាព មានបទពិសោធន៍ក្នុងការគ្រប់គ្រង ធ្លាប់ដឹកនាំបានល្អក្នុងពេលកន្លងមក មានដីស្រែនៅក្នុងតំបន់ស្រោចស្រព និងមានស្ថានភាពសេដ្ឋកិច្ចនឹងនរ"។ ដោយផ្អែកលើកត្តាទាំងនេះ ក្រុមអ្នកមានជីវភាពថ្នាក់កណ្តាល[១៧] និងជាសមាជិកសហគមន៍មានប្រជាប្រិយភាព ក៏បានទទួលការតែងតាំងក្នុងការបោះឆ្នោតជ្រើសរើស សកបទ នៅខេត្តពោធិ៍សាត់។ ស្រដៀងគ្នានេះដែរ អនុប្រធាន សកបទ នៅប្រព័ន្ធរលួស ជាអតីតសមាជិក ក្រុយ ហើយគេបានជ្រើសតាំងរូបគាត់ ដោយសារហេតុផលប្រហាក់ប្រហែលគ្នានឹងការជ្រើសតាំងសមាជិកគណៈកម្មការ សកបទ នៅប្រព័ន្ធដំណាក់អំពិលដែរ ពោលគឺ សហគមន៍បានទទួលស្គាល់គាត់ថាជាមនុស្សស្មោះត្រង់ និងមានតម្លាភាពក្នុងការងារហិរញ្ញវត្ថុ។ លើសពីនេះទៀត គាត់មានបណ្តាញល្អៗនៅក្នុងស្ថាប័នរដ្ឋ និងធ្លាប់ជាអ្នកដឹកនាំដ៏ល្អជួយដោះស្រាយសំណូមពរ និងបញ្ហាផ្សេងៗរបស់កសិករ។ ផ្ទុយទៅវិញ គណៈកម្មការ សកបទ ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត សុទ្ធតែជាសមាជិកសហគមន៍ដែលគ្មានកាន់មុខតំណែងក្នុងជួររដ្ឋអំណាច។

*៥.២.២ តួនាទីជាក់ស្តែងរបស់សហគមន៍កសិករប្រើប្រាស់ទឹក*

នៅពេលបង្កើត សកបទ បានហើយ PDOWRAM ដោយសហការជាមួយ គណៈកម្មការ សកបទ ក៏បង្កើតនូវលក្ខន្តិកៈមួយដែលបញ្ជាក់ពីតួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មការ សកបទ ព្រមទាំងចំណុចលំអិតផ្សេងៗ ដូចជា ការត្រូវយកកម្រៃលើថ្លៃសេវាកម្មធារាសាស្ត្រ (ISF) ជាដើម។ លក្ខន្តិកៈនេះ ជាទូទៅផ្អែកលើ គំរូដែលមានចុះក្នុងសារាចរណ៍លេខ១ អំពី "ក្របខ័ណ្ឌច្បាប់ស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព" (MOWRAM 1999)។ ដោយមូលហេតុនេះ តួនាទីតាមផ្លូវច្បាប់របស់គណៈកម្មការ សកបទ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នានៅតាមគម្រោងនានា។

ភាពខុសគ្នារវាងតួនាទីរបស់គណៈកម្មការ សកបទ ផុសចេញជាចម្បងពីសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ព្រមទាំងកម្រិតនៃការប្រាស្រ័យទាក់ទងរវាងសមាជិក សកបទ និងអ្នកពាក់ព័ន្ធឯទៀតៗ។ ទោះបី សកបទ នៅក្នុងករណីសិក្សា បានដំណើការដោយមានជោគជ័យខុសៗគ្នាក្តី ប៉ុន្តែសម្ភាសន៍ និងអង្កេតដល់កន្លែង បានបង្ហាញតួនាទីជាទូទៅមួយចំនួនរបស់គណៈកម្មការ សកបទ ដូចខាងក្រោម៖

១. ជាកន្លែងសម្រាប់ឲ្យកសិករទំនាក់ទំនង នៅពេលកើតមានបញ្ហាខាងគ្រប់គ្រងទឹកដែលពួកគាត់មិនអាចដោះស្រាយសម្រួលគ្នាបាន ហើយត្រូវយកទៅពិភាក្សាជាមួយ PDOWRAM ក្រុយ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីឲ្យជួយដោះស្រាយ។

២. គ្រប់គ្រងលើការបែងចែកទឹក និងដោះស្រាយទំនាស់តូចៗនៅក្នុងសហគមន៍។

៣. ចាត់ចែងប្រមូលថ្លៃសេវាស្រោចស្រពសម្រាប់ដោះស្រាយការងារដំណើរការ និងថែទាំជួសជុល។

៤. លើកទឹកចិត្ត និងជម្រុញការចូលរួមរបស់កសិករ។

៥. សម្របសម្រួលជាមួយមន្ទីរខេត្ត អាជ្ញាធរមូលដ្ឋាន មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ វិស័យឯកជន និង NGOs សម្រាប់ការថែទាំ និងអភិវឌ្ឍន៍គម្រោង។

៦. ផ្សព្វផ្សាយគោលនយោបាយរដ្ឋាភិបាល និងរាយការណ៍ ឬចែករំលែកព័ត៌មាន ជាមួយកសិករ រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។

---

[១៦] ចំណុចនេះ មិនមាននៅក្នុងគោលការណ៍ណែនាំ ស្តីពី ការបង្កើត សកបទ ឡើយ។

[១៧] កសិករដែលចំណាយជាមធ្យម ២,៥ដុល្លារ/ថ្ងៃ (លើអាហារ និងធាតុចូលកសិកម្ម) មានដីស្រែប្រហែល ២-៣ហិចតា មានគោក្របី ៣-៤ក្បាល ឬគោយន្ត ១គ្រឿង។

បទសម្ភាសន៍នៅប្រព័ន្ធធារាសាស្ត្រល្អស ជាពិសេសជាមួយកសិករ បង្ហាញថា គណៈកម្មការ សកបទ នៅខ្វះសមត្ថភាពដើម្បីដោះស្រាយបញ្ហាឲ្យបានឆាប់រហ័ស និងសមស្រប នៅក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រ។ តួយ៉ាង នៅពេលកសិករលើកពីតម្រូវការបន្ទាន់ធ្វើការជុសជុលហេដ្ឋារចនាសម្ព័ន្ធដែលត្រូវខូចខាត ដោយសារខ្យល់ព្យុះកេតសាណាក្នុងឆ្នាំ២០០៩ សកបទ បានឆ្លើយតបយឺតយ៉ាវ ធ្វើឲ្យកសិករជាច្រើនបាត់បង់ទំនុកចិត្ត ហើយការខូចខាតនេះមិនទាន់បានដោះស្រាយនៅឡើយទេរហូតមកទល់បច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី កសិករនៅតែបន្តនាំយកបញ្ហាទឹកទៅឲ្យគណៈកម្មការ សកបទ ជួយដោះស្រាយ ហើយតួនាទីជាអ្នកសម្របសម្រួលនេះ បានក្លាយជាតួនាទីចម្បងរបស់គណៈកម្មការ។ គណៈកម្មការ សកបទ តែងរាយការណ៍ពីបញ្ហារបស់កសិករទៅដល់ PDOWRAM ឬ ក្រយ ហើយដំណោះស្រាយតែងរកឃើញ និងបញ្ជូនមកគណៈកម្មការ សកបទ ដើម្បីផ្សព្វផ្សាយបន្តទៅកសិករ។

នៅឯប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល សមាជិកគណៈកម្មការ សកបទ និងប្រធានភូមិ បានពន្យល់ថា ទោះបីកសិករមិនសូវពេញចិត្តនឹងរយៈពេលនៃការឆ្លើយតបរបស់ សកបទ ទៅនឹងសំណើរបស់ពួកគេក្តី ក៏នៅទីបំផុតគណៈកម្មការ សកបទ ច្រើនតែដោះស្រាយបញ្ហាបានដោយមានការសម្របសម្រួលពី PDOWRAM។ ពួកគាត់យល់ថាជោគជ័យនេះភាគច្រើនបានមកដោយសារមានប្រព័ន្ធប្រាស្រ័យទាក់ទងគ្នាល្អរវាង សកបទ ក្រយ អភិបាលស្រុក និង PDOWRAM។ កសិករក្នុងគម្រោងដំណាក់អំពិល និយាយថា ពួកគេគាំទ្រ និងជឿទុកចិត្តលើគណៈកម្មការ សកបទ ព្រោះគណៈកម្មការនេះ មានសមត្ថភាពក្នុងការដោះស្រាយបញ្ហាជម្លោះទឹក។ ឧទាហរណ៍ កាលដែលជួបកង្វះខាតទឹកនាពេលថ្មីៗនេះ កសិករបានលើកពីបញ្ហាមួយទាក់ទងនឹងការលៃចែកទឹកទៅឲ្យសមាជិក ក្រយ ម្នាក់ដែលត្រូវជាសមាជិកគណៈកម្មការ សកបទ ផងដែរ ហើយគណៈកម្មការក៏បានទាក់ទងទៅ PDOWRAM ដែលបានបញ្ជូនតំណាងម្នាក់ឲ្យចុះមកជួយដោះស្រាយ។ ពិតហើយ វិធីសាស្ត្រនេះអាចប្រើបាននៅពេលបញ្ហាអាចដោះស្រាយបានតាមរយៈវិធីអនុវត្តជាក់ស្តែង និងជំនួយបច្ចេកទេស ដូចជា ក្នុងករណីប្រឡាយមេនៅមានទឹក ហើយកិច្ចព្រមព្រៀងផ្សេងៗ មានជាអាទិ៍ ការកែតម្រូវ និងការលៃចែកទឹកឡើងវិញ អាចធ្វើទៅបាន។

មន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ធំ បានបញ្ជាក់ថា ការបង្កើត សកបទ គឺដើម្បីលើកកម្ពស់ការគ្រប់គ្រងទឹក និងជួយកែលំអផលិតភាពកសិកម្មរបស់ប្រជាជនក្នុងមូលដ្ឋាន ប៉ុន្តែនាបច្ចុប្បន្នសមាជិក សកបទ ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត មានរាយការណ៍តែពីបញ្ហាទាក់ទងនឹងការប្រមូល ISF និងការគ្រប់គ្រងទំនាស់ ហើយខាងមន្ទីរកំពុងតែលើកទឹកចិត្តឲ្យ សកបទ មកពិគ្រោះយោបល់អំពីបញ្ហាដទៃទៀតផងដែរ។

> *គណៈកម្មការ សកបទ ដែលកសិករបានបោះឆ្នោតជ្រើសតាំង ត្រូវគិតគូរជ្រើសរើសជីល្អៗ គ្រាប់ពូជ ថ្នាំសម្លាប់សត្វចង្រៃ ប្រភេទដំណាំ ធ្វើការកសាងផែនការ និងដឹកនាំកសិករដើម្បីទទួលបានទិន្នផលល្អ។*[១៨]

ដោយមានការគាំទ្របច្ចេកទេសពី PDOWRAM និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) គណៈកម្មការសកបទនៃប្រព័ន្ធដំណាក់អំពិលបានជ្រើសរើសកសិករមួយចំនួនឲ្យចូលរួមវគ្គបណ្តុះបណ្តាលផ្នែកកសិកម្មលើសកម្មភាព ដូចជា របៀបផលិតនិងប្រើជីកំប៉ុស ជីលាមកសត្វ និងរបៀបចិញ្ចឹមគោក្របី ជាដើម។ កសិករទាំងឡាយយល់ឃើញថា សកម្មភាពកសាងចំណេះដឹងទាំងនេះ មានប្រយោជន៍ណាស់សម្រាប់ការបង្កើនផលិតផលរបស់ខ្លួន។ PDAFF បានជ្រើសរើសកសិករស្នូលមកពីខេត្តកំពង់ធំ ឲ្យមកបណ្តុះបណ្តាលកសិករដទៃទៀត អំពីបច្ចេកទេសជាក់ស្តែងធ្វើកសិកម្ម។ PDAFF, PDOWRAM និង គណៈកម្មការ សកបទ សង្ឃឹមថា កសិករទាំងនេះនឹងបង្ហាញពីបច្ចេកទេសនានាដែលគាត់បានរៀនពីអ្នកដទៃ ហើយនៅពេលឃើញជោគជ័យនៃបច្ចេកទេសថ្មីៗ កសិករកាន់តែច្រើនឡើងនឹងយកវិធីទាំងនេះទៅអនុវត្ត។ តាមពិត បន្ទាប់ពី PDAFF ចាកចេញទៅ មានកសិករតិចនាក់ណាស់ដែលអនុវត្តតាមបច្ចេកទេសថ្មីៗទើបរៀនសូត្របាន ។

---

១៨ សម្ភាសន៍ជាមួយប្រធាន PDOWRAM ខេត្តកំពង់ធំ នៅការិយាល័យ PDOWRAM ក្នុងឆ្នាំ២០១០

ក្នុងពេលសម្ភាសន៍ និង FGDs នៅឯប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត មានការលើកមតិផ្ទុយគ្នាពីសមត្ថភាពក្នុងការបែងចែកទឹករបស់គណៈកម្មការ សកបទ។ កសិករខ្លះនិយាយថា ការបែងចែកទឹក មានដំណើរការរលូនល្អក្រោមការគ្រប់គ្រងរបស់ សកបទ ហើយគណៈកម្មការដោះស្រាយបញ្ហាបែងចែកទឹកបានល្អ ហើយអាចផ្ដល់ដំណោះស្រាយផ្នែកបច្ចេកទេសជួយដល់កសិករបានជារឿយៗ។ កសិករផ្សេងទៀតសម្ដែងការមិនពេញចិត្តនឹង កង្វះការជួយជ្រោមជ្រែងពីគណៈកម្មការក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងប្រឡាយរងទី៣ នៅក្នុង និងនៅចន្លោះរវាងដីស្រែនីមួយៗ។ អ្នកភូមិម្នាក់បានប្រាប់ថា ទោះបីតួនាទីរបស់ សកបទ មានរាប់បញ្ចូលទាំងកិច្ចប្រឹងប្រែងដោះស្រាយបញ្ហារបស់កសិករដែរក្ដី ក៏ពួកគេចង់ឲ្យកសិករទទួលបានចំណេះដឹង និងបទពិសោធន៍ តាមរយៈការចូលរួមកាន់តែច្រើនក្នុងសកម្មភាពកសិកម្ម ជាជាងចាំតែពឹងផ្អែកលើគណៈកម្មការ។

ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយកសិករក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត បានបង្ហាញថា ដោយសារកសិករបង់ថ្លៃ ISF ពួកគេយល់ថា គណៈកម្មការ សកបទ ត្រូវទទួលខុសត្រូវបែងចែកទឹកឲ្យបានគ្រប់គ្រាន់ទៅដល់ដីស្រែរបស់ពួកគេ គឺមានទាំងការគ្រប់គ្រងប្រឡាយរងទី៣ និងហេដ្ឋារចនាសម្ព័ន្ធដោះទឹកផង។ ផ្ទុយទៅវិញ គណៈកម្មការ សកបទ មានអារម្មណ៍ថា តួនាទីរបស់ខ្លួន មិនមែនត្រូវគិតពីបញ្ហាទឹកក្នុងដីស្រែនីមួយៗនោះទេ ប៉ុន្តែត្រូវយកចិត្តទុកដាក់លើការបែងចែកទឹកនៅក្នុងប្លុកទាំងមូល[១៩] និងគ្រប់គ្រងលើ O&M នៃប្រឡាយរងទី២ និងហេដ្ឋារចនាសម្ព័ន្ធធំៗផ្សេងទៀត ដូចជា ផ្លូវថ្នល់ និងសំណង់ធំៗ។ ការយល់ឃើញខុសគ្នានេះ បានបង្កបញ្ហាពិបាកដោះស្រាយខាងការបែងចែកទឹក។ ទោះយ៉ាងនេះក្ដី គណៈកម្មការ សកបទ បានព្យាយាមជំរុញឲ្យកសិករចូលរួម និងសហការជាមួយពួកគេដើម្បីដោះស្រាយបញ្ហា។

វិធីសម្រេចឲ្យបានតម្លាភាពផ្នែកហិរញ្ញវត្ថុ និងសិទ្ធិអំណាចរបស់ សកបទ លើការចំណាយផ្សេងៗ វាប្រែប្រួលខុសគ្នាទៅតាមប្រព័ន្ធជាករណីសិក្សា។ នៅក្នុងប្រព័ន្ធរលួស គណៈកម្មការ សកបទ មិនមានអំណាចសម្រេចអារកាត់ទេ ហើយការចំណាយទាំងអស់ត្រូវមានការយល់ព្រមពី ក្រយ។ ផ្ទុយទៅវិញ នៅប្រព័ន្ធស្ទឹងជីនិត គណៈកម្មការ សកបទ មានសិទ្ធិពេញលេញលើការចំណាយ ប៉ុន្តែ ត្រូវរាយការណ៍ទៅកសិករនៅក្នុងកិច្ចប្រជុំជាទៀងទាត់ (ធ្វើឡើងម្ដង ឬពីរដងក្នុងមួយឆ្នាំ) ថា បានចំណាយអស់ប្រាក់ប៉ុន្មាន និងទៅលើអ្វីខ្លះ។ ព័ត៌មាននេះ មិនអាចរកបានពីប្រព័ន្ធដំណាក់អំពិលទេ ព្រោះនៅទីនោះពុំមានប្រមូល ISF ។

ដើម្បីមានប្រាក់សម្រាប់ធានាដល់ការថែទាំប្រព័ន្ធឲ្យមានចីរភាព គណៈកម្មការ សកបទ នៃប្រព័ន្ធស្ទឹងជីនិត បានបង្កើតយុទ្ធសាស្ត្រ ISF មួយតាមការណែនាំ និងមតិពី MOWRAM និងម្ចាស់ជំនួយពីខាងក្រៅ ជាពិសេស ADB និង AFD។ ផ្អែកលើបទសម្ភាសន៍ជាមួយ គណៈកម្មការ សកបទ នៃប្រព័ន្ធស្ទឹងជីនិត បរិមាណ ISF ប្រមូលបានពីកសិករ មិនទាន់គ្រប់សម្រាប់ចំណាយលើថ្លៃ O&M កាលពីឆ្នាំមុនទេ គឺបានប្រហែល ៧០% នៃចំណាយទាំងអស់ប៉ុណ្ណោះ ហើយ ៣០% ដែលនៅសល់នោះ គឺជាការរួមចំណែករបស់រដ្ឋាភិបាល និង AFD តាមរយៈ ក្រុមស្រាវជ្រាវ និងផ្លាស់ប្ដូរបច្ចេកទេស (Group d'Échange et de Recherche Technologique: ហ្គ្រេត) ព្រមទាំងមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក)។ បច្ចុប្បន្ន ជំនួយហិរញ្ញវត្ថុពី AFD តាមរយៈ ហ្គ្រេត និង សេដាក បានបញ្ចប់ ដូច្នេះគេចាំបាច់ត្រូវបង្កើន ISF ដើម្បីដោះស្រាយចំណាយផ្សេងៗប្រចាំខែ។ យុទ្ធសាស្ត្រ ISF បានរៀបចំឡើងដើម្បីឲ្យការងារថែទាំប្រព័ន្ធមានចីរភាព បន្ទាប់ពីការគាំទ្រពីខាងក្រៅត្រូវចប់អស់ ប៉ុន្តែមានកសិករមួយចំនួនបានលើកថា ផែនការនេះប្រហែលមិនអាចទៅរួចទេ (សូមមើលផ្នែកបន្ទាប់ ស្ដីពីការចូលរួម)។ ក្នុងប្រព័ន្ធរលួស គណៈកម្មការ សកបទ អាចប្រមូលវិភាគទានជា ISF បានខ្លះ ប៉ុន្តែដោយសារកសិករនៅតំបន់ភាគខាងត្បូងនៃគម្រោងខ្វះទំនុកចិត្តលើគណៈកម្មការ ដូច្នេះមានតែកសិករមួយភាគតូចប៉ុណ្ណោះ (៣០% នៃគ្រួសារសរុបនៅក្នុងប្រព័ន្ធ) ដែលយល់ព្រមរួមចំណែក។ កង្វះការរួមចំណែកបង់ ISF ក្នុងប្រព័ន្ធធារាសាស្ត្រ ដំណាក់អំពិល បណ្ដាលមួយផ្នែកមកពី ប្រឡាយមេមិនទាន់បានស្ដារឡើងវិញទាំងស្រុង ធ្វើឲ្យប្រព័ន្ធនេះមិនអាចផ្ដល់សេវាស្រោចស្រពបានគ្រប់គ្រាន់ដល់កសិករ។

[១៩] នៅប្រព័ន្ធស្ទឹងជីនិត មានប្រហែល ៤៨ប្លុក ដែលមានទំហំប្រមាណ ៥០-១០០ហិកតា

### *៥.២.៣ សមត្ថភាពគណៈកម្មាធិការ សកបទ៖ ធនធាន និងបញ្ហាប្រឈម*

ធនធានមនុស្ស និងសមត្ថភាពផ្នែកបច្ចេសទេសនិងផ្នែកហិរញ្ញវត្ថុ មានទំនាក់ទំនងគ្នាជិតស្និទ្ធ និងសំខាន់សម្រាប់គណៈកម្មការ សកបទ ក្នុងការបំពេញមុខងារគ្រប់គ្រងរបស់ខ្លួន។ កម្រិតសមត្ថភាពប្រែប្រួលខ្លាំងទៅតាមប្រព័ន្ធធារាសាស្រ្តជាករណីសិក្សាផ្សេងៗគ្នា ដោយសារជាសំខាន់ កម្រិតយន្តការគាំទ្រដល់គណៈកម្មការ សកបទ នៅក្នុងប្រព័ន្ធនីមួយៗ។ ការលៃចែកទឹក ជាតួនាទីដ៏សំខាន់មួយរបស់គណៈកម្មការ សកបទ ប៉ុន្តែជាក់ស្តែង តួនាទីនេះមិនអាចអនុវត្តបានពេញលេញទេ ដោយសារប្រព័ន្ធធារាសាស្រ្តទាំងនោះគ្របដណ្តប់លើផ្ទៃដីធំធេងពេក។ គណៈកម្មការ សកបទ បានឲ្យដឹងថាពួកគាត់មិនមានធនធានមនុស្ស និងសមត្ថភាពផ្នែកបច្ចេកទេសនិងផ្នែកហិរញ្ញវត្ថុ សម្រាប់ដោះស្រាយបញ្ហាទាំងនេះទេ។ កកបទ គួរមានតួនាទីគាំទ្រមុខងាររបស់ សកបទ ប៉ុន្តែពួកគេហាក់មានតែឈ្មោះប៉ុណ្ណោះ ដោយមិនបានផ្តល់ការគាំទ្រអ្វីជាសំខាន់ទៅឲ្យគណៈកម្មការ សកបទ ក្នុងការបែងចែកទឹក ឬដោះស្រាយជម្លោះនោះទេ។

PDOWRAM ដើរតួនាទីសំខាន់នៅតាមប្រព័ន្ធនីមួយៗ ក្នុងការបង្កើនសមត្ថភាពផ្នែកបច្ចេសទេស និងផ្នែកហិរញ្ញវត្ថុ ទៅឲ្យ សកបទ។ ច្បាស់ណាស់ ការសម្របសម្រួលរវាង សកបទ និង PDOWRAM សំខាន់ជាខ្លាំងសម្រាប់កសាងសមត្ថភាពបច្ចេសទេសរបស់សមាជិក សកបទ ទាក់ទិននឹងការបែងចែកទឹក និងថែទាំប្រព័ន្ធ។ ទោះបីមានការលើកឡើងពីបញ្ហាមួយចំនួន នៅក្នុងប្រព័ន្ធដំណាក់អំពិលក្តី ក៏ជារួម កសិករមានអារម្មណ៍ថា ការបែងចែកទឹកមានការគ្រប់គ្រងរលូនល្អ។ ចំណុចនេះបង្ហាញពី សមត្ថភាពបច្ចេកទេសក្នុង សកបទ នៅប្រព័ន្ធដំណាក់អំពិល។ ទោះយ៉ាងនេះក្តី PDOWRAM បានឲ្យដឹងថា ការបណ្តុះបណ្តាល និងជំនួយគ្រាំទ្រដទៃទៀតដែលខ្លួនបានផ្តល់ឲ្យគណៈកម្មការ សកបទ មិនបានអភិវឌ្ឍសមត្ថភាពរបស់ពួកគេឲ្យប្រតិបត្តិការបានដោយឯករាជ្យ ទៅតាមបំណងរបស់ PDOWRAM ដែលចង់បាននោះឡើយ។

ទស្សនៈរបស់កសិករ ចំពោះសមត្ថភាពបច្ចេកទេសនៃគណៈកម្មការ សកបទ របស់ខ្លួន តែងរងឥទ្ធិពលពីកំហិតផ្នែកហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធធារាស្រ្តដែលត្រូវផ្សារភ្ជាប់ទៅនឹងសមត្ថភាពផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍ ខ្វះខាតថវិកាមានន័យថា ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ)។ សំណង់លូបង្ហូរទឹកមានទំហំតូចពេក ឬចាស់ទ្រុឌទ្រោម និងកង្វះប្រឡាយរងទី២ និងទី៣ ក្នុងប្រព័ន្ធរលួស ធ្វើឲ្យការបែងចែកទឹកលំបាកគ្រប់គ្រងជាខ្លាំង ជាពិសេសនៅតំបន់និរតីនៃប្រព័ន្ធនេះ។ សកបទ ក្នុងប្រព័ន្ធរលួស បានទទួលស្គាល់ថា បញ្ហាគ្រប់គ្រងទឹកក្នុងប្រព័ន្ធនេះ លំបាកស្មុគស្មាញ ហើយប្រាក់ប្រមូលបានពីការចូលរួមក្នុង ISF មិនគ្រប់គ្រាន់សម្រាប់ចំណាយលើការជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងប្រព័ន្ធទេ។

សមត្ថភាពហិរញ្ញវត្ថុ ជាបញ្ហាចោទធ្ងន់ធ្ងរមួយក្នុងប្រព័ន្ធបានចុះសិក្សាទាំងបី។ ប្រព័ន្ធទាំងនេះ ត្រូវការហេដ្ឋារចនាសម្ព័ន្ធធារាសាស្រ្តថ្មី ឬការជួសជុល និងថែទាំសំណង់ដែលមានស្រាប់។ ក្នុងប្រព័ន្ធរលួស ISF ប្រមូលបានជាមធ្យមមានតិចជាង ៥០០ដុល្លារ (២លានរៀល) ក្នុងមួយឆ្នាំ។ ប្រហែល ៣% នៃប្រាក់នេះ ត្រូវទុកចំណាយលើការប្រជុំ និងទិញប៊ិច ក្រដាស និងសម្ភារៈដទៃទៀត សម្រាប់គណៈកម្មការ សកបទ ហើយប្រាក់នៅសល់ត្រូវប្រើសម្រាប់ O&M។ ទឹកប្រាក់នេះតាមធម្មតាគ្រប់គ្រាន់សម្រាប់តែការកែលំអតូចតាចលើប្រឡាយមេប៉ុណ្ណោះ។ ក្នុងឆ្នាំ២០០៨ សកបទ ទទួលបានទឹកប្រាក់ ១៧៥០ដុល្លារ (៧លានរៀល) សម្រាប់ O&M ពី ក្រុយ ដែលថ្មីៗនេះបានលក់សិទ្ធិប្រើប្រាស់ ព្រៃកស្បូវ ទៅឲ្យអាជីវកររឯកជន សម្រាប់ដំណើរការជាឡូត៍នេសាទ។ ថវិកានេះគ្រប់គ្រាន់សម្រាប់ជួសជុលប្រឡាយមេប្រវែង ២០០-៤០០ម៉ែត្រ នៅប៉ែកខាងជើងនៃប្រព័ន្ធប៉ុណ្ណោះ។

បញ្ហាចម្បងពីរដូចបានលើកឡើងខាងលើ មិនអាចដោះស្រាយបានទេ ព្រោះខ្វះមូលនិធិ។ កសិករក្នុងប្រព័ន្ធរលួស ដែលមានស្រែនៅជុំវិញ បឹងលៀស ចង់កសាងប្រឡាយមួយភ្ជាប់ស្ទឹងសែន និងបឹងលៀស ដើម្បីឲ្យបឹងមានទឹកនៅរដូវប្រាំង។ ប្រឡាយនេះអាចឲ្យពួកគាត់ដាំដំណាំនៅរដូវប្រាំងបានដោយមិនបាច់បង់ប្រាក់សេវាកម្មទឹកប្រចាំឆ្នាំ ដែលកសិករនៅទីនោះជាច្រើននាក់ពុំមានលទ្ធភាពបង់ទៅឲ្យក្រុមហ៊ុនឯកជនសម្រាប់ការប្រើប្រាស់ប្រឡាយមេ។ កសិករដែលមានប្រាក់ ពេញចិត្តចូលរួមចំណាយតែម្តងត្រឹម ៥០-១០០ដុល្លារ ដើម្បីឲ្យ សកបទ កសាងប្រឡាយនេះ ជាជាង

បង់ប្រាក់សេវាកម្មទឹកទៅឲ្យក្រុមហ៊ុនឯកជន។ ដោយទទួលទិន្នផលបានទាប ប្រមូលផលបានតិចក្នុងពីរឆ្នាំកន្លងមក ដូច្នេះកសិករមួយចំនួនមិនអាចបង់ប្រាក់នេះបាន ហើយការកសាងប្រឡាយក៏មិនអាចធ្វើទៅកើត។ កសិករក្នុងប្រព័ន្ធរលួស ត្រូវខូចខាតផលស្រូវវស្សាជារៀងរាល់ឆ្នាំ ដោយសារតែកសិករនៅខ្សែទឹកខាងលើ និងម្ចាស់ឡូត៍នេសាទ បានទប់ទឹកទុកសម្រាប់បំពេញតាមតម្រូវការរបស់ពួកគេ។ កសិករក្នុងប្រព័ន្ធរលួសនិយាយថា ពួកគេចង់ស្តារប្រព័ន្ធប្រឡាយឡើងវិញ (កសាងដំបូងក្នុងឆ្នាំ១៩៧៥-១៩៧៩) ឬចង់កសាងទំនប់ទឹក ព្រមទាំងប្រព័ន្ធដោះទឹកនៅវាំងដីតាមថ្នាក់ផ្សេងៗគ្នា (ចែកជាថ្នាក់ទាប កណ្តាល និងខ្ពស់) ដើម្បីការពារដំណាំរបស់ខ្លួន។ មធ្យោបាយនេះ ក៏ជួយឲ្យកសិករនៅជិតភូមិរលួសអាចបញ្ចេញទឹកបានតាមពេល និងតាមបរិមាណដែលគាត់ត្រូវការដោយគ្មានប៉ះពាល់ដល់ដំណាំដាំដុះនៅតំបន់ខ្សែទឹកខាងលើ (សូមមើលផែនទីតំបន់ធារាសាស្ត្ររលួស ក្នុងជំពូក៤)។ ប៉ុន្តែគម្រោងសម្រាប់បែងចែកទឹកក្នុងតំបន់ធារាសាស្ត្រឲ្យបានកាន់តែប្រសើរនេះ ក៏មិនទាន់បានអនុវត្តដែរ ដោយសារកង្វះសមត្ថភាពហិរញ្ញវត្ថុ។

នៅតំបន់ធារាសាស្ត្រស្ទឹងជីនិត ក្រសួងធនធានទឹកនិងឧតុនិយម មន្ទីរធនធានទឹកនិងឧតុនិយម ម្ចាស់ជំនួយពីខាងក្រៅ និងអង្គការផ្តល់ប្រឹក្សានានា បានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេសទេស និងផ្នែកហិរញ្ញវត្ថុ (ជំនួយហិរញ្ញវត្ថុបានបញ្ចប់ក្នុងខែមិថុនា ២០០៩)។ ជំនួយទ្រទ្រង់នេះ បានបង្កើនសមត្ថភាពបច្ចេកទេសរបស់គណៈកម្មការ សកបទ ក្នុងការគ្រប់គ្រងការបែងចែកទឹក និងបានផ្តល់ថវិកាសម្រាប់គាំទ្រដល់មុខងាររបស់គណៈកម្មការ ព្រមទាំងដោះស្រាយចំណាយ O&M នៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រផងដែរ។ កម្មវិធីជួយទ្រទ្រង់នេះ បានរចនារៀបចំឡើងដើម្បីកាត់ផ្តាច់ជាបណ្តើរៗពីមួយឆ្នាំទៅមួយឆ្នាំនូវការពឹងផ្អែកលើជំនួយហិរញ្ញវត្ថុរហូតដល់ចុងបញ្ចប់នៃគម្រោង។ សកបទ បានគន់គូរថា កសិករម្នាក់ៗត្រូវបង់ប្រាក់ ១៥ដុល្លារ (៦ម៉ឺនរៀល) ក្នុងមួយឆ្នាំសម្រាប់ដោះស្រាយចំណាយ O&M។ ឥឡូវនេះ ជំនួយពីក្រៅបានចប់អស់ ក៏មានការព្រួយបារម្ភជាខ្លាំងពីការរក្សាឲ្យមានថវិកាសម្រាប់ចំណាយរដ្ឋបាល និង O&M ប្រចាំខែ។ ក្នុងអំឡុងពេលសិក្សា ISF ដែលប្រមូលបាន អាចដោះស្រាយបានត្រឹម ៦០-៧០% នៃចំណាយ O&M ប៉ុណ្ណោះ ហើយកសិករមួយចំនួនបានប្រាប់ថា ពួកគាត់លំបាកណាស់ទៅហើយក្នុងការបង់ប្រាក់ប៉ុណ្ណេះ និងមិនអាចបង់លើសពីនេះទេ។ PDOWRAM ខេត្តកំពង់ធំ បានបញ្ជាក់ថា ស្ថានភាពដូច្នេះមិនមែនមានតែមួយនេះទេ ព្រោះគណៈកម្មការ សកបទ ជាច្រើនក្នុងខេត្តកំពង់ធំ បានដួលរលំ ឬដំណើរការមិនល្អ ដោយសារតែកង្វះ ឬការបញ្ចប់ជំនួយបច្ចេសទេស និងហិរញ្ញវត្ថុ ពីទីភ្នាក់ងារផ្សេងៗ។

## ៥.៣ ការចូលរួម

### *៥.៣.១ ការរួមចំណែករបស់កសិករក្នុងការបង់ថ្លៃសេវាកម្មធារាសាស្ត្រ (ISF)*

ដំណើរការរយៈពេលវែងនៃ សកបទ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ត្រូវពឹងអាស្រ័យលើប្រភពហិរញ្ញវត្ថុជាច្រើន ហើយសំខាន់បំផុតគឺ ISF។ ប្រព័ន្ធជាច្រើនប្រហែលគ្នានឹង ISF នេះបានទទួលជោគជ័យក្នុងតំបន់ផ្សេងៗលើពិភពលោក ប៉ុន្តែមានបញ្ហាធំៗពីរបានផុសឡើងក្នុងបរិបទប្រទេសកម្ពុជា។ ទី១ កសិករជាច្រើនរាយការណ៍ថា មិនមានលទ្ធភាពបង់ប្រាក់ ISF ទេ និង ទី២ កសិករមកពីប្រព័ន្ធដំណាក់អំពិលបានអះអាងថា តាំងពីដើមរៀងមកប្រជាជនកម្ពុជាមិនដែលត្រូវបង់ថ្លៃទឹកសម្រាប់ដំណាំស្រូវនោះទេ ហើយពួកគាត់ជឿថា គាត់អាចមានទឹកគ្រប់គ្រាន់ពីភ្លៀងដោយមិនចាំបាច់ត្រូវចំណាយលើ ISF។ កសិករបង្ហាញអារម្មណ៍រួមគ្នាមួយក្នុងប្រព័ន្ធបានសិក្សាទាំងបី៖ គាត់មិនចង់បង់ថ្លៃ ISF ទេ បើសិនមិនបានទទួលផលប្រយោជន៍ដោយផ្ទាល់ពីប្រព័ន្ធធារាសាស្ត្រ។ កសិករក្នុងប្រព័ន្ធនីមួយៗ មានបទពិសោធន៍ខុសៗគ្នាក្នុងបញ្ហា ISF និងផ្តល់ហេតុផលខុសៗគ្នាលើការយល់ព្រម ឬមិនព្រមបង់ប្រាក់នេះ។ គ្មានកសិករណាម្នាក់ក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងមានកសិករតែ ៣០% ក្នុងប្រព័ន្ធរលួសប៉ុណ្ណោះ ដែលបានបង់ថ្លៃ ISF ប៉ុន្តែមានកសិករជិត ១០០% ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិតបានបង់ថ្លៃ ISF ទៅឲ្យ សកបទ។

ទោះបីគ្មានកសិករណាម្នាក់ក្នុងប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល បានបង់ថ្លៃ ISF ក្នុងអំឡុងពេលសិក្សាក្តី ក៏ MOWRAM ឆ្លងតាមការពិគ្រោះយោបល់ជាមួយកសិករ បានសម្រេចយកស្រូវ (១៤០គ.ក ក្នុងមួយហិកតាក្នុងមួយឆ្នាំ) ជំនួសសាច់ប្រាក់សម្រាប់ថ្លៃ ISF។ បរិមាណស្រូវដែលស្នើឡើង ជំនួសថ្លៃ ISF គឺ ១០០គ.ក/ហិកតា សម្រាប់ដំណាំស្រោចស្រពតាមកម្លាំងទឹកហូរចុះដោយធម្មជាតិ (gravity-fed irrigation) និងបន្ថយមកត្រឹម ៦០គ.ក/ហិកតា សម្រាប់ដំណាំស្រោចស្រពដោយប្រើម៉ាស៊ីនបូម ដើម្បីជួយប៉ះប៉ូវលើថ្លៃប្រេង (Chem *et al.* 2010)។ គណៈកម្មការ សកបទ នៃប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល រាយការណ៍ថា កសិករអាចយល់ព្រមបង់ថ្លៃ ISF នៅពេលណាដែលប្រព័ន្ធនេះបង្ហាញច្បាស់ពីអត្ថប្រយោជន៍សម្រាប់ពួកគេ។ ដូច្នេះគណៈកម្មការជឿថា ប្រព័ន្ធធារាសាស្ត្រ ត្រូវកសាងឲ្យចប់សព្វគ្រប់ និងមានដំណើរការល្អ មុនពេលអាចម្ចាស់ការដោយខ្លួនឯងបាន និងមិនពឹងពាក់លើជំនួយហិរញ្ញវត្ថុពីអ្នកផ្តល់ជំនួយ។

ក្នុងប្រព័ន្ធរលួស កសិករភាគច្រើនដែលចូលរួមបង់ថ្លៃ ISF ជាអ្នករស់នៅជុំវិញបឹងលៀស និងទទួលផលប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្របច្ចុប្បន្ន។ ជាទូទៅ កសិករទាំងនេះបង់ប្រាក់១,២៥ដុល្លារ (៥ពាន់រៀល) ក្នុងមួយហិកតា/ឆ្នាំ ហើយកសិករខ្លះបង់ប្រាក់ដល់ ២,៥០ដុល្លារ (មួយម៉ឺនរៀល) ក្នុងមួយហិកតា/ឆ្នាំ។ កសិករមួយចំនួននៅទីនោះ ពេញចិត្តបង់ថ្លៃសេវាដល់ ១០០ដុល្លារ (បួនសែនរៀល) តែម្តងទៅឲ្យ សកបទ ដើម្បីកសាងប្រឡាយថ្មីមួយភ្ជាប់ ស្ទឹងសែន និងបឹងលៀស ជាជាងត្រូវបង់ថ្លៃដូចការលើកឡើងខាងលើ បូកបន្ថែមថ្លៃប្រេងសម្រាប់ម៉ាស៊ីនបូមទឹកក្នុងមួយឆ្នាំៗទៅឲ្យក្រុមហ៊ុនឯកជន ដើម្បីប្រើប្រាស់ប្រឡាយមេ។ ប៉ុន្តែក្នុងពីរ-បីឆ្នាំចុងក្រោយនេះ កសិករជាច្រើនមិនមានលទ្ធភាពបង់ថ្លៃសេវាកម្មមួយលើកនេះទេ ហើយសូម្បីតែថ្លៃសេវាកម្មធម្មតា ត្រឹម ១,២៥ដុល្លារ/ដីមួយហិកតា/ឆ្នាំ ក៏លំបាកដែរ ដោយសារប្រមូលផលមិនសូវបាន។ កសិករមកពីតំបន់ជុំវិញភូមិរលួស បានសង្កត់ធ្ងន់ថា ប្រសិនបើពួកគេមើលឃើញថា គណៈកម្មការ សកបទ ធ្វើការងារដើម្បីជួយកែលំអស្ថានភាពរបស់ពួកគេនោះ ពួកគេសុខចិត្តបង់ថ្លៃសេវាកម្មធារាសាស្ត្រ។ ប៉ុន្តែក្នុងពេលកំពុងធ្វើការសិក្សា គេឃើញមានការគាំទ្រតិចតួចណាស់ដល់ក្រុមកសិករនេះ។ ជាលទ្ធផល ការប្រមូលថ្លៃ ISF ក្នុងតំបន់ប្រព័ន្ធរលួស មិនបានជោគជ័យទេ។ កសិករដែលបានបង់ប្រាក់ ១០០ដុល្លារ ទៅឲ្យក្រុមហ៊ុនឯកជន ភាគច្រើនរស់នៅប៉ែកខាងលិចនៃប្រឡាយមេដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជន។ តំបន់នេះទទួលទឹកបានគ្រប់គ្រាន់ ទៀងទាត់ និងទាន់ពេលល្អពីប្រឡាយមេ ហើយកសិករតែងទទួលបានទិន្នផលច្រើនជារៀងរាល់ឆ្នាំ។ ក្រុមហ៊ុនឯកជនបានសន្យាជាមួយអតិថិជនថា ក្រុមហ៊ុននឹងសងពេញថ្លៃលើការខូចខាតផលដំណាំ ប្រសិនបើខ្លួនមិនបានផ្តល់ទឹកគ្រប់គ្រាន់សម្រាប់ការដាំដុះ។ ការសន្យានេះបានកាត់បន្ថយហានិភ័យយ៉ាងច្រើនចំពោះជីវភាពរបស់កសិករ។ ទោះបីសម្ភាសន៍ជាមួយកសិករក្នុងតំបន់នេះ មិនស្ថិតក្នុងដែនកំណត់នៃការស្រាវជ្រាវក្តី ក៏ព័ត៌មានខាងលើអាចឲ្យយើងសន្និដ្ឋានថា កសិករពេញចិត្តបង់ថ្លៃខ្ពស់ជាងលើសេវាកម្មផ្តល់ឲ្យដោយក្រុមហ៊ុនឯកជន ព្រោះកសិករទទួលបានសេវាស្រោចស្រពគួរឲ្យជឿជាក់ ព្រមទាំងការធានាសងការខូចខាតពីក្រុមហ៊ុនជាបន្ថែមលើការដែលកសិករទទួលបានប្រាក់ចំណូលកាន់តែច្រើន និងទៀងទាត់នោះទៀត។

ក្នុងប្រព័ន្ធស្ទឹងជីនិត សកបទ ប្រមូលថ្លៃ ISF ពីកសិករទាំងអស់ក្នុងប្រព័ន្ធ។ ក្នុងអំឡុងពេលសិក្សា ISF មានថ្លៃ ៦,២៥-៧,៥០ដុល្លារ (២៥ពាន់រៀល-៣០ពាន់រៀល) ក្នុងដីមួយហិកតាក្នុងមួយឆ្នាំ ហើយគ្រោងឡើងថ្លៃដល់ ១៥ដុល្លារ (៦ម៉ឺនរៀល) ក្នុងឆ្នាំ២០១៣ ដើម្បីអាចធានាដោះស្រាយចំណាយ O&M បាន ដោយមិនបាច់ពឹងផ្អែកអ្នកផ្តល់ជំនួយ។ កសិករក្នុងសហគមន៍តែងសម្តែងការព្រួយបារម្ភពីការឡើងថ្លៃ ISF នៅពេលដ៏ខ្លីខាងមុខ។ ក្នុងពេលសម្ភាសន៍ កសិករម្នាក់និយាយថា៖

> *...ខ្ញុំមិនយល់ស្របនឹងការឡើងថ្លៃសេវាកម្មប្រើប្រាស់ទឹកទេ។ ខ្ញុំបង់តែបីម៉ឺនរៀលក្នុងមួយឆ្នាំប៉ុណ្ណោះ។ ខ្ញុំចំណាយប្រហែល ពីរសែនរៀលក្នុងដីមួយហិកតា ទៅលើជី គ្រាប់ពូជ ពលកម្ម (ប្រាំបីពាន់រៀល/ថ្ងៃ) និងចំណាយចាំបាច់ផ្សេងៗទៀត ដូច្នេះខ្ញុំគ្មានលទ្ធភាពបង់ថែមទៀតទេ... (អ្នកភូមិស្រែតាកោរ ប្រព័ន្ធស្ទឹងជីនិត ឆ្នាំ២០១០)។*

ជាទូទៅមានការយល់ស្របថា សមត្ថភាពរបស់ប្រព័ន្ធស្ទឹងជីនិតក្នុងការរ៉ាប់រងចំណាយ O&M ក្រោយពេលបញ្ចប់ជំនួយពីខាងក្រៅ វាអាស្រ័យលើចំណុចថា តើកសិករអាចផ្លាស់ប្តូរពីការដាំដុះតែមួយលើក ទៅជា ពីរ ឬបីលើក ដែលមានន័យថា កសិករអាចមានលទ្ធភាពបង់ថ្លៃ ISF ខ្ពស់ជាងមុនបានដែរទេ។

*៥.៣.២ ការចូលរួមរបស់កសិករក្នុងការប្រជុំ និងការបោះឆ្នោត*

ការសម្ភាសជាមួយកសិករបានបង្ហាញច្បាស់ថា កសិករច្រើននាក់មានគំនិតអំពីវិធីដោះស្រាយបញ្ហាធារាសាស្ត្រ ប៉ុន្តែកសិករមួយចំនួនលំបាកនឹងទទួលបានចម្លើយតបពី ក្រុម គណៈកម្មការ សកបទ ឬអាជ្ញាធរមូលដ្ឋាន លើគំនិតទាំងនេះ ដោយសារ កង្វះមូលនិធិ ឬក៏ គណៈកម្មការ ឬថ្នាក់ដឹកនាំមូលដ្ឋាន មានរបៀបវារៈមួយផ្សេង។ ក្នុងករណីខ្លះទៀត កសិករមិនចង់ចូលរួមក្នុងសកម្មភាព សកបទ តែម្តង។

គណៈកម្មការ សកបទ ក្នុងប្រព័ន្ធរលួស មិនសូវអើពើនឹងសំណើរបស់កសិករមានដីនៅជិតភូមិរលួសទេ បើធៀបនឹងកសិករមានដីនៅជិតបឹងលៀស។ នៅពេលសាកសួរពីការចូលរួមក្នុងការបោះឆ្នោតជ្រើសរើស សកបទ កសិករមកពីតំបន់ជុំវិញរលួស និយាយថា គាត់រារែក ឬមិនចង់ចូលរួមតែម្តង ព្រោះមិនទុកចិត្តគណៈកម្មការ សកបទ និងមានអារម្មណ៍ថា គណៈកម្មការនឹងគ្មានជួយអ្វីដល់គាត់ទេ។ ទោះយ៉ាងនេះក្តី ការបោះឆ្នោតជ្រើសរើស សកបទ ក្នុងប្រព័ន្ធស្ទឹងជីនិត មានការចូលរួមច្រើនពីកសិករទាំង ២៥ភូមិ ក្នុងឃុំទាំងអស់នៅក្នុងតំបន់ស្រោចស្រព។ ទោះបីកសិករមួយចំនួនក្នុងប្រព័ន្ធដំណាក់អំពិល បានប្រាប់ថា គាត់នឹងបោះឆ្នោតឲ្យសមាជិក សកបទ បច្ចុប្បន្ន នៅពេលគេរៀបចំការបោះឆ្នោតក្តី ក៏ក្នុងពេលធ្វើការសិក្សានេះ ពួកគាត់មិនទាន់មានឱកាសបោះឆ្នោតនៅឡើយទេ។

ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការ សកបទ នៅប្រព័ន្ធស្ទឹងជីនិត មានការចូលរួមច្រើន ប៉ុន្តែការចូលរួមក្នុងកិច្ចសន្ទនាទាក់ទងនឹងធារាសាស្ត្រ មិនសូវមានច្រើនប៉ុន្មានទេ។ កសិករម្នាក់ រាយការណ៍ថា ប្រជាជនមិនចង់ចូលរួម ឬចូលស្តាប់សមាជិកគណៈកម្មការនេះទេ ព្រោះពួកគេយល់ថា គណៈកម្មការនេះជាក្រុមគ្មានសិទ្ធិអំណាច។

## ៥.៤ ការសម្របសម្រួលអ្នកពាក់ព័ន្ធ

*៥.៤.១ ការសម្របសម្រួលនៅមូលដ្ឋាន*

ការសម្របសម្រួល និងលំហូរព័ត៌មានរវាងអ្នកពាក់ពន្ធ័ទាំងអស់ ពីថ្នាក់មូលដ្ឋានទៅថ្នាក់ជាតិ សំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្ត PIMD ប៉ុន្តែការសម្ភាស និងការសង្កេតដល់កន្លែង បង្ហាញពីដំណើការមិនទាន់រលូនគ្នាល្អនៅក្នុង និងរវាងក្រុមអ្នកពាក់ព័ន្ធនៅក្នុងប្រព័ន្ធសិក្សាទាំងបី។ ម្យ៉ាងទៀត ជម្លោះផុសចេញពីកង្វះទឹក កង្វះភាពជឿជាក់ និងការបែងចែកទឹកមិនស្មើគ្នា តែងកើតមានជារឿយៗក្នុងប្រព័ន្ធនីមួយៗ។

តាមទ្រឹស្តី សកបទ ត្រូវផ្ទេរអំណាចគ្រប់គ្រងប្រឡាយរងទី៣ (នៅចន្លោះស្រែ) ទៅឲ្យ កកបទ។ គេបានបង្កើត កកបទរួចហើយ (ឧទាហរណ៍ នៅរលួស) ប៉ុន្តែក្រុមនេះនៅមានតួនាទីតិចតួចណាស់ ហើយក្រៅពីការប្រាស្រ័យទាក់ទងខ្លះៗនៅក្នុងក្រុម គឺមិនសូវមាន ឬក៏គ្មានទំនាក់ទំនងពីក្រុមមួយទៅក្រុមមួយទេ។ នៅស្ទឹងជីនីត គណៈកម្មការ សកបទ បានរៀបចំការប្រជុំដាច់ដោយឡែកពីគ្នានៅភូមិនីមួយៗក្នុងប្រព័ន្ធ ដើម្បីពិភាក្សាជាមួយកសិករពីបញ្ហាទាក់ទងនឹងទឹក។ អ្នកដឹកនាំ សកបទ នៅស្ទឹងជីនិត ប្រាប់ថា សម្រាប់ភូមិនីមួយៗគេរំពឹងថា មានប្រជាជនពី ៣០ ទៅ ៥០នាក់ មកចូលរួមការប្រជុំ ប៉ុន្តែជួនកាលក៏មិនបានប៉ុណ្ណេះដែរ។ អ្នកភូមិប្រាសាទម្នាក់ប្រាប់ថា មានកសិករត្រឹម ១០ ទៅ ៣០នាក់ប៉ុណ្ណោះ មកចូលរួមក្នុងការប្រជុំសម្រាប់ភូមិគាត់ គឺមិនតំណាងឲ្យកសិករទាំងអស់ក្នុងភូមិទេ។ ជារួម មានការលើកឡើងថា ប្រហែល ៥០ ទៅ ៦០% នៃចំនួនកសិករទាំងអស់ក្នុងប្រព័ន្ធ បានចូលរួមក្នុងការប្រជុំទាំងនេះ។

ការសម្របសម្រួលកសិកររៀបចំឡើងដោយកសិករខ្លួនឯង គេឃើញមាននៅរលួស ដោយកសិករក្រុមតូចៗ ដែលមានស្រែនៅជិតៗគ្នា បានចូលលុយគ្នាបង់ថ្លៃប្រេងបូមទឹកស្រោចស្រព។ ប៉ុន្តែ ការសម្របសម្រួលក្នុងមូលដ្ឋាននេះ

កើតមានតែនៅតាមដីស្រែស្ថិតនៅជិតប្រឡាយមេនៅភាគខាងលិចប៉ុណ្ណោះ។ សម្រាប់កន្លែងផ្សេងៗទៀតក្នុងប្រព័ន្ធ កសិករបានជួបបញ្ហាខាងការសម្របសម្រួល ស្រដៀងគ្នានឹងកសិករក្នុងប្រព័ន្ធធារាសាស្ត្រឯទៀតដែរ ដែលជារឿយៗ ជាប់ទាក់ទងនឹងការប្រើជីហួសកម្រិតអាចបង្កការខូចខាតដល់ស្រូវនៅខ្សែទឹកខាងក្រោម និងការកាត់ផ្តាច់ទំនប់ដោយ មិនបានពិគ្រោះជាមួយកសិករនៅជិតខាងគ្នា។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ចាំបាច់ខ្លាំងណាស់សម្រាប់ការបែងចែកទឹកឲ្យទាន់ពេល និងមានប្រសិទ្ធភាព ប៉ុន្តែ ត្រូវមានការប្តេជ្ញាចិត្តខ្ពស់ និងការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។ ជារឿយៗកង្វះកិច្ចសហប្រតិបត្តិការ និងការប្តេជ្ញាចិត្ត ពីកសិករ ជាឧបសគ្គចម្បងមួយរារាំងដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រព័ន្ធ។ នៅប្រព័ន្ធដំណាក់អំពិល កសិករ បានឆ្លើយសម្ភាសន៍ប្រាប់ថា កសិករភាគច្រើនចង់ឲ្យមានការកសាងថ្មី ឬការស្តារជួសជុលនូវប្រឡាយរងទី៣ ដែលបាន កសាងឡើងតាំងពីពាក់កណ្តាលទសវត្សរ៍១៩៧០។ ប៉ុន្តែកសិករអ្នកមានដីស្រែតូចៗបានជំទាស់នឹងការសាងប្រឡាយ ព្រោះគាត់ត្រូវលះបង់ដីស្រែដ៏តូចស្រាប់អស់មួយចំណែកថែមទៀត ដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ប្រាក់ចំណូល និង ជីវភាពរស់នៅរបស់គាត់។

> *...ខ្ញុំមានតែដីស្រែដ៏តូចមួយប្រហែល ៣០ម៉ែត្រការ៉េប៉ុណ្ណោះ។ ខ្ញុំរស់នៅតែម្នាក់ឯង ហើយខ្ញុំត្រូវជួលវា ដើម្បីបានប្រាក់ខ្លះគ្រាន់ទិញរបស់របរទៅវត្ត។ ប្រសិនបើគេកសាងប្រឡាយនេះ វាត្រូវកាត់ចំកណ្តាលដីស្រែខ្ញុំ ខ្ញុំនឹងត្រូវបាត់បង់ដី ដូច្នេះខ្ញុំមិនយល់ព្រមចូលរួមវិភាគទានជាដីស្រែទេ... (អ្នកភូមិខ្នារ ក្នុងប្រព័ន្ធដំណាក់អំពិល ឆ្នាំ២០១០)។*

កសិករជាច្រើននាក់នៅតាមប្រព័ន្ធធារាសាស្ត្រដែលបានសិក្សា បានឆ្លើយសម្ភាសន៍ប្រាប់ថា គាត់ពេញចិត្តចូល រួមជាប្រាក់កាស និងធ្វើសហប្រតិបត្តិការក្នុងប្រព័ន្ធដែលអាចផ្តល់ប្រយោជន៍ឲ្យគាត់បានឆាប់រហ័ស និងមិនបង្កហានិភ័យ បន្ថែមទៀតដល់ជីវភាពរបស់គាត់។

ប្រធាន PDOWRAM ខេត្តពោធិ៍សាត់ បានបញ្ជាក់ថា លក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់ការគ្រប់គ្រង និងបែង ចែកទឹកប្រកបដោយជោគជ័យរបស់គណៈកម្មការ សកបទ រួមមាន សមត្ថភាពបច្ចេកទេស ការសម្របសម្រួល និង ការប្រាស្រ័យទាក់ទង/ផ្តល់ព័ត៌មានបានល្អ រវាង PDOWRAM គណៈកម្មការ សកបទ កសិករនៅមូលដ្ឋាន និង អ្នកភូមិ។ គណៈកម្មការ សកបទ ក៏ត្រូវដឹងពី៖ ១) តម្រូវការទឹកស្រោចស្រពក្នុងអំឡុងពេលកូនរដូវប្រាំងក្នុងរដូវវស្សា ២) ពេលណា និងកន្លែងណាអាចខ្វះទឹកនៅរដូវប្រាំង និង ៣) លទ្ធភាពអាចខ្វះទឹកនៅដើម និងនៅចុងរដូវវស្សា។ មន្ត្រី PDOWRAM បានគូសបញ្ជាក់ថា ការយល់ដឹងនេះ ត្រូវមានគួបផ្សំដោយសមត្ថភាពធ្វើផែនការ លៃចែកទឹក ឬស្តុកទឹក តាមតម្រូវការដោយខ្លួនពួកគេ (ពោលគឺ ដោយមិនបាច់មានការណែនាំពី PDOWRAM)។ គណៈកម្មការ សកបទ ក៏ត្រូវតែអាចធានាថា សមាជិករបស់ខ្លួន និងកសិករ បានយល់ដឹងល្អពីបញ្ហាទាំងនេះ និងមានចំណេះដឹងសមស្របផ្នែក កសិកម្ម ។

ជម្លោះ ឬបញ្ហាក្នុងការសម្រួបសម្រួលនៅមូលដ្ឋាន ឃើញកើតមានឡើងនៅពីរកម្រិត ក្នុងប្រព័ន្ធដែលបាន សិក្សាទាំងបី គឺ៖ ១) រវាងកសិករមានដីស្រែនៅជិតខាងគ្នា និង ២) រវាងកសិករនៅតំបន់ខាងលើ និងតំបន់ខាងក្រោម នៃប្រព័ន្ធតែមួយ។ នៅកម្រិតមូលដ្ឋាន ការសម្របសម្រួល និងសហប្រត្តិការរវាងកសិករ ជារឿយៗជួបការលំបាក ដោយសារកសិករដែលមានដីស្រែនៅជិតៗគ្នា ច្រើនតែមកពីភូមិឆ្ងាយៗពីគ្នា។ តាមការសង្កេត និងរបាយការណ៍ គេយល់ថា ស្ថានភាពនេះធ្វើឲ្យ កសិករពិបាកក្នុងការកសាងភាពស្និទ្ធស្នាល និងទំនុកចិត្តគ្នាទៅវិញទៅមក ដើម្បីអាច ដោះស្រាយបញ្ហាផ្សេងៗទាក់ទិននឹងដីស្រែបានដោយមិត្តភាព។ ក្នុងប្រព័ន្ធដំណាក់អំពិល និងស្ទឹងជីនិត ជម្លោះទាក់ ទងនឹងភ្លឺស្រែបាក់បែករវាងដីស្រែជិតខាងគ្នា ច្រើនកើតមាននៅពេលដែលកសិករឲ្យគោក្របីដើរជាន់លើភ្លឺ ដើម្បី ដឹកជញ្ជូនស្រូវ ឬបើកបង្ហូរទឹកចូលស្រែរបស់ខ្លួនហើយមិនបានជួសជុលភ្លឺវិញ[២០]។ សកម្មភាពនេះបង្កជាជម្លោះ ដោយ

---

[២០] សម្ភាសន៍ជាមួយអ្នកភូមិត្បែង ឆ្នាំ២០១០។

សារជនរងគ្រោះត្រូវអស់ទឹកពីស្រែរបស់ខ្លួនជាមួយគ្នានឹងជី និងថ្នាំសម្លាប់សត្វចង្រៃដែលខ្លួនបានចំណាយលុយទិញ និងខំប្រឹងយកវាមកដាក់ស្រែ ហើយនៅចុងបញ្ចប់ ទាំងទិន្នផលស្រូវ និងជីវភាព ក៏ត្រូវធ្លាក់ចុះ។

មន្ទីរកសិកម្ម (PDAFF) ខេត្តកំពង់ធំ បានកត់សម្គាល់ថា នៅពេលកំពុងធ្វើការសិក្សានេះ កសិករមួយចំនួនក្នុងប្រព័ន្ធស្ទឹងជីនិត មិនបានយកចិត្តទុកដាក់ថែទាំដំណាំខ្លួនគ្រប់គ្រាន់ទេ។ ក្រោយពេលសាបព្រោះរួច ពួកគេទុកស្រែចោល ទៅរកការងារផ្សេងធ្វើវិញ រហូតដល់ពេលប្រមូលផល។ ជារឿយៗ កសិករដែលមានស្រែនៅជិតខាង បានកាត់ភ្លឺស្រែរបស់កសិករអវត្តមានទាំងនោះ ដើម្បីយកទឹកបញ្ចូលមកក្នុងស្រែរបស់ខ្លួន។ ក្នុងពេលសម្ភាសន៍ កសិករម្នាក់និយាយថា៖

> *...ខ្ញុំធ្លាប់កាត់ភ្លឺ និងលួចយកទឹក ពីអ្នកភូមិស្រែតាកោរ។ ទឹកនោះអាចប្រើប្រាស់សម្រាប់ស្រោចស្រពដីស្រែមួយចំនួន។ ពួកយើងធ្វើដូច្នេះ ព្រោះអ្នកភូមិស្រែតាកោរអាចទទួលបានទឹកច្រើនពីប្រឡាយដោះទឹក (អ្នកភូមិសង្គ្រោះ ក្នុងប្រព័ន្ធស្ទឹងជីនិត ឆ្នាំ២០១០)។*

ស្ថានការណ៍នៅរលួស បង្ហាញពីការតស៊ូសម្របសម្រួល និងជម្លោះផុសចេញពីការបែងចែកទឹក នៅកម្រិតអនុគម្រោង រវាងអ្នកប្រើប្រាស់ទឹកនៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ដែលមានតម្រូវការទឹកខុសៗគ្នា។ បញ្ហាបរិស្ថាន រួមមាន ទឹកជន់លិចជារៀងរាល់ឆ្នាំនៅតំបន់រលួស និងស្រយ៉ូវ ដែលចាប់ផ្តើមកើតមានបន្ទាប់ពីការជុសជុលទំនប់ធារាសាស្ត្ររលួសឡើងវិញ និងការបែងចែកទឹកមិនបានល្អក្នុងបរិវេណតំបន់ស្រោចស្រព។ បញ្ហាទាំងនេះជាដើមហេតុចម្បងនៃ ជម្លោះរវាងកសិករ។ មានអ្នកប្រើប្រាស់ទឹកបួនក្រុមសំខាន់ៗក្នុងប្រព័ន្ធរលួស ដែលត្រូវការទឹកក្នុងចំនួន និងក្នុងពេលខុសៗគ្នា។ ក្រុមទី១ ជាកសិករមកពីភូមិអូរគន្ធរ ដែលរស់នៅភាគខាងកើតនៃប្រឡាយមេ (កម្មសិទ្ធិឯកជន) ក្បែរបឹងលៀស។ ក្រុមទី២ ជាកសិករ ដែលរស់នៅ និងដាំដំណាំនៅក្បែរភូមិរលួស នៅភាគនិរតី។ ក្រុមទី៣ ជាម្ចាស់ឡូត៍នេសាទឯកជន នៅព្រែកស្បូវ ហើយក្រុមទី៤ ជាកសិករមានដីស្រែនៅតំបន់ភាគកណ្តាល ដល់តំបន់ព្យសាននៃប្រព័ន្ធរលួស។ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ មិនអាចផ្តល់ទឹកតាមបរិមាណ និងពេលដែលអ្នកប្រើប្រាស់ទឹកទាំងបួនក្រុមនេះត្រូវការទេ។ ជារៀងរាល់ឆ្នាំ គណៈកម្មការ សកបទ ដោយមានការគាំទ្រពី ក្រុយ និង PDOWRAM បានព្យាយាមបញ្ចុះបញ្ចូលកសិករក្នុង សកបទ ឲ្យពិភាក្សា និងចរចាគ្នាពីយុទ្ធសាស្ត្របែងចែកទឹកសម្រាប់រដូវវស្សា។ ប៉ុន្តែកិច្ចប្រឹងប្រែងនេះទទួលផលតិចតួចណាស់ ជាពិសេសសម្រាប់កសិករក្នុងតំបន់ភូមិរលួស ដែលមានបញ្ហាមិនអាចដោះស្រាយបានដោយសារពុំមានការកសាងឡើងវិញសឹងតែទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្របច្ចុប្បន្ន។

ក្នុងប្រព័ន្ធដំណាក់អំពិល ដែលមានប្រឡាយស្រោចស្រពឆ្លងកាត់ភូមិជាច្រើននោះ ជម្លោះលើការបែងចែកទឹកតែងកើតមានឡើងជារៀងរាល់ឆ្នាំ ដោយសារប្រជាជននៅភូមិកណ្តឹងមាសដែលស្ថិតនៅជិតភាគខាងក្រោមនៃប្រឡាយរងទី២ គាត់បិទប្រឡាយនាំទឹកទៅពីរភូមិនៅខាងលើគឺ ខ្នារ និងឆ្នោះតាចាប ដើម្បីយកទឹកប្រើប្រាស់តាមបំណងខ្លួន។ កសិករ មកពីភូមិខ្នារ និងឆ្នោះតាចាប បានរាយការណ៍ពីកំហឹងរបស់ខ្លួននៅក្នុងជម្លោះប្រចាំឆ្នាំលើការផ្គត់ផ្គង់ទឹកនេះ។

*៥.៤.២ ការសម្របសម្រួលក្នុងតំបន់*

ជាគោលការណ៍ យន្តការទំនាក់ទំនងរវាង PDOWRAM និងគណៈកម្មការ សកបទ ហាក់បង្កើតឡើងបានយ៉ាងល្អនៅតាមប្រព័ន្ធជាករណីសិក្សានីមួយៗ ប៉ុន្តែការអនុវត្តជាក់ស្តែងមិនបានល្អទេ។ ការសម្របសម្រួលនៅកម្រិតនេះបានជួបបរាជ័យខ្លះៗ ជាពិសេសដោយសារការហិរញ្ញវត្ថុគ្មានប្រសិទ្ធភាព និងកង្វះធនធានហិរញ្ញវត្ថុ។ ទំនាក់ទំនងសំខាន់ផ្សេងទៀត នៅកម្រិតធំជាងថ្នាក់មូលដ្ឋាន រួមមាន ទំនាក់ទំនងរវាងបណ្តាអង្គភាពនៃអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនឯកជន ទីភ្នាក់ងារផ្តល់ជំនួយ មន្ទីរជំនាញផ្សេងៗទៀតក្នុងខេត្ត (ឧទាហរណ៍ PDAFF) និង ទំនាក់ទំនងរវាង សកបទនៅជិតខាងគ្នាដែលពឹងផ្អែកលើប្រព័ន្ធទឹកតែមួយ (ឧទាហរណ៍ ក្នុងករណីប្រព័ន្ធដំណាក់អំពិល)។

PDOWRAM និងគណៈកម្មការ សកបទ នៃប្រព័ន្ធជាករណីសិក្សាទាំងបី តែងប្រាស្រ័យទាក់ទងគ្នាជាទៀងទាត់ ដោយសារមួយផ្នែកមកពីប្រព័ន្ធទាំងនោះស្ថិតនៅមិនឆ្ងាយពីការិយាល័យ PDOWRAM។ មន្ត្រី PDOWRAM មួយរូបតែង

ចុះពិនិត្យប្រព័ន្ធធារាសាស្ត្រ និងជួបជាមួយសមាជិក សកបទ ម្នាក់ ឬច្រើននាក់ ដើម្បីវាយតម្លៃពីកម្រិតទឹកក្នុងស្រែ និងជួយណែនាំពីការបើក និងបិទទ្វារទឹកមេនានា។ តាមរយៈនេះ PDOWRAM បានផ្តល់ជាជំនួយបច្ចេកទេស ទៅឲ្យប្រព័ន្ធធារាសាស្ត្រទាំងនោះ។

ក្នុងពីរបីឆ្នាំចុងក្រោយនេះ PDOWRAM បានបន្តផ្តល់ការទ្រទ្រង់យ៉ាងជិតស្និទ្ធសម្រាប់ សកបទ ក្នុងប្រព័ន្ធដំណាក់អំពិល។ ក្រោយពីប្រព័ន្ធធារាសាស្ត្របានកសាងរួចរាល់ PDOWRAM នៅតែបន្តចូលរួមយ៉ាងជិតស្និទ្ធក្នុងការសម្រេចចិត្តផ្នែកគ្រប់គ្រងនៅក្នុងប្រព័ន្ធដើម្បីកសាងចំណេះដឹងផ្នែកបច្ចេកទេសនិងភាពឯករាជ្យរបស់សកបទ។រាល់ការសម្រេចចិត្តលើការបែងចែកទឹក បានធ្វើឡើងឆ្លងតាមការពិភាក្សា និងការឯកភាពគ្នារវាងគណៈកម្មការ សកបទ និង PDOWRAM។ តួយ៉ាងនៅពេល សកបទចង់បើកទ្វារទឹកមេដើម្បីបង្ហូរទឹកចូលស្រែណាមួយពួកគេតែងរង់ចាំការយល់ព្រមពីPDOWRAMសិន ដើម្បីជៀសវាងផលវិបាកអវិជ្ជមានមិនអាចដឹងមុនផ្សេងៗ។ កិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់នេះគួរទទួលបានការកោតសរសើរក៏ពិតមែន ប៉ុន្តែ PDOWRA ខេត្តពោធិ៍សាត់ យល់ថា ពួកគេត្រូវព្យាយាមជួយ សកបទ ឲ្យកាន់តែឯករាជ្យ និងម្ចាស់ការខ្លួនឯងឡើង ក្នុងការគ្រប់គ្រងប្រព័ន្ធរបស់ខ្លួន។ ប្រព័ន្ធស្ទឹងជីនិត និងរលួស ពេលខ្លះមិនទទួលបានការគាំទ្រពេញលេញពីសំណាក់ PDOWRAM ទេ។ តួយ៉ាង នៅរលួស (មុនពេលមានការវិនិយោគរបស់ក្រុមហ៊ុនឯកជនថ្មី) PDOWRAM បានផ្តល់ម៉ាស៊ីនបូមទឹកធំមួយទៅឲ្យតំបន់ភាគពាយព្យនៃប្រព័ន្ធ ប៉ុន្តែមិនបានតាមដាន និងផ្តល់នូវការណែនាំផ្នែកបច្ចេកទេសបន្ថែមទៀតទេ។ កសិករនៅប្រព័ន្ធស្ទឹងជីនិត និងរលួស បានស្នើថា PDOWRAM គួរផ្តល់ជាជំនួយបច្ចេកទេសនៅពេលដែល សកបទ និងកសិករមិនអាចដោះស្រាយបញ្ហាបានដោយខ្លួនឯង។

បញ្ហាជម្លោះទឹកនៅប្រព័ន្ធដំណាក់អំពិល កើតមានឡើងលើភូមិសាស្ត្រដីធំជាងប្រព័ន្ធដែលបានសិក្សាពីរផ្សេងទៀត ដោយសារប្រព័ន្ធដំណាក់អំពិល (ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់) ស្ថិតក្នុងតំបន់ផ្ទៃរងទឹកភ្លៀងដូចគ្នានឹងស្រុកមោងឫស្សី ខេត្តបាត់ដំបង និងមានប្រភពទឹកចម្បងជាស្ទឹងតែមួយជាមួយគ្នានឹងប្រព័ន្ធស្រោចស្រពជាច្រើនទៀត ទាំងនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។ ថ្មីៗនេះ កសិករនៅប្រព័ន្ធដំណាក់អំពិល បានបង្កើនផលិតកម្មស្រូវប្រាំងរបស់ខ្លួន បើទោះជា PDOWRAM និងគណៈកម្មការ សកបទ បានក្រើនរំលឹកពីកង្វះទឹកក្តី។ PDOWRAM និង សកបទ មិនអាចទប់ស្កាត់កសិករដែលព្យាយាមខំធ្វើស្រែប្រាំងនោះទេ ព្រោះជីវភាពរបស់ពួកគេត្រូវពឹងផ្អែកលើធនធានបន្ថែមនោះ។ ជារឿយៗ PDOWRAM ទទួលសំណើឲ្យវាយតម្លៃពីស្ថានភាពជលសាស្ត្រ និងវិនិច្ឆ័យពី ផលចំណេញនៃការបង្ហូរទឹកពីបណ្តាប្រព័ន្ធនៅខ្សែទឹកខាងលើ ពីព្រោះ សកបទ និងអាជ្ញាធរមូលដ្ឋាន មិនមានសមត្ថភាព ឬសិទ្ធិអំណាចដើម្បីសម្រេចអារកាត់ និងចរចាលើការព្រមព្រៀងផ្សេងៗ ក្នុងការបែងចែកទឹកនៅកម្រិតផ្ទៃរងទឹកភ្លៀងនោះទេ។ មានហេតុការណ៍ខ្លះបានកើតឡើង ដោយសារកសិករមួយចំនួនក្នុងប្រព័ន្ធដំណាក់អំពិល គាត់ត្រូវការទឹកខ្លាំងពេករហូតដល់ព្យាយាមបង្ហូរទឹកដោយខុសច្បាប់ពីប្រព័ន្ធនៅខ្សែទឹកខាងលើ ដោយវាយបំបែកសោទ្វារទឹកធំ។ ជាទូទៅ ជម្លោះទឹកកើតមាននៅអំឡុងពេលខ្វះទឹក។ ទោះបីមានកិច្ចប្រឹងប្រែងគ្រប់គ្រងការបែងចែកទឹក និងដោះស្រាយជម្លោះក្តី ក៏បច្ចុប្បន្នមិនទាន់មានយន្តការរឹងមាំណាមួយ សម្រាប់ធានាឲ្យមានការគ្រប់គ្រងទឹកបានត្រឹមត្រូវ នៅកម្រិតធំជាងតំបន់ស្រោចស្រពនោះទេ។

កម្រិតនៃការសម្របសម្រួលរវាងវិនិយោគិនឯកជនមូលដ្ឋាន និងមកពីក្រៅ ឃើញមានតែនៅក្នុងករណីប្រព័ន្ធរលួសប៉ុណ្ណោះ។ ក្នុងករណីនេះ មិនមានការពិគ្រោះយោបល់រវាងក្រុមហ៊ុនឯកជន និងប្រជាជនមូលដ្ឋានទេ និងសូម្បីតែជាមួយគណៈកម្មការ សកបទ ឬ ក្រឃ ក៏គ្មានដែរ។ កសិករបានឲ្យដឹងថា ក្រុមហ៊ុនឯកជន និង PDOWRAM បានធ្វើសេចក្តីសម្រេច ហើយគ្រាន់តែផ្តល់ដំណឹងដល់ប្រជាជនមូលដ្ឋានថា ចាប់ពីពេលនេះតទៅប្រជាជនត្រូវបង់ថ្លៃសេវាកម្មប្រចាំឆ្នាំ ១០០ដុល្លារ ដើម្បីប្រើប្រាស់ទឹកក្នុងប្រឡាយ។ ប្រឡាយទឹកឯកជនផ្តល់ផលចំណេញដល់កសិករបានប្រហែលតែពាក់កណ្តាល ពោលគឺ អ្នកមានដីស្រែនៅភាគខាងលិចនៃប្រឡាយមេប៉ុណ្ណោះ។ កសិករខ្វះខាតអារម្មណ៍ជាម្ចាស់ និងទំនួលខុសត្រូវ ដោយសារមិនមានយន្តការអ្វីដើម្បីឲ្យគាត់បានចូលរួមក្នុងការសម្រេចចិត្តលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។ គណៈកម្មការ សកបទ ក៏មានអារម្មណ៍ដូចនេះដែរ។ ពួកគាត់មានអំណាចតិចតួចដូច

បានលើកបង្ហាញក្នុងករណីប្រឡាយទឹកឯកជននៅក្នុងគម្រោងរលួសជាដើម។ ពួកគាត់គ្មានឱកាសដើម្បីតវ៉ា ឬបដិសេធនឹងការវិនិយោគទេ គឺអាចត្រឹមតែសុំឲ្យក្រុមហ៊ុនឯកជនធ្វើការចុះបញ្ជីជាផ្លូវការ និងពិភាក្សាពីបញ្ហាស្រោចស្រពជាមួយ PDOWRAM ប៉ុណ្ណោះ។ សកបទ និយាយថា ក្រុមហ៊ុនឯកជនដែលកាន់កាប់ប្រឡាយមេ បានយល់ព្រមធ្វើសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរខេត្ត (ជាពិសេស PDOWRAM) ដើម្បីដោះស្រាយបញ្ហាមួយករណីម្តងៗ និងសម្រេចបានលទ្ធផលដែលត្រូវផ្តល់ផលចំណេញតាមការរំពឹងទុកដល់អ្នកពាក់ព័ន្ធទាំងអស់ ប៉ុន្តែនៅពេលកំពុងសិក្សា គេមិនទាន់ឃើញមានភស្តុតាងអ្វីមួយបង្ហាញពីលទ្ធផលនេះទេ។

សកបទ ជាច្រើនក្នុងខេត្តកំពង់ធំ បានដួលរលំ ឬមានដំណើរការមិនល្អដោយសារកង្វះការទ្រទ្រង់ហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសពីទីភ្នាក់ងារខាងក្រៅផ្សេងៗ។ នៅចំពោះមុខបញ្ហានេះ សកបទ ក្នុងប្រព័ន្ធស្ទឹងជីនិត មានការរៀបចំ និងការផ្តល់ជំនួយទ្រទ្រង់ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ឬ NGOs ជាពិសេស អង្គការ ហ្រ្គេត និងសេដាក ដែលបានផ្តល់ជំនួយជាទៀងទាត់ទាក់ទងនឹងការគ្រប់គ្រងទឹក និងដំណើរការរបស់ សកបទ ។ ការទ្រទ្រង់ពីខាងក្រៅនេះ បានជួយគាំទ្រយ៉ាងខ្លាំងដល់ប្រតិបត្តិការប្រកបដោយជោគជ័យនៃ សកបទ រហូតដល់ពេលបញ្ចប់គម្រោង នៅខែមិថុនា ២០០៩។ ទោះបីជា សកបទ នៅស្ទឹងជីនិត បានកសាងសមត្ថភាពបច្ចេកទេសដល់កម្រិតដ៏សមរម្យមួយ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្រ្តដោយទទួលបានការទ្រទ្រង់ពី ហ្រ្គេត និង សេដាក ក្តី ក៏ក្នុងអំឡុងពេលសិក្សា សកបទ បានសម្តែងការព្រួយបារម្ភ ព្រោះថាថវិកាប្រចាំខែប្រមូលបានពី ISF អាចមិនគ្រប់សម្រាប់ចំណាយប្រតិបត្តិការ និងការងាររដ្ឋបាលទេ។

ទោះបី កសិករ មេភូមិ ក្រុយ សមាជិកគណៈកម្មការ សកបទ និង PDOWRAM មានការប្តេជ្ញាចិត្តធ្វើការសហការល្អជាមួយគ្នាក្តី ក៏ការប្រាស្រ័យទាក់ទងជាទៀងទាត់តែងជួបឧបសគ្គដោយសារទីតាំងភូមិសាស្រ្តនៅឆ្ងាយពីគ្នា ត្រូវចំណាយលើថ្លៃធ្វើដំណើរនិងថ្លៃទូរស័ព្ទអស់ច្រើនហួសពីលទ្ធភាពផ្គត់ផ្គង់របស់គណៈកម្មការ និងកសិករ។ ករណីនេះកើតមានឡើងនៅប្រព័ន្ធដំណាក់អំពិល ដោយការប្រជុំប្រចាំខែរវាងសមាជិក សកបទ ដើម្បីរាយការណ៍ពីការបែងចែកទឹក ការដាំដំណាំ និងការគ្រប់គ្រងជម្លោះ មិនបានធ្វើឡើងទេ ព្រោះត្រូវចំណាយប្រាក់ពីហោប៉ៅអស់ច្រើនពេក។ ប៉ុន្តែសម្រាប់ប្រព័ន្ធស្ទឹងជីនិត ដែលនៅទទួលបានហិរញ្ញប្បទានពីខាងក្រៅ កិច្ចប្រជុំរវាង សកបទ និង PDOWRAM បានធ្វើឡើងប្រចាំសប្តាហ៍ ហើយសមាជិកគណៈកម្មការទ្រទ្រង់ប្រព័ន្ធធារាសាស្រ្ត[២១] តែងជួបប្រជុំបានទៀងទាត់ក្នុងមួយខែម្តង។

[២១] គណៈកម្មការទ្រទ្រង់ប្រព័ន្ធធារាសាស្រ្ត ដឹកនាំដោយអភិបាលស្រុក និងមានអ្នកតំណាងមកពីបណ្តាមន្ទីរខេត្តពាក់ព័ន្ធ ឃុំ និង ក្រុយ នគរបាល និង សកបទ។

# ៦ ការពិភាក្សា និង សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះបានលើកជាសំណួរពីរ ដើម្បីតម្រង់ទិសការពិនិត្យឡើងវិញតាមភស្តុតាងជាក់ស្តែង។ ខាងក្រោមនេះ ជាការវិភាគលើព័ត៌មានជាក់ស្តែងពាក់ព័ន្ធនឹងសំណួរស្រាវជ្រាវទាំងពីរ។

## ៦.១ ភាពស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

*តើការអនុវត្ត និងរចនាសម្ព័ន្ធអភិបាលកិច្ចមានស្រាប់ វាស៊ីគ្នាប៉ុណ្ណាទៅនឹងទ្រង់ទ្រាយ និងទំហំនៃប្រព័ន្ធធារាសាស្ត្រ?*

អភិបាលកិច្ចផ្នែកធារាសាស្ត្រភាគច្រើននៅកម្ពុជានាបច្ចុប្បន្ន ឆ្លុះបញ្ចាំងនូវ វិធីសាស្ត្រពីរផ្សេងគ្នាគឺ ១) បេសកកម្មដោះស្រាយទឹករបស់ខ្មែរក្រហម[២២] ដែលប្រឹងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រខ្នាតធំ និងវិធីសាស្ត្រអភិបាលកិច្ចដោយមានការចូលរួមនាពេលបច្ចុប្បន្ន ដែលព្យាយាមផ្ទេរមុខងារគ្រប់គ្រងទៅឲ្យកម្រិតសហគមន៍តាមរយៈការបង្កើត សកបទ ឲ្យដើរតួជាអង្គភាពអភិបាលកិច្ចមូលដ្ឋានសម្រាប់ប្រព័ន្ធធារាសាស្ត្រ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធខ្នាតធំកសាងឡើងក្នុងអំឡុងរបបខ្មែរក្រហម ភាគច្រើនមិនទាន់បានពេញលេញ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសទេ ដោយសាររបបនោះមានរយៈពេលខ្លី និងខ្វះខាតសមត្ថភាពផ្នែកបច្ចេកទេស។ រីឯវិធីសាស្ត្របែបសហគមន៍ ក៏ទទួលបានជោគជ័យតិចតួចដែរក្នុងបរិបទវប្បធម៌នៅកម្ពុជា ព្រោះ ១) តាំងពីដើមរៀងមក កម្ពុជាមិនមាន ឬមានបទពិសោធន៍បែបនេះតិចតួចពេក (Oversen *et al.* 1996) និង ២) ប្រជាជនធ្លាប់មានបទពិសោធន៍ជូរចត់ជាមួយវិធីសាស្ត្រដោយមានការចូលរួមនេះ ឆ្លងតាមការអនុវត្តកសិកម្មបែបសមូហភាពរបស់ខ្មែរក្រហម។ លក្ខខណ្ឌទាំងពីរនេះកាន់តែចោទធ្ងន់ឡើង ដោយសារប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាតែងជាប់ទាក់ទងគ្នាចុះឡើងជាខ្លាំង និងមានច្រើនបែបយ៉ាង។ កត្តាទាំងនេះបំផុសសំណួរថា តើហេដ្ឋារចនាសម្ព័ន្ធមិនពេញលេញ និងអន់ខ្សោយទាំងនេះ ដែលកំពុងស្ថិតក្នុងបរិស្ថានជលសាស្ត្រដ៏សម្បូរបែប និងជាប់ទាក់ទងគ្នាចុះឡើងនៅកម្ពុជា វាគួបផ្សំគ្នាបានយ៉ាងណាជាមួយនឹងវិធីសាស្ត្រអភិបាលកិច្ចបែបសហគមន៍នាពេលបច្ចុប្បន្ន ដែលត្រូវផ្សារភ្ជាប់ជាមួយនឹងវប្បធម៌គោលនយោបាយបែបខ្សែខ្នង និងរចនាសម្ព័ន្ធអភិបាលកិច្ចបែបឋានានុក្រម។ លទ្ធផលនៃករណីសិក្សាលើប្រព័ន្ធធារាសាស្ត្រទាំងបី បានបង្ហាញពី ភាពមិនស៊ីគ្នារវាងសមាសភាពទាំងពីរខាងលើ ទាំងនៅក្នុងសហគមន៍ និងកម្រិតលើសពីសហគមន៍ និងទាំងរវាងមន្ទីរជំនាញនានាដែលត្រូវតែដោះស្រាយក្នុងពេលដំណាលគ្នា ដើម្បីកាត់បន្ថយភាពមិនស៊ីគ្នានេះ។ លទ្ធផលក៏បានបំផុសបញ្ហាប្រឈមសំខាន់ៗបី គឺ៖ សមត្ថភាពខាងបច្ចេកទេស និងហិរញ្ញវត្ថុ ធនធានមនុស្ស និងការសម្របសម្រួល។

បញ្ហាប្រឈមខាងហិរញ្ញវត្ថុ គឺការស្វែងរកមធ្យោបាយដើម្បីឲ្យអង្គភាពនៅមូលដ្ឋាន (ឧទាហរណ៍ សកបទ) ទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ ការកែលំអហេដ្ឋារចនាសម្ព័ន្ធក្នុងកម្រិតមួយឆ្លើយតបនឹងតម្រូវការរបស់កសិករ និងការរក្សាប្រតិបត្តិការនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ។ ការស្រាវជ្រាវ ផ្តល់លទ្ធផលមួយស្របគ្នានឹងការសង្កេតរបស់ Chea (2010) ដែលលើកថា គេតែងរំពឹងឲ្យ សកបទ ធ្វើប្រតិបត្តិការដោយប្រើប្រាស់ ISF ជាប្រភពហិរញ្ញវត្ថុចំបង ថ្វីបើគំនិតផ្តួចផ្តើម ISF ពិបាកនឹងយកមកអនុវត្តជាក់ស្តែងក្នុងបរិបទប្រទេសកម្ពុជាក្តី។ ជាក់ស្តែង នៅប្រព័ន្ធរលួសមានកសិករតែ ៣០% បានបង់ ISF ហើយនៅប្រព័ន្ធដំណាក់អំពិល មាន ០%។ កសិករខ្លះរាយការណ៍ថា គាត់ពេញចិត្តនឹងបង់ថ្លៃ ISF ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រអាចផ្តល់ទឹកគ្រប់គ្រាន់សម្រាប់ដំណាំគាត់។ ចំណុចនេះ និងស្ថានភាពក្នុងប្រព័ន្ធធារាសាស្ត្រដែលសិក្សានីមួយៗបង្ហាញថា ការកែលំអស៊ីជម្រៅដល់ហេដ្ឋារចនាសម្ព័ន្ធ ដែលជួយ

[២២] គម្រោងធារាសាស្ត្ររាប់រយគម្រោង បានអនុវត្តឡើងនៅទូទាំងប្រទេស ក្នុងអំឡុងរបបខ្មែរក្រហម (១៩៧៥-៧៩) ដោយមានការកសាងប្រឡាយ និងទំនប់ទឹកជាច្រើន។ រដ្ឋបានប្រើហិង្សាខ្លាំងបំផុត ដើម្បីបង្ខំប្រជាជនឲ្យបំពេញតាមផែនការខ្លួន។

សម្រួលឲ្យមានការបែងចែកទឹកគ្រប់គ្រាន់ និងគួរឲ្យជឿជាក់ដល់កសិករ គឺជាបុព្វលក្ខខណ្ឌដើម្បីប្រមូលវិភាគទាន ISF បានជោគជ័យ។

ជាសង្ខេប ក្នុងបញ្ហាខ្សត់ទឹក (សូមមើលនៅក្នុង ការសិក្សាឯកសារមានស្រាប់) នៅកម្ពុជាមិនមែនគ្រាន់តែមានការខ្សត់ទឹកជាលក្ខណៈសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែជួនកាលមានទាំងការខ្សត់ទឹកជាលក្ខណៈរូបវ័ន្តទៀតផង។ តួយ៉ាង នៅតំបន់ភាគពាយព្យនៃប្រព័ន្ធរលួស (ក្បែរបឹងលៀស) មានកង្វះទឹកជាលក្ខណៈរូបវ័ន្តនៅកម្រិតអនុគម្រោង ហើយកង្វះទឹកជាលក្ខណៈសេដ្ឋកិច្ច (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយខ្លាំង) បានធ្វើឲ្យមានបញ្ហាចោទកាន់តែធ្ងន់ឡើងទៀតចំពោះកសិករ។ នៅទីនោះកសិករដឹងថា ប្រាក់ ISF ដែលគាត់បង់ គេយកទៅចំណាយលើការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែមានកសិករមួយចំនួនមិនអាចបង់ប្រាក់នោះទេ ដោយសារទិន្នផលកសិកម្មទាបពេកព្រោះខ្វះទឹក។ អំឡុងពេលជួសជុល នៅប្រព័ន្ធដំណាក់អំពិលតែងខ្វះទឹកជានិច្ច ហើយសូម្បីតែអ្នកប្រើប្រាស់នៅតំបន់ខ្សែទឹកខាងលើ ក៏គិតថាទឹកមានមិនគ្រប់គ្រាន់ដែរ។ ការបែងចែកទឹកពីប្រព័ន្ធធារាសាស្ត្រនៅខ្សែទឹកខាងលើ ទៅឲ្យប្រព័ន្ធដទៃនៅក្រោមប្រព័ន្ធដំណាក់អំពិល មិនអាចធ្វើកើតទេ ពីព្រោះគ្មានប្រឡាយច្បាស់លាស់រវាងប្រព័ន្ធទាំងនោះ ហើយការបើកទឹកឲ្យហូរតាមស្ទឹងធម្មជាតិ នាំឲ្យបាត់បង់ទឹកច្រើនណាស់តាមការជ្រាប និងរំហួត។

មុខងារកែលំអហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ មិនអាចអនុវត្តដោយ សកបទ ដែលទើបបង្កើតថ្មីតែឯងទេ។ ពីដំបូង ត្រូវមានការទ្រទ្រង់ផ្នែកបច្ចេកទេស និងផ្នែកមូលធនហិរញ្ញវត្ថុពីខាងក្រៅ ហើយជាការប្រសើរ មុខងារគ្រប់គ្រងនឹងត្រូវផ្ទេរទៅឲ្យគណៈកម្មការមូលដ្ឋាន បន្ទាប់ពីកសាងសមត្ថភាពបានគ្រប់គ្រាន់ភ្លាម។ កត្តាសំខាន់មួយដែលត្រូវចងចាំ គឺវិធីសាស្ត្រដោយមានការចូលរួមនៅកម្រិតសហគមន៍ មិនធ្លាប់មាននៅក្នុងវប្បធម៌កម្ពុជាទេ ដូច្នេះត្រូវតែបណ្តុះវាឡើងនៅក្នុងផ្នត់គំនិតរបស់ប្រជាជនមូលដ្ឋាន និងជួយជំរុញថែមទៀត មុនពេលវាអាចដំណើរការដោយឯករាជ្យ ម្ចាស់ការ និងរីកលូតលាស់ខ្លួនឯងបាន។ ករណីប្រព័ន្ធរលួស ជាឧទាហរណ៍ជាក់ស្តែងមួយ ដែលការណែនាំឲ្យប្រើប្រាស់វិធីសាស្ត្រមានការចូលរួមនេះ មិនទទួលបានការជំរុញគ្រប់គ្រាន់ឡើយ។ សកបទ នៅប្រព័ន្ធនោះមានហិរញ្ញវត្ថុខ្សត់ខ្សោយ មិនមានអំណាចសម្រេចចិត្ត និងខ្វះសមត្ថភាពធ្វើការអភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។

ដោយសារការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មីនៅកម្រិតប្រព័ន្ធធារាសាស្ត្រឬអនុប្រព័ន្ធតែងមានតម្លៃខ្ពស់ហើយដើម្បីផ្តល់អត្ថប្រយោជន៍ភ្លាមៗសម្រាប់ជីវភាពរបស់កសិករនោះ សកបទ គួរផ្តោតកិច្ចប្រឹងប្រែងលើការកសាង និងថែទាំប្រព័ន្ធធារាសាស្ត្រទ្រង់ទ្រាយតូចៗជាងនេះ។ ប្រព័ន្ធខ្នាតតូចបែបនេះ អាចមានទាំងការកៀរគរកសិករឲ្យបង្កើយការកសាង និងថែទាំប្រឡាយរងទី៣ និងហេដ្ឋារចនាសម្ព័ន្ធដោះទឹក ដែលជួយដោះស្រាយតម្រូវការទឹកបានភ្លាមៗឲ្យកសិករ។ លទ្ធផលស្រាវជ្រាវ បង្ហាញថា សកបទ ត្រូវធ្វើការសម្របសម្រួលខ្លះៗ ព្រោះកសិករមិនទំនងជាអាចសម្របសម្រួលសកម្មភាពដូចខាងលើដោយខ្លួនឯងបានទេ (ឧទាហរណ៍ ក្នុងករណីប្រព័ន្ធស្ទឹងជីនិត) ហើយក្នុងការងារនេះ សកបទ ក៏គ្មានត្រូវចាយវាយអ្វីដែរ។ ការបែរទៅផ្តោតកិច្ចប្រឹងប្រែងបែបនេះ អាចបង្កភាពមិនពេញចិត្តក្នុងចំណោមកសិករដែលមិនបានទទួលការយកចិត្តទុកដាក់ និងជំនួយជិតដល់ពីគណៈកម្មការ សកបទ ប៉ុន្តែវាបង្ហាញពីសកម្មភាពជាក់ស្តែង និងមានប្រយោជន៍របស់គណៈកម្មការ ដែលជួយរួមចំណែកដល់ការកសាងសមត្ថភាពសង្គម ទំនុកចិត្ត និងការទទួលស្គាល់ សកបទ ពីសំណាក់កសិករ។

បញ្ហាប្រឈមទី២ គឺកង្វះធនធានមនុស្សនៅក្នុងអង្គភាពអភិបាលកិច្ចមូលដ្ឋាន ធៀបនឹងទំហំនៃប្រព័ន្ធធារាសាស្ត្រ និងសមត្ថភាពបច្ចេកទេសដែលត្រូវមានដើម្បីគ្រប់គ្រងប្រព័ន្ធឲ្យបានល្អ។ ប្រព័ន្ធដែលបានសិក្សានីមួយៗគ្របដណ្តប់លើផ្ទៃដីពី ៣ ទៅ ៤ ឃុំ និងឆ្លងកាត់ភូមិជាច្រើន។ ម្យ៉ាងវិញទៀត ហេដ្ឋារចនាសម្ព័ន្ធក្នុងគ្រប់ប្រព័ន្ធ នៅមិនទាន់មានលក្ខណៈពេញលេញទេ។ ប្រព័ន្ធស្ទឹងជីនិតមានស្ថានភាពប្រសើរជាងប្រព័ន្ធពីរទៀត ប៉ុន្តែក៏នៅខ្វះខាតប្រឡាយរងទី៣ ដែរ។ ហេដ្ឋារចនាសម្ព័ន្ធមិនពេញលេញ និងសាងសង់មិនបានល្អ បង្កើតបានជាបន្ទុកខាងហិរញ្ញវត្ថុ និងខាងបច្ចេកទេសដល់ការគ្រប់គ្រងប្រព័ន្ធ។ គណៈកម្មការ សកបទ បច្ចុប្បន្ន នៃប្រព័ន្ធ រលួស និងដំណាក់អំពិល មានសមាជិកជាក់ស្តែងមិនដល់ ១០នាក់ទេ ហើយពួកគាត់ត្រូវគ្រប់គ្រងលើប្រព័ន្ធធារាសាស្ត្រគ្របដណ្តប់លើដីស្រែធំជាង

១០០០ហិកតា ទោះបីជាពួកគាត់មិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការ និងគ្រប់គ្រងជ្រោយក្តី។ ប្រព័ន្ធស្ទឹងជីនិត មានរចនាសម្ព័ន្ធប្រព័ន្ធអភិបាលកិច្ចរៀបចំបានល្អជាងគេ ប៉ុន្តែផ្ទៃដីស្រោចស្រពដ៏ធំធេង និងភាពស្មុគស្មាញនៃអង្គភាព អភិបាលកិច្ចមានច្រើនថ្នាក់និងត្រួតគ្នា(ពោលគឺវត្តមានរចនាសម្ព័ន្ធបន្ថែមនិងបុគ្គលិកបណ្តែតៈសូមមើលជំពូកលទ្ធផល ស្រាវជ្រាវ) នៅតែចោទជាសំណួរថា តើការអនុវត្តប្រកបដោយប្រសិទ្ធភាពអាចកើតមានឬទេ បន្ទាប់ពីហិរញ្ញប្បទានពី ខាងក្រៅបានបញ្ចប់ទៅនាពេលថ្មីៗនេះ។

ការយល់ដឹងពីមុខងារ និងទំនួលខុសត្រូវរបស់សមាជិក សកបទ នៅមានលក្ខណៈស្រពេចស្រពិលនៅឡើយ សូម្បីក្នុងចំណោមសមាជិកគណៈកម្មការក្តី។ នៅក្នុងប្រព័ន្ធដែលបានសិក្សាទាំងបី គ្មាន សកបទ ណាមួយបានកសាង ឬមើលថែទាំប្រឡាយរងទី៣ ឡើយ។ តួយ៉ាង នៅក្នុងប្រព័ន្ធស្ទឹងជីនិត សមាជិក សកបទ យល់ថា មុខងារ និងទំនួល ខុសត្រូវរបស់ខ្លួនអាចមិនផ្តោតសំខាន់លើការជួយ ឬការកៀរគរកសិករឲ្យកសាងប្រឡាយរងទី៣ ទេ ព្រោះពួកគាត់មាន តួនាទីដោះស្រាយបញ្ហាធំជាងនោះ ពោលគឺ ការថែទាំហេដ្ឋារចនាសម្ព័ន្ធធំៗដែលមានស្រាប់ ដូចជា ប្រឡាយមេ និង ប្រឡាយរងទី២ ដូច្នេះគាត់ក៏ចោលសកម្មភាពដ៏សំខាន់បំផុតតែមិនសូវមានគេលើកឡើងទាំងនេះ ទុកឲ្យកសិករម្នាក់ៗ ធ្វើទៅវិញ។ រឿងនេះបំផុសសំណួរថា ហេតុអ្វីក៏មានការភាន់ច្រឡំទៅកើត ពីព្រោះគោលនយោបាយ PIMD បានចែង ច្បាស់ថា សកបទ ត្រូវដើរតួជាអង្គភាពអភិបាលកិច្ចមូលដ្ឋានថ្នាក់ទាបបំផុត ដែលគេត្រូវផ្ទេរទំនួលខុសត្រូវផ្នែកគ្រប់គ្រង ទៅឲ្យ។ ពិនិត្យតាមភាពមិនស៊ីគ្នាជាក់ស្តែងរវាងទំហំប្រព័ន្ធធារាសាស្ត្ររូបវ័ន្ត និងធនធានមនុស្សរបស់ សកបទ គេអាច យល់បានថា ប្រព័ន្ធធារាសាស្ត្រគ្របដណ្តប់លើផ្ទៃដីធំពេក ហួសពីលទ្ធភាពគ្រប់គ្រងរបស់គណៈកម្មការ សកបទ។ តាម ពិត អង្គភាពអភិបាលកិច្ចកម្រិតមូលដ្ឋាននេះ ត្រូវមានអង្គភាពថ្នាក់ទាបជាងនេះទៀត ដើម្បីទទួលខុសត្រូវលើមុខងារនៅ កម្រិតទាបបំផុត (ឧទាហរណ៍ ការគ្រប់គ្រងប្រឡាយរងទី៣ និងហេដ្ឋារចនាសម្ព័ន្ធដោះទឹក)។ ហេតុផលសមស្របត្រូវ បានលើកឡើងដើម្បីជំរុញកសិករឲ្យទទួលខុសត្រូវលើការស្រោចស្រពនៅដីស្រែរបស់ខ្លួន ប៉ុន្តែកង្វះការសម្របសម្រួល និងសមត្ថភាពបច្ចេកទេសនិងហិរញ្ញវត្ថុនៅកម្រិតនេះ ធ្វើឲ្យវិធីនេះអនុវត្តមិនកើត។ ក្រុមអភិបាលកិច្ចតូចៗ (ឧទាហរណ៍ កកបទ) ដូចមានលើកឡើងនៅក្នុង PIMD គួរតែបង្កើតឡើង បណ្តុះបណ្តាល និងសម្របសម្រួលឲ្យបានសមស្រប បើសិនចង់ឲ្យប្រព័ន្ធធារាសាស្ត្រនានារក្សាទំហំដ៏ធំដូចសព្វថ្ងៃនេះ។ ថ្នាក់ដឹកនាំនៃក្រុមតូចៗ ប៉ុន្តែសំខាន់ខ្លាំងទាំងនេះ ត្រូវដាក់បញ្ចូលទៅក្នុង សកបទ ដើម្បីធានាឲ្យមានលំហូរព័ត៌មាន និងកិច្ចសហប្រតិបត្តិការរវាងអង្គភាពអភិបាលកិច្ច កម្រិតទាបបំផុត និងកម្រិតកណ្តាល ព្រមទាំងដំណើរការប្រកបដោយប្រសិទ្ធភាពនៃក្រុមកម្រិតមូលដ្ឋានទាំងនេះ។

បញ្ហាប្រឈមចំបងទី៣ គឺការសម្របសម្រួល។ ប្រព័ន្ធជលសាស្ត្រមិនអាចដាក់បញ្ចូលទៅក្នុងព្រំដែនរដ្ឋបាល ផ្សេងៗ ដូចជា ភូមិ ឃុំ ឬ គម្រោងនានាឡើយ។ ការគ្រប់គ្រងនៅកម្រិតផ្ទៃរងទឹកភ្លៀង បានចាក់ឫសយ៉ាងមាំទាំងក្នុង ទ្រឹស្តី និងការអនុវត្តនៅក្នុងប្រទេសជាច្រើន ពីព្រោះវាប្រើប្រាស់រង្វង់ព្រំដែនផ្នែកបរិស្ថាន ជាឯកតានៃការគ្រប់គ្រង។ នៅកម្ពុជា រចនាសម្ព័ន្ធរដ្ឋាភិបាលសម្រាប់ការគ្រប់គ្រងនៅកម្រិតផ្ទៃរងទឹកភ្លៀង មិនទាន់មានបង្កើតឡើងនៅឡើយ ទេ ប៉ុន្តែទំនាក់ទំនង និងការសម្របសម្រួលយ៉ាងល្អរវាងទីភ្នាក់ងារជំនាញនានា (ឧទាហរណ៍ សកបទ PDOWRAM, MOWRAM) ក៏អាចមានប្រសិទ្ធភាពប្រហែលគ្នាដែរ។ អត្ថប្រយោជន៍ជាសក្តានុពលនៃសមត្ថភាពគ្រប់គ្រងបែបណា មួយនៅកម្រិតផ្ទៃរងទឹកភ្លៀង រួមមាន លទ្ធភាពកាន់តែប្រសើរឡើងក្នុងការបែងចែកទឹកនៅក្នុងផ្ទៃរងទឹកភ្លៀងប្រកប ដោយប្រសិទ្ធភាពនិងសមធម៌ ការដោះស្រាយទំនាស់អំពីកង្វះទឹក និងការការពារសុខភាពផ្នែកអេកូឡូស៊ីនៃប្រព័ន្ធស្ទឹង ទន្លេ។ តម្រូវការការគ្រប់គ្រងនៅកម្រិតនេះ បានលេចធ្លោឡើងក្នុងករណីប្រព័ន្ធដំណាក់អំពិល ដែលជួបបញ្ហាកង្វះ ទឹករាល់ឆ្នាំ ដោយសារតម្រូវការទឹកប្រជែងគ្នារវាង អ្នកប្រើប្រាស់នៅតំបន់ខ្សែទឹកខាងលើក្នុងផ្ទៃរងទឹកភ្លៀង។ ដូចមាន បង្ហាញរួចមកហើយ (សូមមើល ជំពូកទីតាំងករណីសិក្សា) ប្រព័ន្ធដំណាក់អំពិល ស្ថិតក្នុងផ្ទៃរងទឹកភ្លៀងមួយដែលគ្រប ដណ្តប់លើប្រព័ន្ធធារាសាស្ត្រ និងស្រុកជាច្រើន នៃខេត្តចំនួនពីរ។ គណៈកម្មការ សកបទ ក្រយ ថ្នាក់ដឹកនាំភូមិ និងស្រុក មិនមានសិទ្ធិសម្រេចលើបញ្ហាបែងចែកទឹករវាងប្រព័ន្ធនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមទេ ហើយត្រូវពិគ្រោះ ជាមួយ PDOWRAM ដើម្បីសម្រេចអារកាត់ ដោយជួនកាលត្រូវមានការចូលរួមពី PDOWRAM នៅខេត្តបាត់ដំបង និង ពោធិ៍សាត់ ផង។ លទ្ធផលស្រាវជ្រាវ បង្ហាញថា ចំណងទាក់ទងផ្ទៃក្នុងដ៏រលូនរវាង ហេដ្ឋារចនាសម្ព័ន្ធមានផែនការល្អ

និងប្រព័ន្ធអភិបាលកិច្ចរៀបចំបានល្អ អាចនាំឲ្យមុខងារអភិបាលកិច្ចមូលដ្ឋានអនុវត្តបានកាន់តែរលូន (ឧទាហរណ៍ ករណីប្រព័ន្ធស្ទឹងជីនិត ធៀបនឹងប្រព័ន្ធពីរទៀត)។

អត្ថបទនេះទទួលស្គាល់ពីសារៈសំខាន់នៃប្រព័ន្ធអភិបាលកិច្ចដែលចាក់ឫសតាំងពីមុនមក ហើយជំរុញឲ្យមាន ការពិនិត្យពីបញ្ហាអភិបាលកិច្ចធារាសាស្រ្ត ដោយផ្តោតទាំងទៅលើ ការបង្កើតអង្គភាពនៅមូលដ្ឋានដើម្បីអនុវត្តមុខងារ គ្រប់គ្រងនិងថែទាំគម្រោង និងទៅលើ ការបង្កើតប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានពេញលេញមួយដែលអាចដាក់បញ្ចូលទៅ ក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចដែលមានស្រាប់។ ចំណុចនេះសំដៅដល់ ការបង្កើតព្រមគ្នានូវ អង្គភាពអភិបាលកិច្ចមូល ដ្ឋានមួយមានច្បាប់ និងបទបញ្ញត្តិអមផង ព្រមទាំងប្រព័ន្ធទ្រទ្រង់ផ្សេងៗ។ បើសិនគ្មានប្រព័ន្ធនេះទេ កម្មវិធីធារាសាស្រ្ត មុខជាត្រូវបរាជ័យ ដូច Oncken and Burrows (1994) បានបញ្ជាក់ថា ការផ្ទេរសិទ្ធិអំណាចដោយមិនប្រាកដថា មុខងារ គ្រប់គ្រងដើរចំគន្លងត្រឹមត្រូវ ហើយអ្នកទទួលសិទ្ធិក៏អាចអនុវត្តមុខងារដោយខ្លួនឯងបានជោគជ័យនោះ វាមិនមែនជាការ ផ្ទេរសិទ្ធិអំណាចទេ ប៉ុន្តែជាការបោះបង់ទំនួលខុសត្រូវទៅវិញ។ PIMD បានទទួលស្គាល់ពីសារៈសំខាន់នៃប្រព័ន្ធទ្រទ្រង់ នេះ ហើយជំរុញអ្នកអនុវត្តគោលនយោបាយឲ្យធ្វើសកម្មភាពលើសពីការងាររៀបចំ គឺត្រូវចាប់ផ្តើមកែសម្រួលឡើងវិញ នូវប្រព័ន្ធទ្រទ្រង់សម្រាប់ សកបទ តាមរយៈការកំណត់តួនាទីថ្មីសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា។ ប៉ុន្តែការ ឆ្លើយតបនឹងគំនិតផ្តួចផ្តើមនេះ (តាមរយៈការអនុវត្តជាក់ស្តែង) មិនសូវមានទេ ដោយសារកង្វះឆន្ទៈទទួលយកភារកិច្ច ច្រើនថែមទៀត និងកង្វះសមត្ថភាពខាងហិរញ្ញវត្ថុ។

សរុបមក ដើម្បីញ៉ាំងឲ្យហេដ្ឋារចនាសម្ព័ន្ធ និងរបៀបរៀបចំអភិបាលកិច្ចកាន់តែស៊ីគ្នាល្អឡើង ត្រូវតែគិតគូរពី គោលដៅចំបងមួយចំនួន។ ហេដ្ឋារចនាសម្ព័ន្ធត្រូវកែលំអឲ្យដល់កម្រិតមួយដែលអាចបំពេញចិត្តកសិករបានក្នុងបញ្ហា ទិន្នផលស្រូវ ហើយកសិករនឹងមើលឃើញគណៈកម្មការ សកបទ ថាសំខាន់ និងជាអង្គភាពអភិបាលកិច្ចពេញច្បាប់មាន សិទ្ធិអំណាចគ្រប់គ្រងលើប្រព័ន្ធធារាសាស្រ្ត។ រចនាសម្ព័ន្ធ សកបទ ត្រូវកែសម្រួលដើម្បីបញ្ចូលក្រុមតូចៗ (ឧទាហរណ៍ កកបទ) ហើយសមត្ថភាពបច្ចេកទេស ក៏ត្រូវពង្រីកឲ្យហួសពីថ្នាក់ដឹកនាំតែពីរ-បីនាក់នៅក្នុងគណៈកម្មការ។ សកបទ គួរព្យាយាមបង្កើតជាលទ្ធផលជាក់ស្តែង និងលេចធ្លោសម្រាប់សហគមន៍នៅកម្រិតមូលដ្ឋាន ដើម្បីកសាងទំនុកចិត្ត របស់ប្រជាជន។ យន្តការគ្រប់គ្រងរបស់ សកបទ ត្រូវមានតម្លាភាព ដើម្បីទាក់ទាញការចូលរួមបានកាន់តែច្រើន។ ថ្នាក់ ដឹកនាំត្រូវធ្វើជាគំរូល្អ និងដាច់ខាតត្រូវមានតម្លាភាពផ្នែកហិរញ្ញវត្ថុ។ ម៉្យាងទៀត ត្រូវមានកិច្ចប្រឹងប្រែងកែសម្រួល និង បន្ស៊ីគោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងទឹក និងប្រព័ន្ធអេកូឡូស៊ីធំទូលាយ ដើម្បីតម្រង់ទិសការអនុវត្តនៅកម្រិត មូលដ្ឋាន។ គោលដៅទាំងប្រាំនេះ អាចពិបាកសម្រេចបានក្នុងរយៈពេលខ្លី ប៉ុន្តែបើសិនមិនយកមកពិចារណាទេនោះ ការ ស្វែងរកអភិបាលកិច្ចល្អនៅមូលដ្ឋានលើប្រព័ន្ធធារាសាស្រ្ត ប្រហែលពិបាកនឹងធ្វើទៅបាន។

## ៦.២ ការកែសម្រួលរបៀបរបបអភិបាលកិច្ចមានចែចរួចហើយ

*តើការអនុវត្តអភិបាលកិច្ចធារាសាស្រ្តក្នុងការបែងចែកទឹក និងការកសាងនិងថែទាំប្រព័ន្ធ ដែល សកបទ កំពុងអនុវត្ត ស៊ីគ្នាប៉ុណ្ណា ទៅនឹងប្រភេទ និងការរំពឹងទុកដែលមាននៅក្នុងគំនិតផ្តួចផ្តើមអភិបាលកិច្ច ដូចជា IMT និង PIMD ជាដើម? ហេតុអ្វី (តើមានលក្ខខណ្ឌជាក់លាក់អ្វីខ្លះនៅកម្ពុជា ដែលធ្វើឲ្យគំនិតផ្តួចផ្តើមបែបនេះមានដំណើរការល្អ ទទួលបរាជ័យ ឬត្រូវកែសម្រួល?)*

កាលពីដំបូងគេលើកថា គោលដៅចំបងពីរនៃអភិបាលកិច្ចល្អ គឺការផ្តល់ទឹកដល់ប្រជាជន និងតំបន់នានាឲ្យបាន ទៀងទាត់ក្នុងចំនួនគ្រប់គ្រាន់ទាន់ពេលល្អហើយនិងការរចនារៀបចំនិងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់អត្ថប្រយោជន៍ ប្រកបដោយនិរន្តរភាព និងសមធម៌ ដល់ជីវភាពរស់នៅ។ ចំណុចនេះមានន័យថា អភិបាលកិច្ចធារាសាស្រ្តល្អត្រូវមាន យន្តការផ្សេងៗសម្រាប់បែងចែកទឹកឲ្យមានប្រសិទ្ធភាព ហើយក្នុងពេលដំណាលគ្នា ត្រូវមានយន្តការសម្រាប់រចនារៀបចំ កសាង ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ទៅតាមបែបបទមួយមានសមធម៌ និងនិរន្តរភាព។ គោលការណ៍ទាំងបួន

នៃគោលនយោបាយ PIMD (ពោលគឺ ការបង្កើត សកបទ ការកសាងសមត្ថភាពគ្រប់គ្រងរបស់ សកបទ ការជួសជុល និងកែលំអហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដោយមានការចូលរួម និងការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងស្រោចស្រព) បានគូសបញ្ជាក់ពីយន្តការដែលត្រូវមានដើម្បីសម្រេចគោលដៅកំពូលទាំងពីរខាងលើ ហើយដែលស្របគ្នានឹងគោលការណ៍មួយរបស់ IWRM ស្តីពីការគ្រប់គ្រងទឹកនៅកម្រិតសមស្របដ៏ទាបបំផុត (UNCED 1992)។ ទោះបីមានការប្រឹងប្រែងអនុវត្ត PIMD យ៉ាងណាក្តី ក៏លទ្ធផលសិក្សាពីប្រព័ន្ធទាំងបី បង្ហាញថា គោលដៅចំបងនៃអភិបាលកិច្ចទាំងនេះ កម្រសម្រេចបានណាស់ក្នុងការអនុវត្តជាក់ស្តែង។ នៅក្នុងប្រព័ន្ធរលួស និងដំណាក់អំពិល ការបែងចែកទឹកមិនទៀងទាត់សោះ ដោយសារហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ និងមិនពេញលេញ ហើយរចនាសម្ព័ន្ធអភិបាលកិច្ចក៏មិនពេញលេញដែរ ព្រោះខ្វះខាតសមត្ថភាពដ៏ចាំបាច់មួយចំនួន[23]។ ការបែងចែកទឹកនៅប្រព័ន្ធស្ទឹងជីនិតធ្វើបានល្អជាងនៅគម្រោងពីរទៀត ប៉ុន្តែការរក្សាទឹកទុក និងការដោះទឹក នៅតែចោទបញ្ហាដោយសារកង្វះប្រឡាយរងទី៣។ នៅក្នុងប្រព័ន្ធទាំងបី ការអភិវឌ្ឍ/ការស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងលើមូលនិធិពីខាងក្រៅ ហើយក្នុងនោះមានប្រព័ន្ធពីរ ដែលមិនទាន់បានស្តារហេដ្ឋារចនាសម្ព័ន្ធមេរួចរាល់ទេ ឯការថែទាំហេដ្ឋារចនាសម្ព័ន្ធស្ទើរតែគ្មានសោះ។ មានមូលហេតុចំបងៗប្រាំ ដែលធ្វើឲ្យគំនិតផ្តួចផ្តើមនានា ដូចជា PIMD ជាដើម ដំណើរការមិនរួចនៅក្នុងបរិបទកម្ពុជា។

មូលហេតុទី១ គឺភាពមិនស៊ីគ្នារវាង ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយនិងមិនពេញលេញ ហើយនិងវិធីសាស្ត្រសហគមន៍មានភាពទន់ខ្សោយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុនាបច្ចុប្បន្ន។ ឧបសគ្គខាងហិរញ្ញវត្ថុ បច្ចេកទេស និងការសម្របសម្រួល បានរាំង សកបទ នៅប្រព័ន្ធទាំងបី មិនឲ្យដំណើរការបានពេញលេញ។ ស្របគ្នានឹងមតិរិះគន់លើ IWRM ការសិក្សានេះទទួលស្គាល់ថា ការស្វែងរកវិនិយោគមូលធនដ៏ចាំបាច់ដើម្បីសម្រេចតាមគោលការណ៍កំពូល គឺជាបញ្ហាមួយធំលើសសមត្ថភាពតែឯងរបស់ សកបទ ដែលជាអង្គភាពថ្នាក់មូលដ្ឋាន។ មូលធននេះគួរប្រើសម្រាប់កែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងពង្រឹងសិទ្ធិអំណាចរបស់អង្គភាពអភិបាលកិច្ចទឹកមូលដ្ឋាន។

ទី២ វិធីសាស្ត្រសហគមន៍បច្ចុប្បន្ន មិនបានគិតគូរពីរចនាសម្ព័ន្ធអំណាចមានស្រាប់នៅកម្ពុជា ដែលជាមរតកនៃបដិវត្តន៍បៃតងនៅទសវត្សរ៍១៩៦០ ដោយក្នុងនោះ ស្ថាប័នគ្រប់គ្រងទឹកនៅមូលដ្ឋាន តែងត្រូវបានមើលរំលង ឬចាត់ទុកថាមិនសូវសំខាន់ ប្រសិនបើមិនស៊ីគ្នានឹងទំហំ និងរបៀបរៀបចំនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តថ្មី។ នៅកម្ពុជា ទីភ្នាក់ងារផ្តល់ជំនួយនានាបានជំរុញគំនិតថា ថ្នាក់ដឹកនាំ សកបទ មិនគួរជាថ្នាក់ដឹកនាំសហគមន៍ដែលមានស្រាប់នោះទេ។ គំនិតនេះមានចំណុចល្អ ដូចជា ការជំរុញឲ្យមានតម្លាភាពជាងមុន និងប្រព័ន្ធត្រួតមើលនិងថ្លឹងអំណាច ជាដើម ប៉ុន្តែវាកាត់បន្ថយ ឥទ្ធិពលវប្បធម៌បែបខ្សែខ្នងដែលចាក់ឫសជ្រៅនៅកម្ពុជា និងកោតខ្លាចដល់អាជ្ញាធរមានស្រាប់ (ឧទាហរណ៍ មេភូមិ មេដឹកនាំក្រុម ក្រយ)។ អង្គភាពអភិបាលកិច្ចថ្នាក់កណ្តាលទើបបង្កើតថ្មីនេះ អាចត្រូវតស៊ូច្រើនដើម្បីពុះពារឆ្លងកាត់បណ្តាញភក្តីភាពដែលមានស្រាប់ ចំពោះរចនាសម្ព័ន្ធអំណាចស្ថិតនៅខាងលើ និងខាងក្រោមខ្លួន នៅក្នុងលំដាប់ថ្នាក់នៃអភិបាលកិច្ចទឹក។ ជាក់ស្តែងនៅក្នុងករណី សកបទ នៃប្រព័ន្ធរលួស កសិករមួយចំនួនយល់ឃើញថា សកបទ នោះ មិនគួរឲ្យទុកចិត្ត មិនមានប្រសិទ្ធភាពឬសមត្ថភាពគ្រប់គ្រាន់ ក្នុងការដោះស្រាយតម្រូវការទឹកស្រោចស្រពរបស់កសិករទេ ហើយម្យ៉ាងទៀត ក៏ពិបាកនឹងឯករាជ្យដាច់ពី PDOWRAM និង ក្រយ ដែរ ព្រោះត្រូវពិគ្រោះយោបល់ និងរាយការណ៍ទៅជូនស្ថាប័នទាំងពីរនេះ។ ជាទូទៅគេគិតថា សមាជិកគណៈកម្មការ សកបទ ទទួលបានការជឿជាក់ និងការគោរពច្រើន ប្រសិនបើជ្រើសរើសចេញពីរចនាសម្ព័ន្ធអំណាចមានស្រាប់ក្នុងសហគមន៍ (ដូចក្នុងករណីប្រព័ន្ធដំណាក់អំពិល)។ ប៉ុន្តែសមាជិក សកបទ ក្នុងប្រព័ន្ធស្ទឹងជីនិតខ្លះ មិនធ្លាប់មានសមាសភាពក្នុងរចនាសម្ព័ន្ធអំណាចទេ ហើយគាត់ទទួលបានជោគជ័យក្នុងការគ្រប់គ្រងធារាសាស្ត្រ។ ដូច្នេះត្រូវរង់ចាំមើលថា តើជោគជ័យនេះ ពឹងផ្អែកទាំងស្រុងទៅលើការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអ្នកផ្តល់ជំនួយ ឬក៏ អាចរក្សាប្រសិទ្ធភាពរបស់ខ្លួនតទៅទៀតបានបន្ទាប់ពីជំនួយទ្រទ្រង់ត្រូវចប់អស់។

---

23 សូមមើលផ្នែកខាងលើ ស្តីពី ភាពមិនស៊ីគ្នារវាងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំអភិបាលកិច្ច។

ទី៣ វិធីសាស្ត្រសហគមន៍បច្ចុប្បន្ន សង្កត់ធ្ងន់លើការចូលរួម និងការពង្រឹង ISF ប៉ុន្តែគោលគំនិតនេះ មិនធ្លាប់មានពីមុនមកទេនៅកម្ពុជា ហើយថែមទាំងមិនស៊ីគ្នានឹងក្រឹត្យក្រមវប្បធម៌នៅកម្ពុជាទៀតផង។ Agrawal and Gibson (1999) បានឲ្យនិយមន័យការចូលរួមរបស់សហគមន៍ ជាការដែលប្រជាជនមូលដ្ឋានមកចូលរួមទាំងអស់គ្នា ដើម្បីកំណត់អាទិភាព បង្កើតបទបញ្ញត្តិ និងគោលនយោបាយក្នុងសហគមន៍ ព្រមទាំងអនុវត្ត និងពង្រឹងអនុវត្តបទបញ្ញត្តិទាំងនោះ។ ស្រដៀងគ្នាដែរ Calaguas and Francis (2004) បានអំពាវនាវឲ្យមានការយកចិត្តទុកដាក់លើ "ធាតុចូលរបស់សហគមន៍នៅគ្រប់ដំណាក់កាលនៃការរចនារៀបចំ កសាង និងថែទាំប្រព័ន្ធធារាសាស្ត្រ" ស្របតាមវិធីសាស្ត្រប្រកបដោយការចូលរួមដ៏ល្អបំផុតមួយ។ ចំណុចនេះ កម្រកើតមានណាស់នៅកម្ពុជា។ ក្នុងប្រព័ន្ធរលួស និងដំណាក់អំពិល កម្រមានការកោះប្រជុំកសិករមកសួរយោបល់ ឬលើកពីក្តីបារម្ភផ្សេងៗណាស់ ហើយនៅពេលមានការកោះប្រជុំជាលក្ខណៈផ្លូវការម្តងៗ (ឧទាហរណ៍ សម្រាប់អង្កេតដល់កន្លែងក្នុងការស្រាវជ្រាវនេះ) កសិករជាច្រើនមិនសូវចង់និយាយតវ៉ាអ្វីនៅចំពោះមុខអាជ្ញាធរទេ ដែលអាចជាចំណុចមួយនៃវប្បធម៌កម្ពុជាដែលចាត់ទុកការតវ៉ាជាសាធារណៈ ជាកាយវិការមិនសមរម្យ។ ក្នុងប្រព័ន្ធដំណាក់អំពិល កសិករមិនសូវបានចូលរួមទេក្នុងការសម្រេចចិត្តដែលហាក់ធ្វើឡើងដោយ PDOWRAM ហើយ សកបទ ហាក់មានតួនាទីរាយការណ៍ទៅថ្នាក់លើ និងរង់ចាំបញ្ជាពី PDOWRAM។ បញ្ហានេះបណ្តាលមួយផ្នែកមកពីប្រព័ន្ធដំណាក់អំពិលធំខ្លាំងពេក ហួសពីសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់សកបទ។ មូលហេតុសំខាន់មួយទៀតគឺ ទម្លាប់រាយការណ៍និងរង់ចាំបញ្ជាពីថ្នាក់លើ បានចាក់ឫសជ្រៅក្នុងវប្បធម៌កម្ពុជា ដោយគេយល់ថា វាជាឥរិយាបថត្រឹមត្រូវសម្រាប់អង្គភាពអភិបាលកិច្ចថ្នាក់ទាប និងមានអំណាចតិចជាង នៅក្នុងប្រព័ន្ធអភិបាលកិច្ចដែលមានឋានានុក្រមនិងបណ្តាញខ្សែខ្នង។ នៅក្នុងប្រព័ន្ធរលួស កសិករមិនសូវទៅចូលរួមបោះឆ្នោតជ្រើសរើសសមាគម សកបទ ទេ ព្រោះគាត់មិនជឿជាក់ថា វាជាយន្តការសម្រាប់ជ្រើសរើសថ្នាក់ដឹកនាំល្អនិងមានសមត្ថភាពដែលអាចដោះស្រាយបញ្ហារបស់គាត់បាន។ ការចូលរួមបង់ ISF ប្រែប្រួលខុសគ្នាពីករណីមួយ ទៅករណីមួយ។ ការស្រាវជ្រាវពីប្រព័ន្ធទាំងបី បានបង្ហាញលទ្ធផលវិជ្ជមាននៃការពង្រឹងអនុវត្តគោលនយោបាយ ISF ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចដ៏ទាបរបស់កសិករជាច្រើន បានបង្កជាការស្មុគស្មាញដល់ការប្រមូល ISF។ ទោះជាការបង់ថ្លៃទឹកស្រោចស្រព មិនទាន់មានច្រើនក្នុងប្រវត្តិសាស្ត្រកម្ពុជាក្តី ក៏ការសិក្សាបង្ហាញថា ប្រជាជនមិនរុញរានឹងបង់ថ្លៃនេះទេ ឲ្យតែអង្គភាពគ្រប់គ្រង (សកបទ) អាចផ្តល់ទឹក និងសេវាហេដ្ឋារចនាសម្ព័ន្ធដល់ពួកគាត់។ ការបង់ថ្លៃទឹកស្រោចស្រពជារឿងថ្មីចំពោះវប្បធម៌កម្ពុជា ប៉ុន្តែការបង់ថ្លៃសេវាទៅឲ្យរដ្ឋអំណាច គឺមិនមែនជារឿងថ្មីឡើយ។

មូលហេតុទី៤ គឺភាពមិនស៊ីគ្នារវាង គោលនយោបាយទឹក និងការអនុវត្តជាក់ស្តែង ក៏ដូចជា ភាពមិនរលូនគ្នាផ្ទៃក្នុងគោលនយោបាយទឹកខ្លួនឯងនោះទៀត។ គោលដៅចម្បងពីររបស់ PIMD គឺផ្តល់ប្រព័ន្ធធារាសាស្ត្រមានប្រសិទ្ធភាព និរន្តរភាព ភាពគួរឲ្យជឿជាក់ និងមិនប៉ះពាល់បរិស្ថាន (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវន្តបានកែលំអឡើង)។ ប៉ុន្តែដូចមានលើកបង្ហាញក្នុងប្រព័ន្ធរលួស និងដំណាក់អំពិល ការអនុវត្តគោលនយោបាយ PIMD ជាទូទៅតែងផ្តោតលើការបង្កើត សកបទ និងកម្រផ្តោតលើការកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួម ឲ្យដល់កម្រិតស្តង់ដារអប្បបរមាណាមួយដែលអាចទទួលយកបានណាស់។ មួយចំណែកទៀត មានការយកចិត្តទុកដាក់តិចតួចទៅលើការបង្កើតប្រព័ន្ធពេញលេញមួយសម្រាប់ជួយទ្រទ្រង់ដល់ សកបទ ដែលមានដូចជា កកបទ សម្រាប់ធ្វើការនៅកម្រិតទាបបំផុត (ឧទាហរណ៍ កម្រិតក្បាលដីកសិដ្ឋាន) និងការបង្កើតក្រុមគាំទ្រមួយ សម្រាប់ធ្វើការចាប់ពីកម្រិតខេត្តចុះមកវិញ។ បញ្ហានេះអាចមកពីខ្លឹមសារនយោបាយទឹកកម្ពុជា មិនទាន់បានជ្រួតជ្រាបដល់កម្រិតអនុវត្តនៅសហគមន៍ ហើយទីភ្នាក់ងារអនុវត្ត PIMD (MOWRAM និងជាពិសេស PDOWRAM) នៅខ្វះសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់អនុវត្តគោលនយោបាយនេះ។ ដូចបានកត់សម្គាល់ពីខាងលើ ក្រោយពេលបង្កើតឡើងហើយ គេតែងរំពឹងឲ្យ សកបទ ដំណើរការបានដោយឯករាជ្យ បើទោះជាពួកគេខ្វះសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្តី។

ឯកសារគោលនយោបាយ PIMD លើកឡើងថា ជោគជ័យនៃកម្មវិធី PIMD ពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាពរបស់ សកបទ ក្នុងការត្រួតត្រា និងផ្តល់ហិរញ្ញប្បទានដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយចីរភាព។ ការស្រាវជ្រាវនេះបង្ហាញថា ក្នុងការអនុវត្តជាក់ស្តែង សកបទ ហាក់មិនសូវមានអំណាច និងប្រសិទ្ធភាពទេ ហើយ

អប្រសិទ្ធភាព និងធនធានតិចតួចរបស់ សកបទ បានប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេក្នុងការកសាងភាពពេញច្បាប់នៅមូលដ្ឋាន។ តួយ៉ាង គណៈកម្មការ សកបទ នៅរលួស មិនបានដឹងពីទំហំនៃអំណាចសម្រេចចិត្តរបស់ខ្លួនទេ។ គោលការណ៍នៃគោលនយោបាយមួយក្នុង PIMD បានចែងថា ប្រជាជនមូលដ្ឋានជាអ្នកកំណត់សេវាទឹកដែលពួកគេត្រូវទទួលបាន និងជាអ្នកជ្រើសរើសអ្នកផ្តល់សេវាឲ្យពួកគេ។ ចំណុចនេះ មានន័យថា ក្រុមហ៊ុនឯកជនដែលប្រុងធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធណាមួយ គួរត្រូវបានជ្រើសរើសដោយ សកបទ។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង សកបទ ក្នុងប្រព័ន្ធរលួស មិនហ៊ានទាំងសាកសួរពីការបង្កើតក្រុមហ៊ុនផ្តល់ទឹកឯកជនថ្មីមួយ នៅក្នុងតំបន់ត្រួតត្រារបស់ខ្លួនផង។ ក្រុមហ៊ុននោះបានទាក់ទងត្រឹមតែអភិបាលខេត្តប៉ុណ្ណោះ ហើយបន្ទាប់មកក៏បានរកកន្លែងមួយនៅក្នុងឃុំ សម្រាប់ធ្វើប្រតិបត្តិការរបស់ខ្លួន។ អ្វីដែល សកបទ (និង ក្រឃ) អាចធ្វើបាន គឺស្នើឲ្យក្រុមហ៊ុនទៅចុះបញ្ជីនៅឯ PDOWRAM។ នេះជាឧទាហរណ៍មួយ បង្ហាញពីវប្បធម៌នយោបាយនៅកម្ពុជាបង្កភាពស្រពេចស្រពិលដល់កម្រិតព្រំដែនបទបញ្ញត្តិនៃក្របខ័ណ្ឌច្បាប់។

ក្នុងប្រព័ន្ធដំណាក់អំពិល សកបទ ត្រូវជាប់ផុងក្នុងអន្ទាក់វប្បធម៌-នយោបាយ ដោយមិនហ៊ានសម្រេចចិត្តអ្វី មុនពេលបានពិគ្រោះយោបល់ជាមួយ PDOWRAM សោះទេ។ ឥរិយាបថនេះងាយធ្វើឲ្យគេយល់ឃើញថា គណៈកម្មការ សកបទ ជាដៃខ្វែងមួយរបស់ MOWRAM/PDOWRAM សម្រាប់មើលខុសត្រូវលើមុខងារ ដូចជា ការប្រមូល និងរាយការណ៍ស្ថិតិ និងព័ត៌មានផ្សេងៗលើសហគមន៍ ទៅឲ្យ PDOWRAM គឺមិនត្រឹមត្រូវតាមគោលគំនិតនៃគណៈកម្មការគ្រប់គ្រងមូលដ្ឋានដ៏ប្រសើរដូចមានចែងក្នុង PIMD និងក្នុងគោលនយោបាយទឹកនោះទេ។ Kim and Ojendal (2007) បានសង្កេតឃើញថា "(នៅកម្ពុជា) ប្រជាធិបតេយ្យភាវូបនីយកម្មនៃស្ថាប័ននយោបាយ បានជឿនលឿនលើសពី ប្រជាធិបតេយ្យភាវូបនីយកម្មនៃកិច្ចការនយោបាយនៅមូលដ្ឋានជាខ្លាំង"។

មូលហេតុទី៥ គឺលក្ខណៈគ្មានការសម្របសម្រួលគ្នារវាងកំណែទម្រង់គោលនយោបាយផ្សេងៗនៅកម្ពុជា។ ថ្វីបើមានកំណែទម្រង់ពាក់ព័ន្ធគ្នាជាច្រើននៅកម្ពុជាក្តី ប៉ុន្តែការអនុវត្តគ្មានលំដាប់លំដោយជាក់លាក់ទេ និងនាំឲ្យស្ទះដល់ដំណើរការទាំងមូល។ បញ្ហានេះអាចបង្កជាផលវិបាកពីរគឺ៖ កំណែទម្រង់ជាអន្លើៗមួយខ្សែ ឬការជាប់គាំងជាទូទៅបណ្តាលមកពីរបៀបរៀបចំស្ថាប័ន បែបតូចចង្អៀតធ្វើឲ្យកំណែទម្រង់នានាមិនអាចទទួលបានផ្លែផ្កាពេញលេញ (Horng & Craig 2008)។ តួយ៉ាង គេបានទទួលស្គាល់ថា គោលនយោបាយ PIMD គួរផ្តោតការយកចិត្តទុកដាក់ឲ្យហួសពីការរៀបចំសកបទទៅដល់ការកសាងឡើងវិញនូវប្រព័ន្ធទ្រទ្រង់សកបទតាមរយៈការកំណត់តួនាទីថ្មីៗសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលជាប់ពាក់ព័ន្ធ។ ប៉ុន្តែទិន្នន័យជាក់ស្តែងបង្ហាញថា មុខងារកសាងប្រព័ន្ធទ្រទ្រង់ឡើងវិញដូចបញ្ជាក់ខាងលើច្រើនតែត្រូវបានបំបាត់ចោលបើសិនពុំមានហិរញ្ញប្បទានគ្រប់គ្រាន់ (ដូចក្នុងករណីប្រព័ន្ធរលួស និងដំណាក់អំពិល)។ សកបទ ដំណើរការដោយផ្អែកលើកំណែទម្រង់គោលនយោបាយ PIMD/IMT របស់ MOWRAM ក៏ពិតមែន ប៉ុន្តែមានកិច្ចប្រឹងប្រែងតិចតួចណាស់ក្នុងការដាក់បញ្ចូលគោលនយោបាយនេះ ទៅក្នុងកំណែទម្រង់វិមជ្ឈការមេដែលកំណត់ការផ្ទេរទំនួលខុសត្រូវគ្រប់គ្រងធនធានធម្មជាតិ ទៅឲ្យអាជ្ញាធរសហគមន៍។ គោលនយោបាយទឹកមិនបានកំណត់ទេថាតើ ឃុំ និង សកបទ គួរធ្វើការជាមួយគ្នាយ៉ាងណា និងតើ PDOWRAM អាចចូលរួមក្នុងដំណើរការនេះយ៉ាងដូចម្តេច។ លទ្ធផលស្រាវជ្រាវនៅប្រព័ន្ធរលួស និងស្ទឹងជីនិត បង្ហាញថា សកបទ កម្របានជួបជាមួយ ក្រឃ ដើម្បីពិភាក្សាគ្នារកដំណោះស្រាយបញ្ហាណាស់។ ផ្ទុយទៅវិញ សកបទ គ្រាន់តែរាយការណ៍ពីបញ្ហាផ្សេងៗទៅជូន ក្រឃ ឬជារឿយៗតិចជាងទៅកាន់ PDOWRAM ដែលពួកគេគិតថា មានលទ្ធភាព និងជាប់ពាក់ព័ន្ធខ្លាំងជាង។ ការធ្វើសមាហរណកម្មរវាង អង្គភាពអភិបាលកិច្ចរបស់ ក្រឃ និង សកបទ ដូចបានឃើញក្នុងករណីប្រព័ន្ធដំណាក់អំពិល អាចជាដំណោះស្រាយមួយសម្រាប់កែលំអកង្វះខាតការសម្របសម្រួលផ្នែកអភិបាលកិច្ចនៅមូលដ្ឋាន។

នៅក្នុងក្របខ័ណ្ឌវិមជ្ឈការដ៏ធំទូលាយ នៅមានកិច្ចការជាច្រើនដែលត្រូវអនុវត្ត មុននឹងអាចដាក់បញ្ចូលគោលនយោបាយ PIMD/IMT ទៅក្នុងកំណែទម្រង់ D&D ថ្នាក់ជាតិ។ របាយការណ៍របស់គណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ (NCDD 2010) បានលើកថា ជាមធ្យមប្រហែលតែ ១០% ប៉ុណ្ណោះនៃមូលនិធិ

ឃុំសង្កាត់ ដែលបានយកទៅប្រើក្នុងការអភិវឌ្ឍជាប់ទាក់ទងនឹងធារាសាស្ត្រ ប៉ុន្តែរហូតដល់ ៩៥% នៃមូលនិធិស្រុកត្រូវបានវិនិយោគទៅលើប្រព័ន្ធធារាសាស្ត្រជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៦ មក។ ករណីសិក្សានៅប្រព័ន្ធរលួស និងដំណាក់អំពិល បានពិនិត្យខ្លះៗពីការចូលរួមរបស់ ក្រឃ នៅក្នុងការងារធារាសាស្ត្ររបស់សហគមន៍ដែរ ប៉ុន្តែការសិក្សានេះមិនបានពិនិត្យពីតួនាទីរបស់ស្រុក ក្នុងផ្នែកសេវាកសិកម្ម និងធារាសាស្ត្រនោះទេ។ ចំណុចនេះ អាចជាកង្វះខាតមួយនៃការសិក្សា ហើយក៏អាចមានន័យថា រដ្ឋអំណាចស្រុក មិនសូវបានចូលរួមពាក់ព័ន្ធច្រើនក្នុងប្រព័ន្ធធារាសាស្ត្រដែលបានសិក្សាទេ។ ប្រសិនបើសេណារីយ៉ូទី១ ត្រឹមត្រូវ គឺត្រូវមានការសិក្សាបន្ថែមក្នុងវិស័យនេះ ហើយវាកាន់តែមានប្រយោជន៍ទៀតនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកម្មវិធីវិមជ្ឈការថ្នាក់ជាតិ (២០០៩-២០១៩) ដែលកំពុងផ្តោតលើ ការកែលំអរចនាសម្ព័ន្ធអភិបាលកិច្ច និងធនធានមនុស្សនៅកម្រិតស្រុក និងខេត្ត ដើម្បីជំរុញការអនុវត្តរបស់អង្គភាពអភិបាលកិច្ចទាំងនោះ និងជួយ ក្រឃ ក្នុងការផ្តល់សេវាកម្មផ្សេងៗទៅឲ្យប្រជាជន (NCDD 2010)។ តាមការអនុវត្តបែបនេះ មុខងារ និងការបែងចែកហិរញ្ញវត្ថុនៅកម្រិតស្រុក និងខេត្ត មិនអាចមើលរំលងទៀតបានទេ ហើយទំនាក់ទំនងរវាងថ្នាក់ស្រុក និងសេវាធារាសាស្ត្រ ក៏កាន់តែសំខាន់ឡើងដែរ។

បញ្ហាចម្បងចុងក្រោយនៅក្នុងកំណែទម្រង់គ្មានការសម្របសម្រួលគ្នាទាំងនេះ វាស្ថិតនៅខាងក្រៅកំណែទម្រង់វិមជ្ឈការ ហើយរួមមាន គោលនយោបាយកំណែទម្រង់នៅក្នុងក្រសួងជំនាញពាក់ព័ន្ធផ្សេងៗ ដូចជាខាង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាដើម។ ដូចមានបង្ហាញក្នុងផ្នែកការសិក្សាឯកសារមានស្រាប់ IWRM គួបផ្សំនូវទស្សនវិស័យរបស់អ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីបង្កើនការប្រើប្រាស់ទឹកសម្រាប់ផ្នែកសង្គម សេដ្ឋកិច្ច និងអេកូឡូស៊ីឲ្យបានច្រើនបំផុត។ តាមទស្សនៈនេះ ការគ្រប់គ្រង និងអភិវឌ្ឍទឹក គួររួមមានបញ្ចូលអ្នកប្រើប្រាស់ អ្នកធ្វើផែនការ និងអ្នកបង្កើតគោលនយោបាយនៅគ្រប់កម្រិត (ICWE 1992)។ ប៉ុន្តែគំនិតដ៏ខ្ពង់ខ្ពស់នេះ ពិបាកនឹងសម្រេចបានណាស់។ តួយ៉ាង នៅក្នុងបរិបទប្រទេសកម្ពុជា គេបានអនុម័តយកវិធីសាស្ត្រសហគមន៍ ដើម្បីគ្រប់គ្រងស្ទើរតែគ្រប់ប្រភេទនៃធនធានធម្មជាតិ ពោលគឺ សហគមន៍នេសាទ និង សហគមន៍ព្រៃឈើ។ ហើយដោយសារ ការនេសាទ ព្រៃឈើ និងផ្លូវទឹក តែងមានទំនាក់ទំនងគ្នានោះ គេមានចម្ងល់ថា តើស្ថានការណ៍នឹងក្លាយជាយ៉ាងណា ប្រសិនបើសហគមន៍ទាំងនោះ បង្ហាញភក្តីភាពតែចំពោះទីភ្នាក់ងារជំនាញរបស់ខ្លួន ជាពិសេសនៅពេលដែលការសម្របសម្រួលនៅក្នុង និងរវាងទីភ្នាក់ងារទាំងនោះ មានភាពទន់ខ្សោយនៅគ្រប់កម្រិត។ Ojendal (2000) បានកត់សម្គាល់ បញ្ហាប្រឈមបីនៅកម្រិតជាតិ ដែលរារាំងក្រសួងនានាមិនឲ្យធ្វើការស៊ីចង្វាក់គ្នាល្អគឺៈ ១) ស្ថានភាពក្មេងខ្ចី ២) ការប្រាស្រ័យទាក់ទងកម្រិតទាបរវាងក្រសួងនានា ដែលជួនកាលនាំឲ្យមានបញ្ហានយោបាយចូលលាយឡំច្រើនផង ក្នុងផ្នែករដ្ឋបាលនៃក្រសួងនីមួយៗ (បង្កើនការខ្វែងមតិរវាងក្រសួង) និង ៣) ការផ្តល់ហិរញ្ញប្បទានមិនស៊ីគ្នាពីសំណាក់អ្នកផ្តល់ជំនួយ (បង្កើតជាការច្រណែន និងការប្រកួតប្រជែង)។ នាបច្ចុប្បន្ន បញ្ហាចោទខាងការសម្របសម្រួលទាំងនេះ មានច្បាប់រៀបចំអង្គការ សម្រាប់ជួយដោះស្រាយ តាមរយៈការបង្កើតរដ្ឋបាលឯកភាពមួយនៅកម្រិតស្រុក និងខេត្ត។ ដូចបានគ្រោងទុក រដ្ឋាភិបាលកំពុងប្រឹងប្រែងធ្វើការកែលំអធនធានមនុស្ស និងរចនាសម្ព័ន្ធនៅកម្រិតអភិបាលកិច្ចទាំងពីរ ជាមុនសិន។ គេមិនទាន់ដឹងនៅឡើយទេថា តើរដ្ឋបាលឯកភាពនោះ នឹងមានដំណើរការល្អ ហើយអាចដោះស្រាយបញ្ហាសម្របសម្រួលដែលកំពុងមានសព្វថ្ងៃនៅកម្ពុជាបាន ឬមិនបាននោះទេ។

សង្ខេបមក ក្រៅពីភាពមិនចុះសម្រុងគ្នារវាងហេដ្ឋារចនាសម្ព័ន្ធ និងការអនុវត្តអភិបាលកិច្ចនាបច្ចុប្បន្ន នៅមានបញ្ហាច្រើនទៀតនាំឲ្យអភិបាលកិច្ចតាមទ្រឹស្តី និងការអនុវត្តជាក់ស្តែង មិនសូវស៊ីគ្នា។ បញ្ហាខ្លះអាចដោះស្រាយបាននៅកម្រិតមូលដ្ឋាន តាមការកែសម្រួលបន្តិចបន្តួចលើការអនុវត្ត (ឧទាហរណ៍ ការបញ្ចូល សកបទ ក្នុងរចនាសម្ព័ន្ធអំណាចដែលមានស្រាប់) ប៉ុន្តែបញ្ហាខ្លះទៀត ត្រូវការពេលវែងដើម្បីដោះស្រាយ (ឧទាហរណ៍ ការលើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងផ្អែកលើសហគមន៍ និងលទ្ធិប្រជាធិបតេយ្យនៅតាមសហគមន៍ ដើម្បីឲ្យប្រជាជនបានយល់ដឹង និងទទួលស្គាល់ទាំងសិទ្ធិ និងទំនួលខុសត្រូវរបស់ខ្លួនក្នុងឋានៈជាសមាជិកសហគមន៍)។ បញ្ហាផ្សេងទៀត ត្រូវការកិច្ចប្រឹងប្រែងខ្លាំងជាងមុនពីសំណាក់អង្គភាពរដ្ឋាភិបាលថ្នាក់លើ និងថ្នាក់ក្រោម (ឧទាហរណ៍ ការកែសម្រួលនយោបាយទឹក និងធ្វើឲ្យងាយអនុវត្ត និងងាយបត់បែនបានទៅតាមបរិយាកាសនៅមូលដ្ឋាន និងកំហិតច្រើនបែបយ៉ាង) ឬឆន្ទៈនយោបាយ

ខ្លាំងជាងមុនពីគ្រប់កម្រិត (ឧទាហរណ៍ ដើម្បីសម្របសម្រួលគោលនយោបាយកំណែទម្រង់ផ្សេងៗ នៅក្រោមក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការមេ)។ បញ្ហាទាំងនេះ ក៏ដូចជាបញ្ហាបានលើកឡើងក្នុងវគ្គ១ ជំពូកនេះដែរ គឺពិបាកនឹងដោះស្រាយបានក្នុងរយៈពេលខ្លី និងមធ្យម ប៉ុន្តែបើមើលរំលងនោះ វារារាំងដល់ដំណើរការនៃកម្មវិធីអភិវឌ្ឍន៍ធារាសាស្ត្រជាតិ។

## ៦.៣ សេចក្តីសន្និដ្ឋាន យោបល់ និងការស្រាវជ្រាវបន្ថែម

ការសិក្សានេះ បានរកឃើញគំលាតរវាង ការអនុវត្តអភិបាលកិច្ចជាក់ស្តែង គោលការណ៍អភិបាលកិច្ចដ៏ប្រសើរ ដូចមានចែងក្នុង PIMD និង IWRM និងបរិបទហេដ្ឋារចនាសម្ព័ន្ធនិងដែនភូមិសាស្ត្រនៃប្រព័ន្ធធារាសាស្ត្រ។ ដោយឡែក ការសិក្សាបានសង្កេតឃើញថា តំបន់ស្រោចស្រពធំធេងពេក បើធៀបនឹងធនធានមនុស្សនៅក្នុង សកបទ ជាពិសេសក្នុងស្ថានភាពកំពុងខ្វះខាតចំណេះដឹងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុ សម្រាប់ការជួសជុល អភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រព័ន្ធនីមួយៗ។ ទី២ ការគ្រប់គ្រងធារាសាស្ត្រជាក់ស្តែងនៅកម្រិតប្រព័ន្ធ និងអនុប្រព័ន្ធ បានឃ្លាតឆ្ងាយពីគោលការណ៍នៃ PIMD និង IWRM។ ឧទាហរណ៍ តួនាទីជាក់ស្តែងរបស់ សកបទ មិនបានពេញលេញតាមមុខងារជាផ្លូវការទេ ហើយក៏បំពេញមិនបានល្អដែរ។ តួនាទីខ្លាំងបំផុតរបស់ សកបទ តាមការពិនិត្យឃើញក្នុងប្រព័ន្ធជាករណីសិក្សាទាំង៣ មិនមែនជាមុខងារចម្បងត្រូវគ្រប់គ្រងប្រព័ន្ធឲ្យបានល្អនោះទេ ប៉ុន្តែគឺតួនាទីជាអ្នកសម្របសម្រួលរវាងកសិករ និង PDOWRAM។ តួនាទីផ្សេងទៀតរបស់ សកបទ រួមមាន ការបែងចែកទឹកពីប្រឡាយរងទី១ និងទី២ ការដោះស្រាយទំនាស់រវាងកសិករ និង ការប្រមូល ISF។ ទោះយ៉ាងនេះក្តី ការអនុវត្តមុខងារទាំងនេះ មិនបានទៀងទាត់ទេ និងតែងខ្វះមុខខ្វះក្រោយ។ ទោះបីមានគំលាតច្រើនដូច្នេះក្តី ក៏ការសិក្សាបានគូសបញ្ជាក់ពីគុណភាពនៃទំនាក់ទំនងចាក់ស្រេះរវាងសមាសភាគទាំងបីខាងលើនៃការគ្រប់គ្រងធារាសាស្ត្រ ថាជាកត្តាគន្លឹះមួយនៃអភិបាលកិច្ចធារាសាស្ត្រល្អនៅកម្រិតមូលដ្ឋាន។

ការសិក្សានេះក៏បានកត់សម្គាល់កត្តាចម្បងៗពីរ នៃគំលាតរវាង ការអនុវត្តអភិបាលកិច្ចជាក់ស្តែង និងគោលការណ៍អភិបាលកិច្ចដ៏ប្រសើរ។ កត្តាទី១ ទាក់ទងនឹងភាពស្មុគស្មាញផ្នែករូបវ័ន្ត សេដ្ឋកិច្ច សង្គម និងបរិស្ថាននៃទឹកស្រោចស្រពដែលជាសារធាតុមានលំហូរ និងមានចំណងទាក់ទងច្រើន។ លក្ខណៈនេះធ្វើឲ្យអភិបាលកិច្ចទឹកស្រោចស្រពកាន់តែស្មុគស្មាញ និងពាក់ព័ន្ធដល់ច្រើនវិស័យ ជាងការរំពឹងទុកនៅពេលតាក់តែងគោលនយោបាយអភិបាលកិច្ចដ៏ប្រសើរបំផុតនោះ។ ដើម្បីបង្កើតគោលនយោបាយរបៀបនេះ ក៏ត្រូវគិតគូរខ្លាំងដែរពីការសម្របសម្រួលឆ្លងកាត់វិស័យផ្សេងៗ (ឧទាហរណ៍ ក្រសួងនានា)។ កត្តាទី២ គឺវប្បធម៌នយោបាយស្មុគស្មាញរបស់កម្ពុជា ដែលជារឿយៗស្ថាប័នផ្លូវការតែងទន់ខ្សោយ និងជាប់លាយឡំជាមួយរបៀបរបបមិនផ្លូវការ ជំរុញដោយបណ្តាញខ្សែខ្នង និងគណបក្ស។ របៀបរបបក្រៅផ្លូវការទាំងនេះ មានឥទ្ធិពលខ្លាំងនៅក្នុងអភិបាលកិច្ចធារាសាស្ត្រជាក់ស្តែង។ ដើម្បីធ្វើឲ្យស្ថាប័នផ្លូវការនៅមូលដ្ឋាន មានអំណាចខ្លាំងឡើងនៅក្នុងបរិបទនេះ ត្រូវបញ្ចូលស្ថាប័នទាំងនេះទៅក្នុងរចនាសម្ព័ន្ធអំណាចដែលមានស្រាប់នៅក្នុងសហគមន៍។ ការងារនេះ អាចសម្រេចបានតាមរយៈការកំណត់ និងតែងតាំងថ្នាក់ដឹកនាំមានប្រជាប្រិយភាពល្អ ទៅក្នុងស្ថាប័នទាំងនោះ។

ការសិក្សាក្រោយៗទៀតខាងការគ្រប់គ្រងធារាសាស្ត្រ គួរពិនិត្យធនធានទឹកក្នុងលក្ខណៈជាសមាសធាតុដ៏សំខាន់សម្រាប់សេដ្ឋកិច្ច សង្គម បរិស្ថាន និងតំបន់ភូមិសាស្ត្រ។ ការពិនិត្យបែបនេះ ធ្វើឲ្យការស្រាវជ្រាវអំពីអភិបាលកិច្ចធារាសាស្ត្រកាន់តែស្មុគស្មាញ ប៉ុន្តែសំខាន់ឡើង។ អង្គភាពរដ្ឋអំណាចស្រុក និងខេត្ត មិនស្ថិតក្នុងកម្មវត្ថុនៃការសិក្សានេះទេ ប៉ុន្តែគេគិតថា នឹងសំខាន់ខ្លាំងណាស់សម្រាប់ដំណាក់កាលបន្ទាប់នៃ ការអនុវត្តវិមជ្ឈការទាក់ទងនឹងការផ្តល់សេវាកម្មដល់ប្រជាជន (NCDD 2010)។ ដូច្នេះ ត្រូវមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីកំណត់តួនាទីរបស់អង្គភាពទាំងនេះ។ ម្យ៉ាងទៀត ដោយមានសារភាពមិនស៊ីគ្នារវាង ចំណុចមានចែងក្នុងគោលនយោបាយអភិបាលកិច្ចទឹក និងការអនុវត្តជាក់ស្តែងនោះ គួរមានការសិក្សាបន្ថែមទៀតពីភាពខុសគ្នារវាងគោលនយោបាយទាំងនោះ និងការអនុវត្តជាក់ស្តែងដោយអង្គភាពជំនាញតាមវិស័យផ្សេងៗ នៅក្នុងបរិបទធំទូលាយនៃការគ្រប់គ្រងធនធានធម្មជាតិ។

# ៧ អនុសាសន៍គោលនយោបាយ

ការផ្លាស់ប្តូរត្រូវធ្វើឡើងឆ្លងតាមអ្នកពាក់ព័ន្ធផ្សេងៗនៅកម្រិតមូលដ្ឋាន និងកម្រិតខាងលើឯទៀត ដើម្បីកាត់បន្ថយកង្វះភាពស៊ីគ្នារវាង ការអនុវត្តអភិបាលកិច្ចជាក់ស្តែង និងគោលការណ៍ដ៏ប្រសើរបំផុត ក៏ដូចជា រវាងទំហំនៃប្រព័ន្ធធារាសាស្ត្របវ័ន្ត និងការរចនារៀបចំប្រព័ន្ធអភិបាលកិច្ច។ ការកាត់បន្ថយភាពមិនស៊ីគ្នានេះ នឹងបង្កើនផលិតភាពកសិកម្ម លើកកម្ពស់ជីវភាពរស់នៅ និងពន្លឿនដំណើរការឈានទៅសម្រេចគោលដៅជាតិនៃការអភិវឌ្ឍធារាសាស្ត្រ និងការកាត់បន្ថយភាពក្រីក្រ។ អនុសាសន៍ជាក់លាក់មួយចំនួនដែលផុសចេញពីការសិក្សានេះ មានដូចតទៅ៖

**នៅកម្រិតមូលដ្ឋាន៖**

- ដាក់បញ្ចូល សកបទ ទៅក្នុងរចនាសម្ព័ន្ធអំណាចមានស្រាប់នៅក្នុងសហគមន៍ តាមរយៈការតែងតាំងថ្នាក់ដឹកនាំក្រុម មេភូមិ និង ក្រុយ (ពោលគឺ ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដែលមានស្រាប់) ឬថ្នាក់ដឹកនាំជាប្រពៃណី (ឧទាហរណ៍ អាចារ្យ អតីតថ្នាក់ដឹកនាំរដ្ឋអំណាចនៅមូលដ្ឋាន ចាស់ទុំ) និងបុគ្គលមានទម្លាប់និយាយចេញពីគំនិតខ្លួននិងមានជំនាញដឹកនាំ ឲ្យចូលទៅក្នុង សកបទ ដើម្បីធ្វើការជាមួយ ទំនាក់ទំនងខ្សែខ្នងដែលបានចាក់ឫសនៅក្នុងវប្បធម៌កម្ពុជា។
- កេណ្ឌប្រមូលកសិករឲ្យចូលរួមក្នុង កកបទ ដែលមានដំណើរការជាក់ស្តែង ហើយថ្នាក់ដឹកនាំរបស់ កកបទ ទាំងឡាយ ត្រូវបញ្ចូលសមាសភាពទៅក្នុង សកបទ។
- កាត់បន្ថយទំហំផ្ទៃដីស្រោចស្រពត្រូវគ្រប់គ្រង ឬបង្កើនទំហំ សកបទ ដោយទទួលយកតំណាងមកពីឃុំ និងភូមិនានានៅក្នុងប្រព័ន្ធធារាសាស្ត្រ។
- ធ្វើការផ្សព្វផ្សាយចំណេះដឹងឲ្យបានកាន់តែធំទូលាយពី សិទ្ធិ និងទំនួលខុសត្រូវរបស់កសិករ ទាក់ទងនឹងប្រព័ន្ធធារាសាស្ត្រនិងការគ្រប់គ្រងប្រព័ន្ធដូចមានចែងក្នុងគោលនយោបាយPIMDដើម្បីបណ្តុះស្មារតីជាម្ចាស់ និងឆន្ទៈចូលរួមរបស់កសិករ។
- ធ្វើការផ្សព្វផ្សាយចំណេះដឹងឲ្យបានកាន់តែធំទូលាយពីគោលដៅ និងភាពចាំបាច់នៃវិភាគទាន ISF ពីកសិករទាំងឡាយ។
- ជួយសម្រួលឲ្យមានទំនាក់ទំនងមិនផ្លូវការកាន់តែច្រើនរវាង សកបទ និងកសិករ ដើម្បីបង្កើនទំនុកចិត្តចំពោះអង្គភាពអភិបាលកិច្ច និងសមត្ថភាពសង្គមនៅក្នុងប្រព័ន្ធ។

**នៅកម្រិតក្រោមជាតិ** (**រួមទាំង** NGOs)៖

- អនុវត្តការកសាងយុទ្ធសាស្ត្រប្រាកដនិយមសម្រាប់ការចាកចេញទៅវិញនៃ ទីភ្នាក់ងារផ្តល់ជំនួយ តាំងពីពេលចាប់ផ្តើមគម្រោង ដើម្បីធានាឲ្យប្រព័ន្ធមាននិរន្តរភាព ក្រោយពេលមូលនិធិបានពីអ្នកផ្តល់ជំនួយត្រូវចប់។
- បង្រួបបង្រួមផ្នែករដ្ឋបាល តាមរយៈ ការលើកទឹកចិត្ត ការតែងច្បាប់ និងការពង្រឹងការប្តេជ្ញាចិត្ត និងការរួមចំណែកខ្លាំងជាងមុន ពីសំណាក់អង្គភាពអភិបាលកិច្ចកម្រិតស្រុក និងខេត្ត ក្នុងការសម្របសម្រួលប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងបញ្ហានានាជាប់ទាក់ទងនឹង ការចែកចាយទឹកនៅកម្រិតផ្ទៃរងទឹកភ្លៀង (ឧទាហរណ៍ រវាងអ្នកប្រើប្រាស់នៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម)។ ការរួមចំណែករបស់ពួក

គេ ជាមួយនឹងប្រព័ន្ធរដ្ឋាភិបាលមេ ត្រូវរៀបចំឲ្យមានដំណើរការក្នុងរយៈពេលវែង ដើម្បីជំរុញការផ្លាស់ប្តូរជាលក្ខណៈស្ថាប័ន នៅក្នុងប្រព័ន្ធរដ្ឋាភិបាល។

- ផ្សព្វផ្សាយចំណេះដឹង ស្តីពីជលសាស្ត្រកម្រិតមូលដ្ឋាន ទៅឲ្យ សកបទ និងអាជ្ញាធរមូលដ្ឋានដទៃទៀត ដើម្បីជួយឲ្យមានការបែងចែកទឹកប្រកបដោយទំនួលខុសត្រូវលើបរិស្ថាន និងមានប្រសិទ្ធភាពសម្រាប់កសិកម្ម។

**នៅកម្រិតជាតិ៖**

- កែសម្រួលគោលនយោបាយ និងជំរុញឲ្យមានការសម្របសម្រួលកាន់តែច្រើនរវាងក្រសួងជំនាញផ្សេងៗ ដោយហេតុថា ទឹកជាសារធាតុមានលំហូរ និងមានចំណងទាក់ទងច្រើន នឹងផ្នែករូបវន្ត សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ លក្ខណៈនេះធ្វើឲ្យ អភិបាលកិច្ចទឹក កាន់តែស្មុគស្មាញ និងពាក់ព័ន្ធច្រើនដល់វិស័យ ច្រើនជាងការរំពឹងទុកនៅពេលកំពុងតាក់តែងគោលនយោបាយអភិបាលកិច្ចបច្ចុប្បន្ន។

- ផ្តល់ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់ ការកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រពេញលេញ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធពេញលេញនោះ នៅពេលដែលបន្ទុកចំណាយវាធំហួសពីសមត្ថភាពរបស់សហគមន៍។

- ពង្រឹងដល់ការអនុវត្តកំណែទម្រង់វិសហមជ្ឈការ ដើម្បីឲ្យកំណែទម្រង់នេះ អាចជួយទ្រទ្រង់ដល់រដ្ឋបាលមូលដ្ឋាន។

# ឯកសារយោង

Agrawal A. & C.C. Gibson (1999), “Enchantment and disenchantment: the role of community in natural resource conservation”, World Development, 27(4), pp. 629-649

Arnstein, S. R. (1969), “A ladder of citizen participation”, *Journal of the American Planning Association* 35 (4), pp. 216-224

Asian Development Bank (2008), *Cambodia: Water Resources Management (Sector) Project*, Technical Assisstance Consultant’s Report (TA no. 4848) pp. 759

Barker, R. & F. Molle (2004), *Evolution of Irrigation in South and Southeast Asia*, Comprehensive Research Report No. 5, International Water Management Institute, pp. 45

Calaguas, B. & J. Francis (2004), “Community Capacity Building and Empowerment: Wasting Resources or Ensuring Sustainability?” In ADB (ed.), *Water and Poverty: The Themes – A Collection of Thematic Papers* (Asian Development Bank: Kyoto, Japan)

Chea, C. (2010), *The Governance of the Common Pool Resource: The Case of Irrigation Water in Cambodia,* Working paper 47 (Phnom Penh: Cambodia Development Resource Institute)

Coward, E. W. (1976), “Indigenous Organisation, Bureaucracy and Development: The Case of Irrigation”, *Journal of Development Studies* 13 (1), pp. 92-105

Curran, T. (1971), “Water Resources Management in the Public Interest”, *Journal of the American Water Resources Association* 7 (1), pp. 33-39

Global Water Partnership – Technical Advisory Committee (2000), “Integrated Water Resources Management”, *TAC Background Papers* No. 4 (Stockholm: GWP-TAC)

Global Water Partnership (2002), *Introducing Effective Water Governance* (Stockholm: GWP)

Horng, V. & D. Craig (2008), Accountability and Planning in DecentraliSed Cambodia, Working Paper 39 (Phnom Penh: CDRI)

International Conference on Water and the Environment (1992), “The Dublin statement and report of the conference”, International Conference on Water and the Environment: Development Issues for the 21st century, 26–31 January, Dublin, Ireland

International Water Management Institute (2007), “IWRM Challenges in Developing Countries: Lessons from India and elsewhere”, *IWMI Water Policy Briefing* 24 (January 2007) (Colombo, Sri Lanka: IWMI)

IWA/UNEP (2002), *Industry as a Partner for Sustainable Development: Water Management* (London: IWA/UNEP)

Janssen M. A. (2007), “Coordination in irrigation systems: an analysis of the Lansing Kremer model in Bali”, *Agricultural Systems,* Vol. 93, pp. 170-190

Jeffrey, P. & M. Gearey (2006), “Integrated Water Resources Management: lost on the road from ambition to realisation?” *Water Science and Technology* 53 (1), pp. 1-8

Jonker, L. (2002), “Integrated water resources management: theory, practice, cases”, *Physics and Chemistry of the Earth,* 27, pp. 719–720

Kim, S. & J. Ojendal (2007), *Where Decentralization Meets Democracy: Civil Society, Local Government, and Accountability in Cambodia,* Working Paper 35 (Phnom Penh: CDRI)

Lansing J. S. (1987), “Balinese ‘Water Temples’ and the Management of Irrigation”, *American Anthropologist* 89 (2), pp. 326-341

Lansing, J.S. & J.N. Kremer (1993), “Emergent properties of Balinese water temples”, *American Anthropologist* 95 (1), pp. 97–114

Li, T. (2006), *Neo-Liberal Strategies of Governance through Community: The Social Development Programme of the World Bank in Indonesia,* IILJ Working Paper 2006/2 (New York: New York University School of Law)

Living River Siam (2010), “Lower Mekong Dams”, *Living River Siam,* http://www.livingriversiam.org/mk/_sub-eng-lowerdam.html (accessed 4 September 2010)

Molden, D. (2007), *Water for Food*, *Water for Life: A Comprehensive Assessment of Water Management in Agriculture* (London: Earthscan)

Molle, F., T. Foran & P. Floch (2009), “Introduction: Changing Waterscapes in the Mekong Region - Historical Background and Context”, in: F. Molle, T. Foran and M. Käkönen (eds.) *Contested Waterscapes in the Mekong Region: Hydropower, Livelihoods and Governance* (London: Earthscan)

Mollinga, P. (2008), “Water, Politics and Development: Framing a Political Sociology of Water Resources Management”, *Water Alternatives* 1 (1), pp. 7-23

Moore, E. (1989), “Water Management in Early Cambodia: Evidence from Aerial Photography”, *Geographical Journal* 155 (2), pp. 204-214

MOWRAM (1999), Circular No.01, 11 January 1999 on the “Implementation Policy of Sustainable Irrigation Systems” (Phnom Penh: MOWRAM)

National Programme for Sub-national Democratic Development (2010), *Implementation Plan First Three Years (2011-2013)* (Phnom Penh: NCDD)

Ojendal, J. (2000), *Sharing the Good: Modes of Managing Water Resources in the LowerMekong River Basin*, (Stockholm: Göteborg University Department of Peace and Development Research)

Ostrom E. (1999), “Design principles in long-enduring irrigation institutions”, in *Polycentric Governance and Development: readings from the workshop in Political Theory and Policy Analysis* (University of Michigan Press) pp. 432

Ostrom, E. (1992), *Crafting Institutions for Self-Governing Irrigation Systems* (San Francisco, CA: ICS Press)

Ovesen, J., I.B.Trankell, & J. Ojendal (1996), *When Every Household is an Island: Social Organization and Power Structures in Rural Cambodia* (Stockolm: Uppsala University/Sida)

Reisner, M. (1986), *Cadillac Desert: The American West and its Disappearing Water* (New York: Viking)

Ribot, J.C. (2000), “Decentralisation, Participation, and Representation: Administrative Apartheid in Sahelian Forestry”, in P.E. Peters (ed.), *Development Encounters: Sites of Participation and Knowledge* (Cambridge: Harvard University Press)

Rose, N. S. (1999), *Powers of Freedom: Reframing Political Thought* (Cambridge: Cambridge University Press)

Rusten, C., Kim S., Eng N.& Pak K. (2004), *The Challenges of Decentralisation Design in Cambodia* (Phnom Penh: CDRI)

Rusten, C., Kim S., Eng N. & Pak K. (2004), *The Challenges of Decentralization Design in Cambodia* (Phnom Penh: Cambodia Development Resource Institute)

Sneddon, C. & C. Fox (2007), "Power, Development, and Institutional Change: Participatory Governance in the Lower Mekong Basin", *World Development* 35 (12), pp. 2161-2181

United Nations Conference on Environment and Development (1992), "Earth Summit Agenda 21", Rio de Janeiro, 3-14 June

Wittfogel, K.A. (1957), *Oriental Despotism: A Comparative Study of Total Power* (New Haven: Yale University Press)

World Commission on Dams (2000), *Dams and Development: A New Framework for Decision-Making – The Report of the World Commission on Dams* (London: Earthscan Publications) pp. 404

World Summit on Sustainable Development (2002), "Plan of Implementation of the World Summit on Sustainable Development", Johannesburg, 26 August – 4 September

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI


១. Kannan, K.P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលម្អ* (ឯកសារពិភាក្សា លេខ ១) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ជាភាសាខ្មែរ ៤.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនខ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឺលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារ ពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,៥០ដុល្លារ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ច តំបន់សម្រាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍ កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៩. តេង-យូឌី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនRDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ ៤.៥០០រៀល ជាភាសាអង់គ្លេស ៤,៥០ដុល្លារ។

១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។

១៣. អ៊ឹង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកម្ពស់អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សា លេខ ១៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យ វិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,០០ដុល្លារ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៨,០០ដុល្លារ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សា៉វ៉ារី ប៊ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ* (ឯកសារពិភាក្សា លេខ១៨) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៧,០០ដុល្លារ។

១៩. ច័ន្ទ-សុផល ទេព-សា៉វ៉ារី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ ដុល្លារ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតម្លៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តម្លៃ ៨.០០០រៀល។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

២៣. Bruce McKenney និងព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិនិងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ១០.០០ ដុល្លារ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney ( ធ្នូ ២០០៣ ) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* ( ឯកសារពិភាក្សាលេខ២៧ ) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៨. ព្រុំ-តុលា និង Bruce McKenney ( ធ្នូ ២០០៣ ) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* ( ឯកសារពិភាក្សាលេខ២៨ ) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣០. Caroline Hughes និង គឹម-សេតារា ( មិថុនា ២០០៤ ) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរតម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥០ដុល្លារ។

៣១. Robert Oberndorf ( កក្កដា ២០០៤ ) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៣១ ) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥០ដុល្លារ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី ( ឧសភា ២០០៥ ) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* ( ឯកសារពិភាក្សាលេខ៣២ ) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣៣. Hansen, Kasper K. និង នុប-នេត ( ធ្នូ ២០០៦ ) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* ( Working Paper No. 33 ) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ។

៣៤. ប៉ក់-គឹមជឿន ហ៊ីង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig ( មីនា ២០០៧ ) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* ( ឯកសារពិភាក្សាលេខ៣៤ ) ជាភាសាអង់គ្លេស ៦,០០ដុល្លារ។

៣៥. គឹម-សេតារា និង Joakim Öjendal ( ឧសភា ២០០៧ ) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* ( ឯកសារពិភាក្សាលេខ៣៥ ) ជាភាសាអង់គ្លេស តម្លៃ ៤,០០ដុល្លារ។

៣៦. លឹម-សុវណ្ណារា ( វិច្ឆិកា ២០០៧ ) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៣៦ ) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥០ដុល្លារ។

៣៧. ចែម ផល្លា និងអ្នកផ្សេងទៀត ( ឧសភា 2008 ), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៨. ប៉ក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* ( Working Paper No. 38 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៩. ហ៊ីង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* ( Working Paper No. 39 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤០. អេង នេត្រា និង David Craig ( មីនា ២០០៩ ), *Accountability and Human Resource Management in Decentralised Cambodia* ( Working Paper No. 40 ) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian ( មេសា ២០០៩ ) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ ( ឯកសារពិភាក្សាលេខ ៤១ )* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ។

៤២. ធន់ វិមាលា អ៊ូ ស៊ីវហួច អេង នេត្រា និង លី តឹម ( តុលា 2009 ), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា ( ធ្នូ ២០០៩ ) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូនៅកម្ពុជា* ( ឯកសារពិភាក្សាលេខ ៤៣ ) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤៤. ច័ន្ទ សុផល ( ធ្នូ ២០០៩ ) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៤៥. ការបោះពុម្ពរបស់ CDRI ( ធ្នូ 2009 ), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៦. ការបោះពុម្ពរបស់ CDRI ( ធ្នូ 2009 ), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៧. ជា ជូ ( សីហា 2010 ), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៨. ការបោះពុម្ពរបស់CDRI ( សីហា2010 ), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី ( ឧសភា ២០១១ ), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយការចូលរួម ស្ដីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៥០. ប៉ក់ គឹមជឿន ( ឧសភា ២០១១ ), *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់* ជាភាសាអង់គ្លេសតម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths ( មិថុនា ២០១១ ), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥២. អ៊ួច ច័ន្ទតារ៉ានី សាំង ច័ន្ទហង្ស និង ផាន់ ដាលីស ( សីហា ២០១១ ), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាអង់គ្លេស តម្លៃ ៣,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៥៣. Chann Sopheak, Nathan Wales and Tim Frewer ( August 2011 ), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៥៤. ណាំងតិរុណ ខៀវ ដារ៉ាវី, Philip HIRSCH និង Isabelle WHITEHEAD ( កក្កដា ២០១១ ), *លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ ១២.០០០រៀល។

៥៥. កឹម សុធន ឈឹម ឈន់ ចេង វុទ្ធី និង សូ សុវណ្ណារិទ្ធ ( កក្កដា ២០១១ ), *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៥៦. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos ( កក្កដា ២០១១ ), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៧. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos ( កក្កដា ២០១១ ), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៥៨. ហ៊ីងវុត្ថា លន់ ពិដេ និង ផាន់ ដាលីស ( តុលា ២០១១ ) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា៖ លក្ខណៈសម្គាល់បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង* ជាភាសាខ្មែរ តម្លៃ ១០.០០០ រៀល អង់គ្លេស តម្លៃ ២,៥០ដុល្លារ។

*៥៩. ចែម ផល្លា, Philip Hirsch និង សុមេធ ប៉ារ៉ាឌី ( កញ្ញា ២០១១ ),* Hydrological Analysis in Support of *Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

*៦០. ការបោះពុម្ពរបស់ CDRI ( តុលា ២០១១ ),* Poverty Dynamics Study: Evidence from Nine Villages in *Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

*៦១. រស់ បណ្ឌេត, លី តឹម និង Anna Thompson ( កញ្ញា ២០១១ ),* Catchment Governance and Cooperation *Dilemmas: A Case Study from Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315 ខណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា

☎ (855-23) 881-384/881-701/881-916/883-603/012 867-278

🖷 (855-23) 880-734

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

តម្លៃ ១០.០០០៛

9 789995 052546